ស្រាវជ្រាវដោយ

**សេង តារា**

# មាសស្រមោលសិល្ប

## ភាគ១៣



អ្នកម្នាង សៀង ឌី និងលោកស៊ីន ស៊ីសាមុត
ច្រៀងក្នុងភាពយន្តរឿង "អប្សរា" ឆ្នាំ ១៩៦៦



**អ្នកម្នាង សៀង ឌី**

**កម្រងប្រវត្តិជីវិតសិល្បការិនីល្បីៗជំនាន់ដើម**

# សេច តារា

# ឃាស ស្រាបណគីរ

## ភាគ១៣

ស្នាដៃទី ៣០

រក្សាសិទ្ធិគ្រប់យ៉ាង

ព-ស : ២៥៥៦ -គ.ស: ២០១២

បណ្ណាគារ អង្គរធំ

ANGKOR THOM BOOK CENTER

Tel: 023 888 886 (4 Lines), Fax: 023 881 577
#261, Kampuchea Krom Blvd (St.128)
Phnom Penh, Cambodia
E-mail: info@atbc.com.kh
Website: www.atbc.com.kh

# វាចាអ្នកចងក្រង

ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ មានមិត្តអ្នកអានជាច្រើនបានចុចទូរសព្ទមកខ្ញុំហើយសួរថា "ហេតុអ្វីបានជាមិនឃើញសៀវភៅ "មាសស្រោបនគរ" និងសៀវភៅ "ថ្ងៃលិចឯនាយសមុទ្រ" ចេញផ្សាយសោះ ? តើខ្ញុំខ្វះឯកសារ? ឬរកប្រវត្តិអ្នកចម្រៀងនិងអ្នកនិពន្ធផ្សេងៗមិនទាន់បាន ?

បាទ ! ឆ្លៀតឱកាសនេះខ្ញុំសូមបកស្រាយជូនមិត្តអ្នកអានថា ស្ទើរពេញ១ឆ្នាំមកនេះ ខ្ញុំពិតជាមិនបានចេញសៀវភៅភាគថ្មីៗមែន តែមិនមែនរកឯកសារពុំបានទេ គឺមានឯកសារច្រើនណាស់ដែលខ្ញុំរកបាន តាំងពីប្រវត្តិអ្នកចម្រៀងនិងប្រវត្តិអ្នកនិពន្ធដែលខ្ញុំបានចុះសម្ភាសន៍សាច់ញាតិរបស់ពួកគាត់ផ្ទាល់ ប៉ុន្តែមូលហេតុនៃការចេញផ្សាយភាគថ្មីៗយឺតយ៉ាវនេះព្រោះតែខ្ញុំរវល់ច្រើនពេក ។ ហើយនេះមិនត្រឹមតែហៅថា "**រវល់ធម្មតា**" ទេ គឺចូលដល់ថ្នាក់ "**មមាញឹក**" មែនទែន ។ រវល់នោះគឺដោយសារខ្ញុំត្រូវចុះទៅស្វែងសាច់ញាតិរៀមច្បងទាំងនោះនៅតាមខេត្តនានា ពិសេសអ្វីដែលធ្វើឱ្យខ្ញុំដកខ្លួនមកសរសេរមិនបាននោះ ដោយសារខ្ញុំជាប់ធ្វើការឱ្យវិទ្យុ ។

ដូច្នេះទើបមួយរយៈនេះ ខ្ញុំគ្មានពេលច្រើនទេព្រោះធ្វើការច្រើនពេក សូម្បីតែពេលហូបបាយសឹងគ្មានផង ។ ឯសៀវភៅ "មាសស្រោបនគរ" ភាគ ទី១៣ នេះ គឺខ្ញុំឆ្លៀតពេលសរសេរយ៉ាងលំបាកបំផុតទើបអាចចេញផ្សាយបានដើម្បីបំពេញទៅតាមការទាមទាររបស់មិត្តអ្នកអានដែលរង់ចាំយូរមកហើយ ។

នៅពេលឮខ្ញុំបកស្រាយដូច្នេះ ប្រហែលមានមិត្តអ្នកអានខ្លះចោទសួរមកវិញថា "ចុះបើការស្រាវជ្រាវនេះរវល់ម្លឹងហើយ ម៉េចក៏ទៅធ្វើការឱ្យវិទ្យុទៀត ? ..."

បើមិត្តអ្នកអានចោទសួរបែបនេះមែន គឺជាសំនួរមួយល្អណាស់ ហើយខ្ញុំរីករាយ

នឹងឆ្លើយមែនទែន ។...បាទ! ការពិតខ្ញុំគួរតែយកពេលវេលាទាំងឡាយមកសរសេរសៀវភៅមែនព្រោះវាកំពុងពេញនិយម កំពុងទទួលបាននូវការគាំទ្រពីបងប្អូនប្រជាពលរដ្ឋទូទៅ ប៉ុន្តែប្រហែលបងប្អូនមិនដឹងទេថា ការស្រាវស្រាវដើម្បីចងក្រងចេញជាសៀវភៅមិនមែនស្រួលសោះឡើយ គឺលំបាកមែនទែន មិនដូចការសរសេររឿងប្រលោមលោក ដែលគ្រាន់តែអង្គុយក្នុងបន្ទប់ស្ងាត់ ស្រមើលស្រមៃសរសេរចេញមកនោះឡើយគឺការសៀវភៅនេះទាមទារការធ្វើដំណើរឆ្ងាយៗរកឯកសារ។ហើយការធ្វើដំណើរត្រូវចំណាយពេលវេលា ចំណាយកម្លាំង ពិសេសចំណាយថវិកាច្រើនណាស់ តាំងពីការហូបចុក ចាក់សាំងម៉ូតូ និងស្នាក់នៅជាដើម ហើយទាំរាំសរសេរចេញមួយភាគ មិនមែនតែ១ខែឬ២ខែនោះទេ យ៉ាងហោចណាស់ក៏ចាប់ពី៣ខែទៅ៥ខែដែរ ។ រីឯតម្លៃនៃការលក់កម្មសិទ្ធិបោះពុម្ពនោះ មិនមែនបានថ្លៃជាងអ្នកនិពន្ធរឿងប្រលោមលោកឯណា គឺបានតែ២០០ ទៅ៣០០ដុល្លារដូចតែគេឯងអញ្ចឹងដែរជួនកាលថោកជាងអ្នកនិពន្ធខ្លះផង។ ដូច្នេះមិត្តអ្នកអានជួយពិចារណាទៅមើល បើ៣-៤ខែ ប្រាក់ចំណូលបានតែប៉ុណ្ណឹងតើខ្ញុំរស់ឯណាកើត?បើប្រៀបធៀបទៅគឺចាញ់ប្រាក់ខែកម្មការិនីកាត់ដេរផង ។ ហេតុនេះ ខ្ញុំត្រូវតែរកការងារផ្សេងដើម្បីយកប្រាក់ជាក់សាំងម៉ូតូដើររកឯកសារ មកទិញបាយហូប បង់ថ្លៃផ្ទះ ថ្លៃទឹក ថ្លៃភ្លើង...។ល។ ព្រោះការស្រាវជ្រាវនេះ គ្មានមូលនិធិគ្មានក្រសួងគ្មានអង្គការណាឧបត្ថម្ភមួយកាក់ឡើយ គឺខ្ញុំធ្វើដោយសេចក្តីស្រលាញ់ និង ដោយលទ្ធភាពផ្ទាល់ខ្លួនរបស់ខ្ញុំសុទ្ធសាធទាំងអស់ ។ នេះមិនទាន់មានប្រពន្ធផង ខ្ញុំលំបាកយ៉ាងនេះទៅហើយ ប្រសិនបើមានប្រពន្ធវិញ មិនដឹងគេលែងក្បាលចោលតាំងអង្កាល់ទេ ? ព្រោះកន្លះឆ្នាំ អាចរកលុយបានតែ២០០ទៅ៣០០ដុល្លារនោះ ។ កុំថាឡើយទិញបាយញាត់ក្រពះ សូម្បីតែបង់ថ្លៃផ្ទះ ថ្លៃទឹក ថ្លៃភ្លើងក៏មិនគ្រប់ផង ។ ប៉ុន្តែការពិតទៅ ខ្ញុំក៏ចង់ឈប់ពីការងារ

វិទ្យុម្តងៗដែរដើម្បីយកពេលមកស្រាវជ្រាវនិងសរសេរសៀវភៅនេះ តែខ្ញុំខ្លាចពេលខ្ញុំកំពុងសរសេរៗ ស្រាប់តែដាច់ពោះស្លាប់ហើមស្អុំងក្នុងបន្ទប់គ្មាននរណាដឹង ពិតជាចង្រៃផ្ទះជួលរបស់គេមិនខាន ហើយគ្មានឱកាសសរសេរបន្តឡើយ ។ ហេតុនេះខ្ញុំក៏ទ្រាំធ្វើនេះបន្តិច ធ្វើនោះបន្តិចដើម្បីបង្គ្រប់គ្នាទៅវិញទៅមក ។ ហើយនេះមិនមែនជាការត្អូញត្អែរដើម្បីឱ្យមិត្តអ្នកអានអាណិត ជួយផ្តល់លុយ ផ្តល់កាក់ ឬទិញចាយឱ្យហូបនោះទេ តែខ្ញុំចង់បង្ហាញពីរឿងដ៏សែនលំបាកៗជាច្រើនដែលខ្ញុំជួបប្រទះក្នុងជីវភាពនិងការងារប្រចាំថ្ងៃ ។ តាមពិតមកដល់ឆ្នាំ ២០១២ នេះខ្ញុំអាយុ៣០ឆ្នាំហើយ ហើយវ័យនេះគួរតែខ្ញុំត្រូវរកប្រពន្ធឱ្យជួយដាំបាយនិងបង្កើតកូនផងដែរ តែលទ្ធភាពខ្ញុំពេលនេះមិនអាចរកប្រពន្ធបានឡើយ ហើយខ្ញុំសូមប្រាប់បងប្អូនទាំងអស់ថា ពេលនេះ ខ្ញុំពិតជាចង់បានប្រពន្ធមែនព្រោះអាយុកាន់តែច្រើនហើយ ខ្លាចគេសើចចំអកថា "កម្លោះចាស់" ព្រោះកម្លោះៗក្នុងភូមិខ្ញុំ ព្រមទាំងបងប្អូនខ្ញុំទាំង៩នាក់ គេរៀបការ មានកូនមានចៅអស់ទៅហើយ ។ ហេតុនេះ ខ្ញុំក៏ចង់សាងអនាគតនឹងគេដែរ ព្រោះនៅមានកម្លាំង ខ្លាចចាស់ពេកគេមិនយកធ្វើប្តី បើចាស់មានលុយ មិនថ្វីទេ តែបើចាស់ហើយក្រទៀតនោះ ពិតជាមានតែផ្លូវសុំសីលនៅវត្តមិនខាន ។

សូមអរគុណ បងប្អូនដែលអាននូវទុក្ខសោករបស់ខ្ញុំ ហើយសំរាប់ភាគ ១៣ នេះ លោកអ្នកនឹងបានជ្រាបនូវប្រវត្តិរបស់សិល្បការិនីជើងចាស់មួយរូបទៀតគឺអ្នកម្នាង សៀង ឌី ។ សូមបញ្ជាក់ថា សៀវភៅសរសេរចប់តាំងពីដើមឆ្នាំ ២០១១ ម្លេះ ប៉ុន្តែខ្ញុំទើបសម្រេចចិត្តចេញផ្សាយនៅចុងឆ្នាំ ២០១២ នេះឯង ។

កំហុសខុសឆ្គងដោយអចេតនាផ្សេងៗ សូមមិត្តអ្នកអានមេត្តាអភ័យទោស ។

**ភ្នំពេញ ថ្ងៃទី ៣១ ធ្នូ ឆ្នាំ ២០១២**

# គោរពជូន

មិត្តអ្នកអានជាទីស្រលាញ់ ! នៅក្នុងសៀវភៅ"មាសស្នេហ៍បនគរ"ភាគទី១២ នេះ ខ្ញុំបាទ **សេង តារា** សូមឧទ្ទិសស្នាដៃនេះជូនដល់វិញ្ញាណក្ខន្ធ៍រៀមច្បងកវីនិពន្ធ និងតន្ត្រីករទាំងអស់ដែលបានទទួលអនិច្ចកម្មតាំងក្នុងជំនាន់ដើម និងជំនាន់ក្រោយ នេះ សូមឱ្យពួកលោកបានទៅសោយសុខនាឋានបរមសុខនៅឯបរលោកកុំបីឃ្លាង ឃ្លាតឡើយ ហើយចំពោះរៀមច្បងដែលនៅមានជីវិតក៏សូមឱ្យអស់លោកមានសុខ ភាពល្អ មានអាយុយឺនយូរ និងមានសុភមង្គលគ្រប់ពេលវេលា ។ ជាពិសេស ក៏សូម គោរពផ្ញើជូនអ្នកម្នាង **សៀង ឌី** ដែលជាសិល្បការិនីជើងចាស់ដែលខ្ញុំលើកយកមក លាតត្រដាងស្នាដៃនិងទេពកោសល្យនៅក្នុងភាគនេះ សូមឱ្យសៀវភៅនេះក្លាយជា វត្ថុអានុស្សាវរីយ៍ដ៏មានតម្លៃចំពោះជីវិតអ្នកម្នាងតទៅគ្រប់ជំនាន់ ។

ម្យ៉ាងទៀត ខ្ញុំបាទក៏សូមផ្ញើជូនដល់អ្នកមានគុណទាំងពីរ គឺលោកឪពុក **សេង ម៉ៅ** និងអ្នកម្ដាយ **ស្រេង គីមស្រ៊ី** ដែលសព្វថ្ងៃនៅរស់ឯស្រុកកំណើត គឺភូមិ**ជំនីក** ឃុំ **គំពង់រាប** ស្រុក **ព្រែកប្បាស** ខេត្ត **តាកែវ** ព្រមទាំងលោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានផ្ដល់ចំណេះដឹងដល់រូបខ្ញុំតាំងពីបឋមសិក្សាដល់មហាវិទ្យាល័យ។ គឺដោយ សារអស់លោកអ្នកមានគុណទាំងនេះហើយដែលបានជម្រុញខ្ញុំឱ្យមានថ្ងៃនេះ ។

ចុងក្រោយ សូមឧទ្ទិសជូន **តាឡូង** ដែលបានចែកឋានកាលពីឆ្នាំ **១៩៩០** និង ឧទ្ទិសជូនម៉ែយាយ **ហ៊ុន ផូ** ជាទីស្រលាញ់ និងគោរពបំផុតស្មើនឹងព្រះពុទ្ធក្នុងដួង ចិត្តរបស់ចៅដែលបានចែកឋានទៅកាលពីឆ្នាំ **២០០៥** សូមវិញ្ញាណក្ខន្ធ៍អ្នកទាំង ពីរបានដល់ត្រើយសុគតិភព ។

**ដោយស្មោះ....ពីខ្ញុំ** **សេង តារា**

# ជីដូនជីតាខាងម្ដាយ

ជីដូនខាងឪពុក
លោកយាយ យឹម សាំង
(ស្លាប់ឆ្នាំ ២០០៦)









## អ្នកមានគុណទាំងពីរ



លោកឪពុក សេង ម៉ៅ និងអ្នកម្ដាយ ស្រេង គីមស្រ៊ី

ជីដូនជីតាចិញ្ចឹមខាងម្ដាយ




# ជីដូនជីតា
# និងឪពុកម្ដាយ របស់
# ខ្ញុំបាទ សេង តារា

# ឯកសារមាស

"មាសស្រោបនគរ" មានន័យថា អ្នកចម្រៀងកវីនិពន្ធ តន្ត្រីករ និងសិល្បករ សិល្បការិនី ឆ្នើមៗជំនាន់ដើមទាំងនោះប្រៀបបាននឹង "ដុំមាស" មក "រុំស្រោបនគរ" ខ្មែរយើងឱ្យរីកចម្រើននិងភ្លឺរន្ទាលរុងរឿងយ៉ាងត្រចះត្រចង់កាលពីជំនាន់នោះ ហើយដែលបានក្លាយជាតួរតន្ត្រីអមតៈរហូតមកដល់សព្វថ្ងៃ និងតទៅអនាគតគ្មានព្រំដែន

# អ្នក ម្នាង សៀង ឌី



ជាសិល្បការិនីរៀមច្បងដែលបានទទួលនូវការបណ្តុះបណ្តាលពីលោក ស៊ីន ស៊ីសាមុត និងដែលបានប្រលងជាប់លេខ ១ នៅក្នុងសមាជជាតិដំបូងគេ នៅអំឡុងពាក់កណ្តាលទ.វឆ្នាំ ១៩៥០ ប្លែកតែគ្រូបែរជាធ្លាក់ទៅលេខ២ ស្ពានមិនដល់ ...

បើនិយាយពីទេពកោសល្យនិងស្នាដៃសិល្បករ សិល្បការិនី តន្ត្រីករ និងកវីនិពន្ធជំនាន់ដើម គឺជាប្រធានបទដ៏វែងអន្លាយដែលយើងនិយាយមិនចប់មិនហើយ ព្រោះរៀមច្បងទាំងនោះសុទ្ធតែមានភាពវិសេសវិសាលនិងខ្សែជីវិតប្លែកៗគ្នាដែលគួរឱ្យចង់ដឹងចង់តាមដាន ។ ជួនកាលប្រវត្តិរៀមច្បងខ្លះមានរឿងរ៉ាវដែលយើងនឹកស្មានមិនដល់ក៏មានហើយអស់លោកខ្លះ មានរឿងដ៏គួរឱ្យអស់សំណើចក៏មានដែរ ។ ជាក់ស្តែងដូចជាប្រវត្តិរបស់កំពូលវិចិត្រករជក់ទិព្វ **ញឹក ឌឹម** ដែលខ្ញុំសរសេរនៅក្នុងសៀវភៅ"**មាសស្រោបនគរ" ភាគ ១០** បានធ្វើឱ្យមិត្តអ្នកអានគ្រវីក្បាលហួសចិត្ត ហើយផ្ទុះសំណើចគ្រប់ៗគ្នានូវរឿងរកាំរកូសពីរលើករវាងលោក និងអធិរាជសម្លេងមាស **ស៊ីន ស៊ីសាមុត** ដែលរឿងទី១ លោក **ញឹក ឌឹម** ខឹងលោក **ស៊ីន ស៊ីសាមុត** ដែលមិនបានមកច្រៀងបទ"**កុលាបមួយទង**"ឱ្យគាត់នៅលើឆាកទូរទស្សន៍ខណៈគាត់រៀបចំពិធីសំដែងឆាកឈុតក្នុងរឿង"កុលាបមួយទង" របស់គាត់ ។ រីឯរឿងទី២ គាត់ខឹងលោក **ស៊ីន ស៊ីសាមុត** ច្រៀងបទ"**រំដួលស្ទឹងសង្កែ**" ដែលត្រង់ទំនុកបទ្ទរមានឃ្លាថា "***វិចិត្រករអើយកុំបាច់គូរអី នៅក្នុងលោកិយស្រើល្អគ្មានទេ មានតែរំដួលដងស្ទឹងសង្កែ....***"ដែលត្រង់ឃ្លានេះ លោក **ញឹក ឌឹម** ចោទថា លោក **ស៊ីន ស៊ីសាមុត** ច្រៀងចំអកឱ្យគាត់ជាវិចិត្រករនោះ ប៉ុន្តែការពិតបទនោះ គឺលោក **គង្គ ប៊ុនឈឿន** ជាអ្នកនិពន្ធសោះ ចំណែកលោក **ស៊ីន ស៊ីសាមុត** គ្រាន់តែច្រៀងប៉ុណ្ណោះ គ្មានដឹងរឿងអ្វីឡើយ ។ ដោយឡែក និយាយអំពីកវីរៀមច្បង **ពៅ ស៊ីផូ** ដែលជាកវីសំបូរស្នេហ៍ចម្រុះបែបវិញ ជាទូទៅគេស្គាល់លោកត្រឹមតែជាអ្នកនិពន្ធបទភ្លេង ទំនុកច្រៀងប៉ុណ្ណោះ ប៉ុន្តែគួរបញ្ជាក់ថា ក្រៅពីជាកវីនិពន្ធដ៏ល្បីល្បាញនោះ លោកក៏ជានាយប៉ូលីស (Inspector Police) មួយរូបផងដែរ ហើយគឺលោក **ពៅ ស៊ីផូ** នេះឯងដែលជាគ្រូរបស់អធិរាជសម្លេងមាស **ស៊ីន ស៊ីសាមុត** និង

ជាអ្នកជួយជ្រោមជ្រែងលោក **ស៊ីន ស៊ីសាមុត** ឱ្យក្លាយទៅជាអ្នកចម្រៀងអាជីពពិតប្រាកដ ព្រមទាំងជាកវីដែលនិពន្ធចម្រៀងឱ្យលោក **ស៊ីន ស៊ីសាមុត** ច្រៀងផ្សាយតាមវិទ្យុជាតិមុនគេបំផុតនៅអំឡុងឆ្នាំ **១៩៥៣-៥៤** ហើយបានដឹកនាំឱ្យអ្នកចម្រៀងឯកខ្មែរមានកេរ្តិ៍ឈ្មោះល្បីរន្ទឺរហូតដល់សព្វថ្ងៃ ។

ក្រលេកមកអ្នកម្នាង **សៀង ឌី** វិញ បងប្អូនប្រជាពលរដ្ឋខ្មែរទាំងឡាយពិតជាធ្លាប់ឮឈ្មោះជាក់ជាមិនខាន ជាពិសេសបើនិយាយចំពោះអ្នកនិយមស្តាប់ចម្រៀងជំនាន់ដើមវិញ គឺគ្មានអ្នកណាដែលមិនស្គាល់កិត្តិសព្ទដ៏សែនល្បីល្បាញរបស់សិល្បការិនីដ៏មានស្នាដៃវិសេសវិសាលរូបនេះឡើយ ។ អ្នកម្នាងគឺជាអ្នកចម្រៀងមួយរូបដែលបានកសាងកេរ្តិ៍ឈ្មោះតាំងពីអំឡុងពាក់កណ្តាលទ.វឆ្នាំ **១៩៥០** ម្លេះ គឺមុនអ្នកស្រី **ម៉ែន រ៉ន** អ្នកស្រី **ម៉ៅ សារ៉េត** អ្នកស្រី **ឈុន វណ្ណា** អ្នកស្រី **ព្រាំ យិតចូ** ឬអ្នកស្រី **សូ សាវឿន** ទៅទៀត ។ ហើយប្រៀបធៀបទៅអ្នកស្រី **រស់ សេរីសុទ្ធា** អ្នកស្រី **ហួយ មាស** និងអ្នកស្រី **យារ សោភ័ណ** ជាដើម គឺអ្នកម្នាងកាន់តែមុនឆ្ងាយទៅទៀត ។



ពេលដែលអ្នកម្នាងចូលប្រឡូកក្នុងសិល្បៈតន្ត្រីនេះ អ្នកចម្រៀងខាងលើនេះនៅជាកុមារីនៅឡើយទេ ។ អ្នកម្នាងបានចូលហាត់ច្រៀងតាំងពីអាយុមិនទាន់គ្រប់១០ឆ្នាំម្លេះ គឺតាំងពីអំឡុងដើម ទ.វឆ្នាំ **១៩៥០** ដោយបានចូលហាត់ច្រៀងនៅក្នុងវង់ភ្លេងមួយឈ្មោះថា "**រាជសីហ៍តន្ត្រី**" ហើយបានទទួលនូវការបណ្តុះបណ្តាលពីតន្ត្រីករនិងអ្នក

និពន្ធជើងចាស់ជាច្រើនដូចជាលោក **យ៉ាន់ កាយ៉ុន** លោក **ម៉ែរ ប៊ុន** លោក **យ៉ង់ ឈឿង** ហៅ **សំនៀងឫទ្ធី** លោក **ពៅ ស៊ីផូ** និងលោក **ភួង បុប្ផា** .....ជាដើម ។ បន្ថែមលើនេះ អ្នកម្នាងក៏ជាកូនសិស្សជំនិតរបស់លោក **ស៊ីន ស៊ីសាមុត** ដែរ ។

ដោយបានទទួលការយកចិត្តទុកដាក់ពីសំណាក់កវីនិពន្ធនិងតន្ត្រីករទាំងនេះ បូករួមនឹងការប្រឹងប្រែង ព្យាយាមរបស់អ្នកម្នាងផ្ទាល់ផង ទើបក្រោយមកនៅពេលដែលអ្នកម្នាងចូលប្រឡូកនៅក្នុងអាជីពតូរតន្ត្រីនេះបានធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់អ្នកម្នាងត្រូវបានគេទទួលស្គាល់ និងកោតសរសើរយ៉ាងផុសផុល ។ សម្លេងដ៏ពិរោះរបស់អ្នកម្នាងត្រូវបានគេថតចាក់ផ្សាយតាមវិទ្យុជាតិ និងថតថាសលក់ព្រោងព្រាតដើម្បីបំពេអារម្មណ៍ប្រជាពលរដ្ឋខ្មែរទូទៅ ។ បន្តិចម្តងៗ កេរ្តិ៍ឈ្មោះអ្នកម្នាងមិនត្រឹមតែទទួលនូវការពេញនិយមពីមជ្ឈដ្ឋានអ្នកស្តាប់ដែលជាប្រជានុរាស្ត្រសាមញ្ញប៉ុណ្ណោះ គឺថែមទាំងល្បីរន្ទឺសុះសាយដល់ព្រះមហាក្សត្រទៀតផង គឺ **សម្តេចឪ ព្រះករុណា ព្រះបាទ នរោត្តម សីហនុ** ព្រះបិតាឯករាជ្យជាតិយើងសព្វថ្ងៃនេះ ។ ហើយអ្នកម្នាងក៏មានកិត្តិយសដោយត្រូវបានព្រះករុណាជីវិតតម្កល់លើត្បូងនិពន្ធចម្រៀងឱ្យច្រៀងបញ្ចូលក្នុងខ្សែភាពយន្តរបស់ទ្រង់ជាមួយលោក **ស៊ីន ស៊ីសាមុត** ប្រកបដោយមោទនភាពក្រៃលែង ហើយខ្សែភាពយន្តនោះត្រូវបានគេតម្កល់ទុកមកដល់បច្ចុប្បន្នផងដែរ ។

អ្នកម្នាង **សឿង ឌី** ជាសិល្បការិនីដែលមិនងាយរកបាន គឺទាំងសម្លេងនិងទាំងអាកប្បកិរិយា ។ ទោះបីអ្នកម្នាងជាប់សាច់សារលោហិតរាជវង្សក៏ដោយ តែអ្នកម្នាងមិនប្រកាន់ឬកឆ្មើងឆ្មៃ ក្រអឺតក្រទមឡើយ គឺបើសិនអ្នកណាអញ្ជើញអ្នកម្នាងទៅចូលរួមកម្មវិធីអ្វីមួយក៏អ្នកម្នាងផ្តល់កិត្តិយសអញ្ជើញទៅដែរជាពិសេសកម្មវិធីដែលទាក់ទងនឹងសិល្បៈ កុំថាឡើយចំពោះអ្នកមានមុខមាត់ធំៗខ្ពស់ៗដែលអ្នកម្នាងធ្លាប់ស្គាល់ គឺបើទោះ

អ្នកនោះ អ្នកម្នាងមិនធ្លាប់ស្គាល់ហើយគ្មានមុខមាត់ក្នុងសង្គមក៏ដោយ ក៏អ្នកម្នាងទទួលនូវការអញ្ជើញដែរ ។ ចំពោះអ្វីដែលខ្ញុំលើកឡើងនេះ មិនមែនជាការបញ្ជើចបញ្ជើរ ឬពោលបញ្ជោរដោយសារតែអ្នកម្នាងជាមនុស្សមានមុខមាត់ធំក្នុងសង្គមនិងជាប់សាច់ខ្សែស្រឡាយរាជវង្សទេ តែនេះគឺជាការពិតដែលខ្ញុំបានជួបផ្ទាល់ ។



អ្នកម្នាងសៀង ឌី និងអ្នកស្រី ឌី សាវេ៉ត(ភ្នំពេញ ១៩៩៩)

ជាក់ស្តែង កាលពីចុងឆ្នាំ**២០០៩** កន្លងទៅខ្ញុំបានអញ្ជើញអ្នកម្នាងតាមទូរសព្ទដើម្បីមកសម្ភាសន៍នៅស្ថានីយ៍វិទ្យុ **ឧន្លេ** FM 102.5 MHz ពេលនោះអ្នកម្នាងក៏បានមកតាមការអញ្ជើញរបស់ខ្ញុំដោយចិត្តទូលាយជាទីបំផុត ដោយមិនគិតថា ខ្ញុំអញ្ជើញតាមទូរសព្ទគ្មានលិខិតអញ្ជើញផ្លូវការឡើយ ហើយក៏មិនគិតថា ខ្ញុំគ្រាន់តែជាមនុស្សម្នាក់ដែលគ្មានបុណ្យសក្តិ ឬ មុខមាត់ក្នុងសង្គមដែរ ។ ដោយពិតនោះ អ្នកម្នាងមិនដែលឃើញមុខខ្ញុំ ឬស្គាល់ឈ្មោះខ្ញុំបន្តិចឡើយ ។ ហើយចំពោះអត្តចរិកដ៏ទូលំទូលាយនេះ ក៏ធ្វើឱ្យខ្ញុំនឹកឃើញដល់សិល្បការិនីមួយរូបទៀតដែរ នោះគឺអ្នកស្រី **ឌី សាវ៉េត** អតីតតារាភាពយន្តដ៏ល្បីល្បាញក្នុងជំនាន់អ្នកម្នាងដែរនោះ ។ អ្នកស្រី **ឌី សាវ៉េត** នៅតែមានសេចក្តីស្រលាញ់សិល្បៈ និងមិនឆ្មើងឆ្មៃដូចអ្នកម្នាង **សៀង ឌី** ដែរ អ្នកណាអញ្ជើញចូលរួមកម្មវិធីអ្វីក៏អ្នកស្រី **ឌី សាវ៉េត** មិនបដិសេធដែរ លើកលែងតែអ្នកស្រីរវល់ ។

ដោយឡែក អ្នកម្នាង **សៀង ឌី** គឺជាសិល្បការិនីមួយរូបក្នុងចំណោមសិល្បករនិងសិល្បការិនីមួយចំនួនតូចដែលមានភព្វវាសនារស់រានមានជីវិតដល់សព្វថ្ងៃដែរ ដែលអ្នកទាំងនោះរួមមានដូចជាអ្នកស្រី **ឈុន វណ្ណា** (នៅអាមេរិច) អ្នកស្រី **ជួប សារឿន** (នៅកម្ពុជា) អ្នកស្រី **ឌី សាខន** (អាមេរិច) អ្នកស្រី **ស្វ សាវឿន** (នៅបារាំង) អ្នកស្រី **ហែម សុវណ្ណ** (នៅភ្នំពេញ) លោក **មាស ម៉េងហ៊ាង** (នៅបារាំង) លោក **វ៉ា សារុន** (នៅភ្នំពេញ) លោក **កុល សែម** (នៅភ្នំពេញ) និងលោក **ថាច់ សូលី** (នៅកំពង់ឆ្នាំង) ។ល។ ហើយចំពោះមូលហេតុដែលអ្នកម្នាងមានវាសនារស់រានមកដល់សព្វថ្ងៃ មិនមែនអ្នកម្នាងរួចជីវិតដោយចៃដន្យពីរបប **ប៉ុល ពត** ដូចអ្នកចម្រៀងខាងលើទេ ប៉ុន្តែដោយសារអ្នកម្នាងបានចេញទៅរស់នៅប្រទេសបារាំងជាមួយស្វាមីតាំងពីដើមទ.វឆ្នាំ ១៩៧០មម្លេះ ហេតុនេះទើបអ្នកម្នាងមិនបានឆ្លងកាត់របបដ៏មហាឃោរឃៅនោះ ។

ចំពោះប្រវត្តិនិងស្នាដៃរបស់អ្នកម្នាង **សៀង ឌី** ខាងក្រោមនេះ គឺជាប្រសាសន៍ផ្ទាល់របស់អ្នកម្នាងដែលខ្ញុំបានអញ្ជើញមកសម្ភាសន៍នៅវិទ្យុ **ទន្លេ** FM 102.5 Mhz កាលពីចុងឆ្នាំ **២០០៩** កន្លងទៅ ។ ដូច្នេះ ដើម្បីចង់ដឹងថា តើខ្សែជីវិតរបស់សិល្បការិនីដ៏ល្បីល្បាញរូបនេះមានរឿងរ៉ាវយ៉ាងណានោះ សូមមិត្តអ្នកអានតាមដានដូចតទៅ ៖

## ~ប្រវត្តិគ្រួសារនិងកុមារភាព

អ្នកម្នាង **សៀង ឌី** (ឈ្មោះដើម **សូ សុវណ្ណារី**) កើតនៅអំឡុងឆ្នាំ **១៩៤៦** ត្រូវនឹងខែ **អាសាឍ ឆ្នាំ ចរ** ក្នុងគ្រួសារដែលមានជីវភាពដ៏ធូធារមួយនៅរាជធានីភ្នំពេញ ក្បែរវិមានឯករាជ្យ ។ លោកឪពុកឈ្មោះ **សូ ឌិន** ជាអ្នកដឹកនាំសំដែងនិងតាក់តែងរឿងល្ខោនឱ្យលោកឃុនព្រះម្នាង **យិន តាត** ជាព្រះមហេសី **ម្លូលស៊ីសុវត្ថិ** នៅម្តុំផ្សារ**ស៊ីឡឹប** ។ ចំណែកអ្នកម្តាយឈ្មោះ **ឯម សីរន្ធ** ហៅ **សោភ័ណនារី** ជាអ្នកចម្រៀងបុរាណនៅទ.វឆ្នាំ **១៩៤០** ក្នុងវង់ភ្លេងព្រះរាជទ្រព្យ ។

អ្នកម្នាងមានបងប្អូនបង្កើតចំនួន ៥ នាក់(ស្រី ៤ ប្រុស ១) រួមមាន ៖

១- **សូ សាវិនណារ៉ា** (ស្រី) ភរិយាលោក ហាស់ សាឡន

២- **សូ សុភិន** (ស្រី) ប្តីជាអ្នកជួលជុលយន្តហោះ និងជាតន្ត្រីករផ្លុំសាក់សូហ្វូន ក្រោយមកជាទាហានជើងគោកថ្នាក់ ១(ចូលនិវត្តន៍) ។

៣- **សូ សុវណ្ណារី** (សៀង ឌី) (ស្រី)

៤- **សូ សុវណ្ណារីន្ធ** (ប្រុស) និស្សិតនៅសាលាពាណិជ្ជកម្ម

៥- **សូ សុវ៉ាន់ធី** (សៀង វ៉ាន់ធី) (ស្រី) អ្នកចម្រៀងវង់ភ្លេង SKD

ក្នុងចំណោមបងប្អូនទាំង ៥ នាក់នេះ សព្វថ្ងៃនៅរស់ ២ នាក់ប៉ុណ្ណោះ គឺរូបអ្នកម្នាងនិងបងស្រីទី ២ ឈ្មោះ **សូ សុភិន** ។



លោក សូ ជិន
ឪពុកអ្នកម្នាង សៀង ឌី

## សាច់ញាតិគ្រួសារអ្នកម្ដាង សៀង ឌី ឆ្នាំ ១៩៩៣ នៅភ្នំពេញ




## សាច់ញាតិអ្នកម្ដាង សៀង ឌី នៅភ្នំពេញ ក្នុងអំឡុងឆ្នាំ ១៩៩៩



## ការសិក្សា

អ្នកម្នាងចូលរៀននៅអាយុប្រហែល ៦ ឆ្នាំនៅសាលា **ព្រះកែវមរកត** ដែលស្ថិតក្នុងព្រះបរមរាជវាំងសព្វថ្ងៃ ។ ជាមួយគ្នានោះ ក្រៅពីការសិក្សាចំណេះទូទៅ រៀងរាល់ថ្ងៃព្រហស្បតិ៍ អ្នកម្នាងនិងកូនសិស្សដទៃទៀតដែលរៀននៅសាលាព្រះកែវមរកត ត្រូវបានគេឱ្យទៅហាត់រៀនរាំរបាំព្រះរាជទ្រព្យជានិច្ចនៅឯប្រាសាទចន្ទ័ឆាយា ។ ដូច្នេះ នេះគឺជាមូលដ្ឋានមួយដែលបណ្តុះបេះដូងនិងកាយសម្បទាអ្នកម្នាងឱ្យជក់ជាប់សិល្បៈតាំងពីពេលនោះរហូតមក ។ ធម្មតាដោយនៅជាកុមារីដែលចូលចិត្តអ្វីប្លែកនិងសប្បាយបានធ្វើឱ្យអ្នកម្នាងយកចិត្តទុកដាក់លើការរាំច្រៀងនេះមែនទែន ។ ប៉ុន្តែចំពោះការសិក្សាអក្សរសាស្ត្រនិងចំណេះទូទៅផ្សេងៗក៏អ្នកម្នាងមិនបានធ្វេសប្រហែសដែរ គឺផ្ចិតផ្ចង់ស្មើគ្នានឹងការហាត់រាំដែរប៉ុន្តែពេលនោះដោយសារសាលារៀនខាងចំណេះទូទៅដែលអ្នកម្នាងរៀនមានការផ្លាស់ប្តូរជាញឹកញាប់នោះ ធ្វើឱ្យអ្នកម្នាងមិនបានរៀនសូត្រជាប់លាប់ល្អទេ ។

រៀននៅសាលាព្រះកែវមរកតបានប្រហែលជាង៣ឆ្នាំ សាលានោះក៏ផ្លាស់មករៀនក្រោយវាំងវិញ ។ លុះរៀនទីនោះបានប្រហែលជាង១ឆ្នាំទៀត សាលានោះក៏ផ្លាស់មកម្តុំផ្សារបឹងកេងកងទៀត ។ តែទោះបីសាលាផ្លាស់ប្តូរទីតាំងញឹកញាប់ក៏ដោយ ក៏អ្នកម្នាងនៅតែតស៊ូរត់តាមសាលារហូតមកមិនបានបោះបង់ការសិក្សាចោលទេ លើសពីនេះក្រៅរៀននៅសាលារដ្ឋ អ្នកម្នាងក៏ឆ្លៀតពេលទៅរៀននៅសាលាឯកជនបន្ថែមផងដែរ ហើយតាមដែលអ្នកម្នាងនៅចងចាំ សាលានោះឈ្មោះ "សាលា **ថៃខ៊ុកក្វាន់**" ដែលស្ថិតនៅជិតផ្លូវ Pasteur ( បច្ចុប្បន្ន) គ្មានទេ ។

## ដើមហេតុចូលប្រឡូកក្នុងសិល្បៈ

ទាក់ទងទៅនឹងរឿងនេះ អ្នកម្នាងមានប្រសាសន៍រំឮកថា កាលនោះ នៅពេលចូល

រៀនដំបូង ដោយសារមានសម្លេងពិរោះ លោកគ្រូ **ហ៊ាញ** នាយកសាលា និងលោកគ្រូ **ម៉ែត** នាយករងនិងជាគ្រូបង្រៀន តែងតែឱ្យអ្នកម្នាងជាអ្នកផ្តើមច្រៀងបទ"**នគររាជ**" ( ***សូមពួកទេព្តា រក្សាមហាក្សត្រយើងឱ្យបានរុងរឿង.....*** ) ជានិច្ច ពេលដល់ម៉ោងគោរពទង់ជាតិម្តងៗ រួចហើយទើបសិស្សដទៃទៀតច្រៀងបន្តតាមក្រោយរហូតដល់ចប់ ប៉ុន្តែពេលនោះ អ្នកម្នាងមិនបានចាប់អារម្មណ៍ថា សម្លេងរបស់ខ្លួនពិរោះឡើយ គឺឱ្យតែគេឱ្យច្រៀង ដឹងតែច្រៀងប៉ុណ្ណោះ ប៉ុន្តែប្រហែលដោយសារតែរឿងនេះឯងដែលជាដើមហេតុនាំឱ្យអ្នកម្នាងបានឈានចូលមកប្រឡូកក្នុងសិល្បៈតន្ត្រី ។ត្រង់ចំណុចនេះ អ្នកម្នាងមានប្រសាសន៍ថា លុះមកដល់អំឡុងឆ្នាំ **១៩៥៣** ខណៈពេលអ្នកម្នាងទើបមានអាយុ ៨ ឆ្នាំនៅឡើយ លោក **សូ ឌិន** ជាឪពុក ក៏បានយកអ្នកម្នាងឱ្យចូលហាត់ច្រៀងនៅក្នុងវង់ភ្លេងមួយឈ្មោះ"**វង់ភ្លេងរាជសីហ៍តន្ត្រី**"ដែលមានលោក **យ៉ាន់ ភាយ៉ុន** ជាប្រធានវង់ភ្លេង ។ សូមបញ្ជាក់ថា លោក **យ៉ាន់ ភាយ៉ុន** ក៏ជាអ្នកនិពន្ធបទចម្រៀងជើងចាស់មួយរូបតាំងពីជំនាន់លោក **ពៅ ស៊ីផូ** និងលោក **ភួង បុប្ផា** ដែរ ។ លោកគឺជាម្ចាស់ទំនុកច្រៀងនៃបទ"**ឫទ្ធិសក្ខលាស្រុកកំណើត**"ច្រៀងដោយលោក**ស៊ីន ស៊ីសាមុត** និងបទ "**ធំធ្លាញនាងលក្ខិណា** " ច្រៀងដោយអ្នកស្រី **រស់ សេរីសុទ្ធា** ។ហើយបទទាំងពីរនេះគឺដឹកនាំនិងប្រគុំថតដោយវង់ភ្លេង "**រាជសីហ៍តន្ត្រី**" របស់លោកផ្ទាល់តែម្តងហើយដែលមានលោក **ម៉ោយ ហូ** ជាអ្នកនិពន្ធបទភ្លេង ។ បទទាំងពីរនេះនៅមានរូបរាងរហូតមកដល់សព្វថ្ងៃ ។

វិលមកអ្នកម្នាង**សៀង ឌី** វិញ នៅពេលចូលហាត់ច្រៀងនៅទីនេះក្នុងអំឡុងដើមឆ្នាំ ១៩៥៣ នោះ អ្នកម្នាងចាំបានថា កាលនោះមានអ្នកចម្រៀង៩នាក់ទៀត (ប្រុស ៥ ស្រី ៤) កំពុងហាត់ច្រៀងនិងច្រៀងនៅក្នុងវង់ភ្លេងនេះដែរ គឺមានលោក **ស៊ីន ស៊ីសា**

មុត លោក **ស្មះ ម៉ាត់** លោក **អ៊ុ សន** លោក **ស៊ុន គ្រី** និង លោក **សំកុល** ។ ចំណែកខាងនារីមានអ្នកស្រី **មារតី** អ្នកស្រី **សាវតី** អ្នកស្រី **សុធី** និងអ្នកស្រី **ទេព រំដួល** ។ ដូច្នេះបើសរុបទាំងអ្នកម្នាងដែលទើបចូលហាត់ច្រៀងម្នាក់ថែមទៀត វង់ភ្លេងនេះមានគ្នា១០នាក់ល្មម គឺប្រុស ៥ និងស្រី ៥ ។



អ្នកម្នាងបានរៀបរាប់ខ្លះៗអំពីសិល្បករនិងសិល្បការនីមួយចំនួនក្នុងវង់ភ្លេងនេះថា កាលនោះអ្នកទាំងនោះសុទ្ធតែនៅកម្លោះក្រមុំទាំងអស់គឺទាំងលោក **ស៊ីន ស៊ីសាមុត** លោក **សុះ ម៉ាត់** លោក **អ៊ុំ សន** លោក **ហាស់ សាឡន** និងនាង **សុធី** ។ល។ ដោយឡែកចំពោះនាង**សាវតី** អ្នកម្នាងមានប្រសាសន៍បន្ថែមថា នាងជាកូនកាត់បារាំង ច្រៀងភាសាខ្មែរមិនសូវច្បាស់ទេ ប៉ុន្តែនាងច្រៀងពិរោះណាស់ ។ ហើយគឺនាង **សាវតី** ហ្នឹងឯងដែលជាម្ចាស់បទ "**នៅក្នុងលោកិយ**" "**សំបុត្រក្រោមខ្នើយ**" ដ៏ល្បីល្បាញនោះ និងបទ"**មេឃមីរស្រទុំ...**"( មិនមែនដូចបទរបស់អ្នកស្រី **ម៉ៅ សារ៉េត** និងអ្នកស្រី **ឈួន ម៉ាល័យ** ទេ) ។ អ្នកម្នាងបានរៀបរាប់ឱ្យដឹងបន្តទៀតថា នៅក្នុងវង់ភ្លេង "**រាជសីហ៍តន្ត្រី**"នោះមានតន្ត្រីករច្រើន គឺប្រហែល ២២នាក់ ដូចជាលោក **ពៅ ស៊ីផូ** ខាងវីវ៉ូឡុងដែក លោក **ត្នូច បុប្ផា** ផ្លុំសាក់សូ លោក **ហាស់ សាឡន** កូតវីយូឡុង ប៉ុន្តែកវីនិពន្ធ តន្ត្រីករ និងអ្នកចម្រៀងទាំងនេះ មិនមែនប្រកបអាជីពតែសិល្បៈមួយមុខនេះទេ អ្នកទាំងនោះសុទ្ធតែមានការងារនៅក្នុងជួរមន្ត្រីរាជការស្ទើរតែទាំងអស់ ដូចជាលោក **ពៅ ស៊ីផូ** ជានាយប៉ូលីស លោក **ត្នូច បុប្ផា** និងលោក **ស៊ីនគ្រី** ធ្វើគយ លោក **ហាស់ សាឡន** ធ្វើគ្រូនៅសាលាភ្លេង លោក **ស៊ីន ស៊ីសាមុត** និងលោក **សុះ ម៉ាត់** ធ្វើជាគ្រូពេទ្យនៅក្នុងព្រះបរមរាជវាំង ចំណែកលោក **អ៊ុំ សន** និងអ្នកស្រី **សុធី** ធ្វើគ្រូបង្រៀននៅកំពង់កន្ទួត ខេត្តកណ្តាល ។ រីឯអ្នកម្នាង ពេលនោះនៅក្មេងជាងគេបង្អស់ ។

លុះក្រោយពេលរៀនចេះច្រៀងល្អគួរសមហើយ អ្នកម្នាងតែងចេញច្រៀងតាមវង់អកកេះ"**រាជសីហ៍តន្ត្រី**"ជាញឹកញាប់ជាមួយលោក **ស៊ីន ស៊ីសាមុត** និងអ្នកចម្រៀងផ្សេងៗទៀត ។ជួនកាលច្រៀងនៅមុខរោងដំរី( ក្នុងវាំង) នៅមុខអគាររដ្ឋសភាចាស់កែងជ្រុងខាងត្បូងព្រះបរមរាជវាំងសព្វថ្ងៃ ។ គឺចេញច្រៀងមួយអាទិត្យម្តង ឬមួយខែម្តងឱ្យ

ប្រជាពលរដ្ឋនៃជំនាន់សង្គមរាស្ត្រនិយមទស្សនាកំសាន្ត ។ រីឯលោក **ស៊ីន ស៊ីសាមុត** តែងតែជួយបង្ហាត់ច្រៀងយ៉ាងយកចិត្តទុកដាក់ណាស់ ។



ទាក់ទងទៅនឹងការរៀនច្រៀងជាមួយលោក **ស៊ីន ស៊ីសាមុត** នេះ អ្នកម្នាងមានប្រសាសន៍ថា កាលនោះក្រៅពីរៀនចំណេះទូទៅនៅឯសាលារដ្ឋ និង រៀនច្រៀងនៅវង់ភ្លេង"**រាជសីហ៍តន្ត្រី**"របស់លោក **យ៉ាន់ ភាយ៉ុន** នៅរៀងរាល់ល្ងាចពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលចេញពីសាលា អ្នកម្នាងតែងតែទៅរៀនច្រៀងនៅផ្ទះលោក **ស៊ីន ស៊ីសាមុត** ជានិច្ចដែលពេលនោះផ្ទះគាត់នៅក្នុងបឹងម៉ុរិត្តកោះបច្ចុប្បន្ន ។ ហើយកាលនោះមានមិត្តភក្តិរបស់អ្នកម្នាងម្នាក់ទៀតឈ្មោះ **ម៉ុំ ប៊ុនធី** ក៏តែងតែងទៅជាមួយអ្នកម្នាងផងដែរ ប៉ុន្តែមិនមែនទៅរៀនច្រៀងដូចអ្នកម្នាងទេគឺគ្រាន់តែទៅជាគ្នាព្រោះក្មេងៗចូលចិត្តដើរទៅណាមកណាជាមួយគ្នាប៉ុណ្ណោះ ។ទាក់ទងនឹងរឿងនេះដែរ អ្នកម្នាងរំឭកឡើងវិញហាក់អស់សំណើចថា ពេលទៅរៀនច្រៀងនៅផ្ទះលោក **ស៊ីន ស៊ីសាមុត**ដែលស្ថិតនៅលើទឹកក្នុងបឹងម៉ុរិត្តកោះនោះ ជួនកាលអ្នកម្នាងនិងមិត្តភក្តិឈ្មោះ **ម៉ុំ ប៊ុនធី** នោះដើរធ្លាក់ទឹកក៏មានព្រោះពីមាត់បឹងទៅដល់ផ្ទះលោក **ស៊ីន ស៊ីសាមុត** ត្រូវដើរលើស្ពានឬស្សីដែលគេធ្វើសំរាប់ឆ្លងទៅមក។ លុះឃើញអ្នកម្នាងឬមិត្តភក្តិអ្នកម្នាងធ្លាក់ទឹកនោះលោក **ស៊ីន ស៊ីសាមុត** ក៏ប្រញាប់រត់ចេញពីផ្ទះមកស្រង់ ហើយច្រៀងបន្លប់ដើម្បីកុំឱ្យអ្នកម្នាងនិងមិត្តភក្តិដែលនៅក្មេងៗភ័យថា "***មីនាងធ្លាក់ទឹកៗៗ...***" ។ ដោយឡែកអ្នកស្រី **ម៉ុំ ប៊ុនធី** មិត្តភក្តិអ្នកម្នាងបច្ចុប្បន្ននៅមានជីវិតនៅឡើយដែរ សព្វថ្ងៃកំពុងបំរើការងារជាគ្រូពេទ្យនៅសណ្ឋាគារ **កាំប៊ូឌីយ៉ាណា** (Cambodiana) ។

## ~ក្លាយជាអ្នកចម្រៀងជ័យលាភី

ក្រោយមក ប្រទេសកម្ពុជាយើងទទួលឯករាជ្យពីបារាំងនៅឆ្នាំ **១៩៥៣** ។លុះមកដល់ឆ្នាំ **១៩៥៥** គេបានបង្កើតពិធី "**ពិពណ៌អន្តរជាតិ**" មួយព្រមទាំងមានពិធីប្រលងចម្រៀងផង ។ ពេលនោះខាងវង់ភ្លេង"**រាជសីហ៍តន្ត្រី**"បានឱ្យអ្នកម្នាងនិងអ្នកចម្រៀង

មួយចំនួនទៀតក្នុងវង់ភ្លេងនេះទៅចូលរួមប្រលង រួមមានដូចជាលោក**ស៊ីន ស៊ីសាមុត** លោក **ស៊ុះ ម៉ាត់** លោក **អ៊ុំ សន** នាង **ឌេព រំដួល** និងនាង **សុធី** ជាដើម ។ ពេលនោះមុនពេលចូលប្រលង លោក **ស៊ីន ស៊ីសាមុត** បានបង្ហាត់អ្នកម្នាងឱ្យច្រៀង២បទ គឺ១បទទោល និង ១បទច្រៀងឆ្លងឆ្លើយសំរាប់ច្រៀងក្នុងពិធីប្រលងនោះ ។ ហើយបទឆ្លងឆ្លើយនោះ គឺច្រៀងជាមួយលោក **ស៊ីន ស៊ីសាមុត** តែម្តង ។ អ្នកម្នាងរៀបរាប់បន្តថា កាលនោះដោយអ្នកម្នាងនៅក្មេងនិងកំពស់តូចទាបនោះ ពេលឡើងប្រលង គេបានធ្វើកូនតុមួយឱ្យឈរពីលើដើម្បីឱ្យមានកំពស់ស្មើគេ ។ ចំណែកមេប្រយោគត្រួតពិនិត្យនិងផ្តល់ពិន្ទុនៅក្នុងពិធីប្រលងនោះមានទាំងខ្មែរនិងបរទេស ដោយក្នុងនោះក៏មានលោក **ហែម ចំរើន**ដែលជាមន្ត្រីមានឋានៈធំម្នាក់នៅជំនាន់នោះផង ។ហើយគេពិនិត្យល្អិតល្អន់ណាស់គឺតាំងពីការស្លៀកពាក់ ទឹកមុខ ការលើកដាក់សម្លេង និងកាយវិការជាដើម ។

វាគឺជារឿងមួយដ៏អស្ចារ្យនិងគួរឱ្យកោតសរសើរណាស់ចំពោះអ្នកម្នាង **សៀង ឌី** ព្រោះរយៈពេលនៃការប្រលងនោះបានកន្លងផុតជាងកន្លះស.វទៅហើយ បើគិតតាំងពីឆ្នាំ **១៩៥៥** ដល់ឆ្នាំ **២០១១** នេះមានរយៈពេល **៥៦** ឆ្នាំហើយ ក៏ប៉ុន្តែអ្នកម្នាងនៅចងចាំចំណងជើងបទចម្រៀង និង ទំនុកបទនោះបានច្បាស់ល្អណាស់ ព្រមទាំងអាចច្រៀងបានទៀតផង ។ បទចម្រៀងទោលដែលអ្នកម្នាងលើកយកទៅប្រលងក្នុងឱកាសនោះមានចំណងជើងថា "**ព្រះចន្ទ្រា**" រីឯចម្រៀងឆ្លងឆ្លើយដែលច្រៀងជាមួយលោក **ស៊ីន ស៊ីសាមុត** មានចំណងជើងថា "**ចន្ទ្រាជាសាក្សី**" ។

ខាងក្រោមនេះ គឺជាទំនុកច្រៀងទាំងស្រុងនៃចម្រៀងទាំងពីរបទដែលអ្នកម្នាងនិងលោក **ស៊ីន ស៊ីសាមុត** ច្រៀងក្នុងពិធីប្រលងនៅអំឡុងឆ្នាំ **១៩៥៥** ហើយដែលអ្នកម្នាងនៅចងចាំរហូតមកដល់សព្វថ្ងៃ ។

# ព្រះចន្ទ្រា

| | |
|---|---|
| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
| ស៊ីន ស៊ីសាមុត | សៀង ឌី |

I. ឱ ! ព្រះចន្ទ្រាទេទាបមក ឱ្យខ្ញុំឈោងបេះយកៗដាក់លើឱរា

ចន្ទ័អើយៗចន្ទ័ ម្ដេចបានមកជាគ្នា ខ្ញុំស្រែកយំយ៉ាងណា

ចន្ទ្រាគ្មានភ្ជាបែរមក ។

II. ខ្ពស់អើយៗខ្ពស់ ហួសនិស្ស័យ ចន្ទក្រលេកមើលដី

ដីជាឋានមនុស្សលោក គ្នាគ្មានអ្វីទេ មានតែចិត្តស្នេហ៍សោយសោក

ចន្ទ័អើយចន្ទ័ទន់ទាបមក ដៃខ្ញុំចាំត្រកងចន្ទ័ ។

R. ធ្វើបាបធ្វើកម្មឱ្យខ្ញុំទុក្ខព្រួយ តិចមានថ្ងៃមួយទុក្ខព្រួយរញ្ជួយដល់ប្រាណ

ផលបុណ្យចន្ទ័ផុត ច្យុតិចាកមកដល់ទីឋាន ទុកចិត្តមិនដែលបាន

ចន្ទ័មិនអាណិតទឹកភ្នែក ។

III. ..........................................................................

..........................................................................។

# ចន្ទ្រាជាសាក្សី

| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
| --- | --- |
| ស៊ីន ស៊ីសាមុត | ស៊ីន ស៊ីសាមុត~សៀង ឌី |

I. (ប) រាត្រីនេះហើយស្រីនឹងឃ្លាតឃ្លា

(ស) ឱ ! ប្រុសពុំងាអូនសូមលាប្រុសបងហើយ

(ប) ឱ ! ព្រលឹងបងខានបានឃើញត្រាណត្រើយ ចិត្តអើយថ្លើមអើយ

សែនស្តាយ សំដីរវើយដូចខ្យល់ផាត់ ។

(ស) លាហើយណារាត្រីស្ងាត់ ឱ ! វាយោផាត់ត្រជាក់អ្វីម្លេះទេ

(ប) ដូចជាពាក្យមាសមេ ដែលស្រីស្នេហ៍នាងបានស្រដី ។

R. (ស) ឱ ! ព្រះចន្ទ្រាអើយ (ប) សូមជួយធ្វើសាក្សី រវាងសេចក្តីស្នេហា

(ស) ឱ្យខ្ញុំផង (ប) ដូចចិត្តបំណងប្រាថ្នា (២ដង)

(រួម) ក្តីខ្ញុំសូមផ្សងសច្ចា លុះ...ត្រាតែជីវិតក្ស័យ ។

ចំណែករឿងដ៏គួរឱ្យសរសើរមួយទៀតដល់អ្នកម្នាង គឺអ្នកចម្រៀងដែលបានជាប់ចំណាត់ថ្នាក់នៅក្នុងពិធីប្រលងក្នុងឆ្នាំ**១៩៥៥**នោះក៏អ្នកម្នាងនៅចងចាំបានច្រើនផងដែរ ហើយនៅពេលរំឭកដល់ព្រឹត្តិការណ៍នេះ ក៏ធ្វើឱ្យអ្នកម្នាងមានមោទនភាពជាទីបំផុតផងដែរ ។ អ្នកម្នាងមានប្រសាសន៍ថា វាហាក់ដូចជារឿងមួយដែលមិនគួរឱ្យជឿសោះព្រោះអ្នកម្នាងនៅជាកុមារីអាយុទើប១០ឆ្នាំនៅឡើយ ចំណែកអ្នកចម្រៀងក្រៅពីនេះសុទ្ធតែមានវ័យច្រើនជាងអ្នកម្នាងច្រើនណាស់ ហើយពួកគេក៏មានបទពិសោធន៍ច្រើនជាងអ្នកម្នាងផងដែរ ប៉ុន្តែនៅពេលដែលពួគណៈកម្មការប្រកាសលទ្ធផលធ្វើឱ្យអ្នកម្នាង និងអ្នកចូលរួមទស្សនាទាំងប៉ុន្មានមានការភ្ញាក់ផ្អើលគ្រប់ៗគ្នា ។ ទី១គឺភ្ញាក់ផ្អើលចំពោះបេក្ខនារីដែលពេលនោះ គេបានប្រកាសថា កុមារី **សៀង ឌី** ជាប់លេខ **១** ។ គ្រាន់តែប្រកាសចប់ មនុស្សម្នាទាំងឡាយក៏ស្រែកហោកញ្រៀវទះដៃកងរំពងរីឯតន្ត្រីករនិងអ្នកចម្រៀងក្នុងវង់ភ្លេង"**រាជសីហ៍តន្ត្រី**"លើកបោះអ្នកម្នាងយ៉ាងរំភើបរីករាយគ្រប់ៗគ្នា ។ បន្ទាប់មក បេក្ខនារីលេខ **២** បានទៅនាង **ឆេព រំដួល** ចំណែកនាង **សុធី** ជាប់លេខ **៣** ។ រីឯរឿងភ្ញាក់ផ្អើលមួយទៀតគឺនៅពេលដែលមេប្រយោគប្រកាសលទ្ធផលជ័យលាភីខាងប្រុស ។ បាទ ! មុននឹងនិយាយដល់ចំណុចនេះ មិត្តអ្នកអានប្រហែលជាគិតទុកជាមុនដូចៗគ្នាហើយថា គឺច្បាស់ជាលោក **ស៊ីន ស៊ីសាមុត** មិនខាន ។ ប៉ុន្តែការពិតមិនមែនដូច្នេះឡើយ គឺបេក្ខបុរសលេខ **១** បានទៅលោក **ឆេង អ៊ិន** ចំណែកលោក **ស៊ីន ស៊ីសាមុត** ជាប់លេខ **២** លោក **សុះ ម៉ាត់** លេខ **៣** លោក **អ៊ុំ សន** លេខ **៤** និងលេខ ៥ អ្នកម្នាងភ្លេចឈ្មោះទៅហើយ ។ ត្រង់ចំណុចនេះ មិត្តអ្នកអានពិតជាភ្ញាក់ផ្អើលនិងប្រហែលកំពុងតែងឿងឆ្ងល់ហើយថា ហេតុអ្វីបានលោក **ស៊ីន ស៊ីសាមុត** បែរជាធ្លាក់ដល់ចំណាត់ថ្នាក់លេខ២ទៅវិញ ?

បាទ ! ចំពោះមូលហេតុដែលលោក **ស៊ីន ស៊ីសាមុត** ធ្លាក់ទៅលេខ **២** នោះ អ្នកម្ដាងមានប្រសាសន៍ថា មិនមែនដោយសារសម្លេងទេ គាត់ច្រៀងពិរោះណាស់ ប៉ុន្តែធ្លាក់ដោយសារតែគាត់គ្មានកាយវិការ គឺពេលគាត់ច្រៀង គាត់ឈរស្ងៀមថ្ងឹងដូចគោរពទង់ជាតិ ឬដូចគល់ឈើ ។ ហេតុនេះទើបគាត់ធ្លាក់មកដល់លេខ ២ ។ រីឯលោក **ឆេង អ៊ីន** ដែលជាប់លេខ **១** សម្លេងមិនដល់លោក **ស៊ីន ស៊ីសាមុត** ទេ ប៉ុន្តែគាត់បានកាយវិការទាំងអស់ ប៉ុន្តែពេលជាប់លេខ **១** ហើយ លោក**ឆេង អ៊ីន**មិនបានចូលប្រឡូកក្នុងសិល្បៈទេ គឺគាត់បានទៅសិក្សានិងរស់នៅឯបរទេសបាត់ទៅ ។ ដោយឡែកក្រៅពីការប្រលងចម្រៀង ក៏មានការប្រលងបវរកញ្ញា និងបង្ហាញម៉ូដផងដែរ ។ ហើយនារីៗដែលចូលរួមប្រលងបវរកញ្ញាសុទ្ធតែមានរូបសម្រស់ស្អាតៗ និងភាគច្រើនជាកូនអ្នកធំ ។ ចំពោះបេក្ខនារីដែលប្រលងជាប់លេខ**១**ផ្នែកបវរកញ្ញានៅឆ្នាំនោះ អ្នកម្ដាងចាំថា ឈ្មោះនាង **ទេព ភាន់ណារី** ជាកូនអ្នកនៅម្ដុំជ្រោយចង្វារ បច្ចុប្បន្ននៅមានជីវិតនៅឡើយទេគឺកំពុងរស់នៅរដ្ឋ កាលីហ្វ័រញ៉ា (California) សហរដ្ឋអាមេរិច ។ ដោយឡែក ក្រៅពីអ្នកម្ដាងប្រលងជាប់លេខ ១ គឺខាងវង់ភ្លេង " **រាជសីហ៍តន្ត្រី** " ក៏បានជាប់លេខ១ផងដែរព្រោះដូចអ្នកម្ដាងបញ្ជាក់មកខាងលើហើយថា ពិធីនោះគេមិនត្រឹមតែប្រលងអ្នកចម្រៀងទេ គឺគេប្រលងទាំងវង់ភ្លេងផងដែរ គឺបើវង់ភ្លេងណាប្រគុំលេងបានល្អនឹងបានទទួលរង្វាន់ ។

ចំពោះអ្នកម្ដាងវិញ ក្រោយពេលប្រលងជាប់ចំណាត់ថ្នាក់លេខ ១ ដោយបានទទួល "**មេដាយមាស**" នៅក្នុងឆ្នាំ **១៩៥៥** នោះ អ្នកភ្លេងនិងអ្នកចម្រៀងប្រុសស្រីនៅក្នុងវង់ភ្លេង "**រាជសីហ៍តន្ត្រី**" ស្រលាញ់ចូលចិត្តគ្រប់ៗគ្នា ។

ជាមួយគ្នានោះដែរ ក្រោយពេលប្រលងជាប់លេខ **១** នោះ អ្នកម្ដាងតែងបានចេញច្រៀងជាហូរហែរទាំងការប្រគុំតន្ត្រីធម្មតា និងចេញច្រៀងក្នុងពិធីផ្សេងៗដង្ហែសម្ដេចឪ

គ្រប់ស្រុកភូមិឃុំខេត្ត គឺក្នុងឱកាសដែលព្រះអង្គយាងចុះទៅសម្ពោធសមិទ្ធិផលនានាក្នុងជំនាន់ **សង្គមរាស្ត្រនិយម** ព្រមទាំងដង្ហែតាមទ្រង់ទៅច្រៀងនៅបរទេសទៀតផង។




**អ្នកស្រី ទេព កាន់ណារី ដែលប្រលងជាប់បវរកញ្ញាលេខ ១ នៅឆ្នាំ ១៩៥៥**

## -ការឈានចូលក្នុងវង់ភ្លេង"យោធាភិរម្យ"

អ្នកម្នាងចាំបានថា នៅអំឡុងដើមឆ្នាំ ១៩៦០ អ្នកម្នាងបានដង្ហែព្រះករុណាទៅប្រទេសចិនជាលើកដំបូងជាមួយលោក **ស៊ីន ស៊ីសាមុត** ហើយក្រោយមកទៅប្រទេសបារាំង ទៅឥណ្ឌូនេស៊ី កូរ៉េ និង ប្រទេសផ្សេងៗជាច្រើនទៀត ។ ក្រោយមក អ្នកម្នាងក៏ចាប់ផ្តើមច្រៀងថតថាសដំបូងបន្ទាប់បានប្រឡូកសិល្បៈជាច្រើនឆ្នាំ ។ ប៉ុន្តែគួរបញ្ជាក់ថា នៅក្នុងអំឡុងឆ្នាំ **១៩៥៨** ខាងក្រុមវង់ភ្លេងទាហានឈ្មោះ "**យោធាភិរម្យ**" ដែលជាវង់ភ្លេងដ៏ល្បីល្បាញដាច់គេប្រចាំស្រុកខ្មែរកាលជំនាន់នោះបានមកទាក់ទងឱ្យចូលច្រៀងជាមួយពួកគេដែរ ប៉ុន្តែអ្នកម្នាងមិនទាន់ចូលទេ ព្រោះគិតថាខ្លួននៅក្មេងពេក ព្រោះទើបមានវ័យ ១៣ ឆ្នាំប៉ុណ្ណោះ តែទោះយ៉ាងណា ខាងវង់ភ្លេង"**យោធាភិរម្យ**" បានកក់អ្នកម្នាងទុកជាស្រេចដោយរង់ចាំឱ្យអ្នកម្នាងមានវ័យច្រើនជាងនេះបន្តិចដើម្បីចូលច្រៀងជាមួយពួកគេនៅថ្ងៃក្រោយហើយពេលនោះគេបានកំណត់ប្រាក់ខែឱ្យដឹងជាមុនទៀតផង ។ លុះក្រោយមក នៅអំឡុងដើមទ.វឆ្នាំ **១៩៦០** ទើបអ្នកម្នាងចេញពីវង់ភ្លេង"**រាជសីហ៍តន្ត្រី**" របស់លោក **យ៉ាន់ ភាយ៉ុន** ហើយចូលច្រៀងនៅក្នុងវង់ភ្លេង "**យោធាភិរម្យ**" អ្នកម្នាងរៀបរាប់ទៀតថា ពេលនោះវង់ភ្លេង "**យោធាភិរម្យ**" មានអ្នកចម្រៀងល្បីៗ ដែលជារៀមច្បងអ្នកម្នាងដូចជា អ្នកស្រី **ម៉ៅ សារ៉េត** និងអ្នកស្រី **ឈួន ម៉ាឡៃ** ជាដើម ។រីឯអ្នកចម្រៀងប្រុសមានលោក **សម សាខន** (ក្រោយមកក្លាយជាស្វាមីអ្នកស្រី **ម៉ៅ សារ៉េត**) លោក **លីវ តឹក** លោក **តូច តេង** និងលោក **មាស សាម៉ន** ។ ចំណែកអ្នកភ្លេងនិងអ្នកនិពន្ធល្បីៗមានលោក **កែវ ឯម** ក្រោយមកក្លាយជាស្វាមីអ្នកស្រី **សូ សាវឿន** លោក **ម៉ោយ ហូ** និងលោក **ញៀម ផុន** ហៅ **ភុក** ...។

ដោយបានចូលមកច្រៀងក្នុងវង់ភ្លេង"**យោធាភិរម្យ**"នេះ អ្នកម្នាងបានច្រៀងថត

ថាសជាលើកដំបូងនៅអំឡុងឆ្នាំ **១៩៦២** នោះ ។ ប៉ុន្តែមុននេះអ្នកម្នាងក៏បានច្រៀងថត ជាច្រើនដែរសំរាប់ផ្សាយតាមវិទ្យុជាតិ ។ ចំណែកចម្រៀងដែលថតថាសដំបូងនោះ ភាគច្រើនជាចង្វាក់រាំវង់និងជាចម្រៀងប្រជាប្រិយដែលអ្នកភ្លេងនិងអ្នកនិពន្ធជំនាន់នោះយក មករៀបសម្រួលបញ្ចេញបញ្ចូលពាក្យពេចន៍ និងបទភ្លេងខ្លះៗដើម្បីថតចេញជាចម្រៀង ផ្លូវការ ដែលក្នុងនោះរួមមានបទ "**ឱ! ផ្កាយលើមេឃ**" "**លើកដៃឡើងរាំ**" "**ឱ! ស្វាយចន្ទី**"និងបទ"**ចន្ទ័រះពេញ**" ។ល។ និង ។ល។ ហើយចំពោះការថតចម្រៀងទាំងនេះ ជូនកាលគេអញ្ជើញលោក **ហាស់ សាឡន** និងជូនកាលគេអញ្ជើញលោក **មែរ ប៊ុន** មកសម្រួលតន្ត្រីនិងដឹកនាំភ្លេងប្រគុំ ។ ដោយឡែកថាសជំនាន់ដំបូងនោះគេនិយមប្រើថាសលេខ **៣៣** តួ រីឯក្រុមហ៊ុនថតថាសនៅដើមទ.វ ឆ្នាំ **១៩៦០** នោះក៏មិនទាន់មានច្រើនដែរគឺមានតែក្រុមហ៊ុនថតថាស **ចន្ទ័ឆាយា** និងក្រុមហ៊ុនថតថាស**ភាពីតូល** ប៉ុណ្ណោះ ។ ចំណែកអ្នកចម្រៀងល្បីៗដែលគេអញ្ជើញមកច្រៀងថតដាក់ថាសមានលោក **ស៊ីន ស៊ីសាមុត** លោក **ស៊ុះ ម៉ាត់** អ្នកស្រី **ម៉ៅ សារ៉េត** និងអ្នកស្រី **ឈួន ម៉ាឡៃ** ។ល។ រីឯអ្នកចម្រៀងក្រៅពីនេះដូចជាលោក **អ៊ុំ សន** លោក **ស៊ុនគ្រី** អ្នកស្រី **សាវតី** និងអ្នកស្រី **សុធី** ជាដើម មិនបានថតថាសច្រើនទេគឺបានតែថតផ្សាយតាមវិទ្យុជាតិប៉ុណ្ណោះព្រោះរវល់ធ្វើគ្រូនៅឆ្ងាយៗ យូរៗម្តងគឺពេលវិស្សមកាលទើបបានថតដាក់ថាសនឹងគេ ។ហេតុនេះទើបយើងឃើញថាអ្នកចម្រៀងរៀមច្បងទាំងនេះមិនបានបន្សល់ទុកបទចម្រៀងច្រើននឹងគេទេ ។

ពេលបានថតថាសលក់តាមទីផ្សារនិងច្រៀងផ្សាយវិទ្យុជាតិ កេរ្តិ៍ឈ្មោះអ្នកម្នាងចេះតែល្បីឡើងជាបន្តបន្ទាប់ ហើយការថតចម្រៀងក៏ចេះតែមកញឹកជាងមុនដែរ ។

ដោយឡែកនៅក្នុងវង់ភ្លេង"**យោធាភិរម្យ**" មានអ្នកភ្លេងច្រើនណាស់ ហើយសុទ្ធ

សឹងជាអ្នកមានថ្វីដៃខ្ពស់ គឺសុទ្ធតែចេញពីសាលាភ្លេង ។ តាមអ្នកម្នាងចាំ តន្ត្រីករក្នុងវង់ភ្លេងដ៏ល្បីល្បាញនេះមាន ២២ ទៅ ២៥ នាក់ ។ ចំពោះចម្រៀងដែលអ្នកម្នាងបានច្រៀង ហើយដែលមានវង់ភ្លេង"**យោធាភិរម្យ**"នេះជាអ្នកប្រគុំរួមមានដូចជាបទ "**ក្រមុំកែប ឱសថទិព្វ**" "**សម្រស់ខេត្តមណ្ឌលគិរី**" "**ខ្លួនខ្ញុំបួកគោ**" "**សួនកំសត់**" "**សម្រស់ស្រុកស្រែអំបិល**" និងបទ "**ទឹកភ្នែកមុនថ្ងៃលិច**" ...ជាដើម ។ល ។

# ថាសចម្រៀងជំនាន់ដើមរបស់អ្នកម្នាង



## ថាសចម្រៀងបទ

# “សង្ឃឹមថាបានជាគូ” និងបទ“អរុណរះ”

## និពន្ធដោយលោក វ៉ោយ ហូ និងលោក មែរ ប៊ុន



# ថាសចម្រៀងបទ

# “គូស្នេហ៍និរាស” ច្រៀងដោយអ្នកម្នាង សៀង ឌី និងបទ “ស្រណោះទន្លេសូឡូ” ច្រៀងដោយអ្នកស្រី ឈួន ម៉ាឡៃ



ស្រោមថាសបទ"**ចន្ទូរះលំអង**" (ហួយ មាស) និងបទ"**ប្រចណ្ឌ**"

ច្រៀងដោយអ្នកម្នាង **សៀង ឌី**






នៅឆ្នាំ **១៩៦៤** បន្ទាប់ពីទៅប្រទេសចិន អ្នកម្នាងត្រូវព្រះករុណាសម្តេចឪបានព្រះរាជទានឱ្យទៅប្រទេសបារាំងទៀតដើម្បីច្រៀងបង្ហាញបរទេសឱ្យស្គាល់នូវតន្ត្រី និងរបាំខ្មែរដូចជាល្ខោនព្រះរាជទ្រព្យនិងចម្រៀងមហោរីជាដើម ។ក្រៅពីអ្នកម្នាង អ្នកចម្រៀងដែលបានទៅជាមួយអ្នកម្នាងមានគ្នា ៤នាក់មាន **ស៊ីន ស៊ីសាមុត** លោក **សុះ ម៉ាត់** និងអ្នកស្រី **ម៉ៅ សារ៉េត** ។ ហើយដោយសារបានទៅប្រទេសបារាំងនៅឆ្នាំនោះហើយដែលពេលនោះក្រោយពេលត្រលប់មកវិញអ្នកស្រី **ម៉ៅ សារ៉េត** ឱ្យលោក **ម៉ា ឡៅពី** បាននិពន្ធបទ"**រាត្រីនៅស្វមៀ**" និងបទ "**នាវាម៉េហ្សង់អង**" ឱ្យអ្នកស្រី **ម៉ៅ សារ៉េត** ច្រៀង ។ ជាពិសេសលោក **ស៊ីន ស៊ីសាមុត** ក៏បាននិពន្ធចម្រៀងច្រើនរៀបរាប់ពីអានុស្សាវរីយ៍នៅប្រទេសបារាំងនេះដូចជាបទ"**អង់តូនីញ៉ែតា**""**ម៉ារីណា**""**វីយ៉ូឡែតា**"និងបទ"**លាហើយបារីស**"ជាដើម ។

ចំពោះចម្រៀងដែលអ្នកម្នាងច្រៀង មានបទខ្លះខាងក្រុមហ៊ុនថតថាសហៅទៅថតផ្ទាល់តែម្តង ហើយបទខ្លះអ្នកម្នាងច្រៀងផ្សាយតាមវិទ្យុ ។ លុះពេលផ្សាយទៅ មានអ្នកស្តាប់ចូលចិត្តច្រើន ទើបក្រុមហ៊ុនសុំទិញយកទៅបញ្ចូលក្នុងថាសដើម្បីលក់ ។ត្រង់ចំណុចនេះ ខ្ញុំបាទសូមបញ្ជាក់ឱ្យបងប្អូនជំនាន់នេះដឹងថា ជំនាន់ទ.វឆ្នាំ ១៩៦០នោះ គ្មានម៉ាស៊ីនថតសម្លេងនិងមិនទាន់មានម៉ាញ៉េនៅឡើយទេ គឺមានតែវិទ្យុប៉ុណ្ណោះសំរាប់ស្តាប់ ហើយវិទ្យុក៏មានតែ១ប៉ុស្តិ៍ដែរ គឺវិទ្យុជាតិ ។ ដូច្នេះចម្រៀងដែលគេថតសំរាប់ផ្សាយ គឺយើងអាចស្តាប់បានតែនៅពេលវិទ្យុជាតិផ្សាយប៉ុណ្ណោះ ប្រសិនបើវិទ្យុមិនចាក់ក៏គ្មានបទនោះស្តាប់ដែរ ។ ហេតុនេះដើម្បីយកបទនោះមកចាក់ស្តាប់នៅផ្ទះ ហើយចង់ស្តាប់ពេលណាក៏បាន ទាល់តែយកបទនោះទៅផ្តិតដាក់ថាសសិន រួចទើបយកមកចាក់ស្តាប់បាន ព្រោះជំនាន់នោះយើងមានតែម៉ាស៊ីនចាក់ថាសទេ ។ ហេតុនេះហើយ ក្រុមហ៊ុនថតថាសខ្លះ ពេល

ខ្លះគេហៅអ្នកចម្រៀងទៅថតផ្ទាល់ដើម្បីផ្តិតដាក់ថាសលក់ ចំណែកបទខ្លះគេទិញពីអ្នកចម្រៀង ឬពីអ្នកនិពន្ធដែលច្រៀងផ្សាយតាមវិទ្យុជាតិនោះឯង ។ ហើយពេលយកមកផ្តិតដាក់ថាសនោះ ជួនកាលគេយកបទដែលច្រៀងរួចនោះមកផ្តិតតែម្តងក៏មាន ឬជួនកាលគេឱ្យអ្នកចម្រៀងនោះច្រៀងឡើងវិញក៏មាន ។ ហេតុនេះហើយទើបយើងឃើញថាចម្រៀងខ្លះដែលមានទំនុកច្រៀងនិងបទភ្លេងតែមួយ មានពីរដូចគ្នារហូតមកដល់សព្វថ្ងៃ ។ ដូចជាបទ"**ថ្ងៃ១២កក្កដា**"ច្រៀងដោយលោក **ស៊ីន ស៊ីសាមុត**និងបទ"**ផ្សែងមរណៈ**"ដែលច្រៀងដោយលោក **ស៊ុះ ម៉ាត់** ជាដើម ។ បទទាំងនេះគឺសុទ្ធតែច្រៀងពីរដង ។ ចំណែកបទខ្លះ ពេលច្រៀងដាក់វិទ្យុជាអ្នកចម្រៀងផ្សេង លុះពេលគេផ្តិតដាក់ថាសគេឱ្យអ្នកចម្រៀងម្នាក់ទៀតច្រៀងឡើងវិញក៏មាន ។ ឧទាហរណ៍បទ "**ចិត្តម្ចាស**" "**ព្រាត់ភ្លឺសំពៅ**" "**ក្រឡាហោមគង់**"និងបទ "**កំពង់ចាមកំពង់ចិត្ត**"...បទទាំងនេះពេលច្រៀងផ្សាយតាមវិទ្យុ គឺលោក **ស៊ុះ ម៉ាត់** ជាអ្នកច្រៀងទេ លុះពេលគេយកមកផ្តិតជាថាសលក់ គេសុំទិញសិទ្ធិពីលោក **ស៊ុះ ម៉ាត់** ដែលជាម្ចាស់បទដើម ហើយយកបទទាំងនេះមកឱ្យលោក **ស៊ីន ស៊ីសាមុត** ជាអ្នកច្រៀងវិញ ។ ហើយមូលហេតុដែលគេមិនយកលោក **ស៊ុះ ម៉ាត់** ច្រៀងដាក់ថាស ព្រោះថៅកែក្រុមហ៊ុនគិតថា លោក **ស៊ីន ស៊ីសាមុត** ល្បីជាង **ស៊ុះ ម៉ាត់** ដូច្នេះបទទាំងនោះអាចនឹងលក់ដាច់ច្រើនជាងលោក **ស៊ុះ ម៉ាត់** ច្រៀង ។ ក្រៅពីនេះ រួមមានបទ"**សំណើចចំអកព្រហ្មលិខិត**" ម្ចាស់សំនៀងដើមគឺ លោក **យ៉ង់ ឈឿង** ហៅ **សំនៀងឬទ្ធិ** (ជាអ្នកនិពន្ធផ្ទាល់និងច្រៀងផ្ទាល់ ក្រោយមកលោកលើកថ្វាយទៅ **អ្នកអង្គម្ចាស់ ស៊ីសុវត្ថិកុឡាឆាត**ច្រៀងបន្ត ហើយក្រោយមកប្រគល់ទៅលោក **ជូឡុង បូរ៉ាមី** (កូនប្រុសរបស់សម្តេចចក្រី **ញឹក ជូឡុង**ច្រៀងបន្តទៀត លុះទើបមកដល់ពាក់កណ្តាលទ.វឆ្នាំ១៩៦០ទើបមកដល់លោក

**ស៊ីន ស៊ីសាមុត** ច្រៀងថតថាសជាផ្លូវការ ។ រីឯបទ"**អានី**" ម្ចាស់សំនៀងដើមគឺ **អ្នកអង្គម្ចាស់ ប៉ាណារ៉ា សិរីវុឌ** (ជាអ្នកនិពន្ធផ្ទាល់និងច្រៀងផ្ទាល់) ។ ហេតុនេះទើបយើងឃើញថា បទខ្លះនៅសល់សម្លេងម្ចាស់ដើមរហូតសព្វថ្ងៃ ដូចជាបទ "**អានី**" របស់**អ្នកអង្គម្ចាស់ ប៉ាណារ៉ា សិរីវុឌ** និងបទ"**កំពង់ចាមកំពង់ចិត្ត**"របស់លោក **ស៊ុះ ម៉ាត់** ជាដើម ។

ដោយឡែក ចំពោះអ្នកម្នាង ក្រៅពីច្រៀងប្រចាំវង់ភ្លេង "**យោធាភិរម្យ**" ទទួលប្រាក់ខែពីរដ្ឋនោះ អ្នកម្នាងក៏ច្រៀងនៅរង្គសាលល្បីៗនៅទីក្រុងភ្នំពេញកាលជំនាន់នោះដែរ ដូចជារង្គសាល "Magasin D'etat" ដែលស្ថិតនៅខាងមុខព្រលានយន្តហោះពោធិចិនតុង រង្គសាល **អូឡាំពិក** នៅខាងមុខស្តាតអូឡាំពិក (សព្វថ្ងៃរង្គសាលCityLight) និងរង្គសាលបណ្តែតទឹក "La Lune" នៅទល់មុខផ្សាររាត្រីបច្ចុប្បន្ន ។

**អ្នកម្នាង សៀង ឌី នៅទីក្រុង ឡុងប៊ិច រដ្ឋ កាលីហ្វ័រញ៉ា សហរដ្ឋអាមេរិច ឆ្នាំ ១៩៨៧**



និយាយអំពីបទចម្រៀងដែលអ្នកម្នាងបានច្រៀង ទាំងចាក់ផ្សាយតាមវិទ្យុ និងថតថាសភាគច្រើនជាបទប្រជាប្រិយខ្មែរ និងចម្រៀងមួយចំនួនទៀតត្រូវបាននិពន្ធដោយកវីល្បីៗកាលពីជំនាន់នោះ ដូចជាលោក **ពៅ ស៊ីផូ** លោក **យ៉ង់ ឈៀង** ហៅ **សំនៀងឫទ្ធី** លោក **ម៉ែរ ប៊ុន** លោក **ហាស់ សាឡន** និងលោក **វ៉ោយ ហូ** ...ជាដើម ។

បទប្រជាប្រិយដែលអ្នកម្នាងច្រៀងរួមមានបទ :

០១ -**ឱ ! ស្វាយចន្ទី** ច្រៀងរួមគ្នាដោយលោក **សម សាខន** អ្នកម្នាងនិងអ្នកស្រី **សូ សាវិនណារ៉ា** ដែលជាបងស្រីច្បងរបស់អ្នកម្នាង

០២ -**ឱ ! ផ្កាយលើមេឃ** ច្រៀងម្នាក់ឯង

០៣ -**រាំតាមសិល្បករ** ច្រៀងម្នាក់ឯង

០៤ -**ចន្ទ័រះពេញ** (កុំទោម្ទេញ...) ច្រៀងម្នាក់ឯង

០៥ -**គន់មើលផ្កាយ** ច្រៀងម្នាក់ឯង

០៦ -**រាំវង់ល្ងាចថ្ងៃសៅរ៍** សម សាខុន និងអ្នកម្នាង

០៧ -**លើកដៃឡើងរាំ** សម សាខន-ម៉ៅ សារ៉េត និងអ្នកម្នាង

និងមានចម្រៀងជាច្រើនទៀតប៉ុន្តែបាត់បង់អស់ទៅហើយ ។ ចំណែកចម្រៀងដែលកវីនិពន្ធនានាជំនាន់នោះនិពន្ធឱ្យអ្នកម្នាងច្រៀងរួមមានបទ :

០១ -**ព្រោះតែស្រលាញ់** និពន្ធដោយលោក **យ៉ង់ ឈៀង**

០២ -**ភ្នែកកែវឱសថទិព្វ** និពន្ធដោយលោក **យ៉ង់ ឈៀង**

០៣ -**សួនកំសត់** និពន្ធដោយលោក **យ៉ង់ ឈៀង**

០៤ -**ស្រណោះស្រុកស្រែអំបិល** និពន្ធដោយលោក **យ៉ង់ ឈៀង**

០៥ -**ប្រចណ្ឌ** និពន្ធដោយលោក **យ៉ង់ ឈឿង**

០៦ -**សម្រស់ខេត្តមណ្ឌលគិរី** និពន្ធដោយលោក **វ៉ោយ ហូ**

០៧ -**ទឹកភ្នែកមុនថ្ងៃលិច** និពន្ធដោយលោក **វ៉ោយ ហូ**

០៨ -**ចម្រៀងអស់សង្ឃឹម** និពន្ធដោយលោក **ហាស់ សាឡុន**

០៩ -**នុះហ្ន៎ ! មើលពួកកម្លោះ** និពន្ធដោយលោក **ហាស់ សាឡុន**

១០ -**សំបុត្រជាវិញ្ញាណស្នេហ៍** និពន្ធដោយលោក **ហាស់ សាឡុន**

១១ -**កុលាបអូនស្នេហ៍** និពន្ធដោយលោក **ពៅ ស៊ីផូ**

១២ -**គូស្នេហ៍និរាស** និពន្ធដោយ **ពៅ ស៊ីផូ**

១៣ - **ព្រះសុរិយា** ១៩៦១ និពន្ធដោយលោក **ពៅ ស៊ីផូ**

១៤ -**ដួងចិត្តបុរស** និពន្ធដោយអ្នកម្នាង **ពៅ ស៊ីផូ**

១៥ -**រាំធាន់ខ្លួននៅក្មេង** និពន្ធដោយលោក **ហាស់ សាឡុន**

១៦ -**អរុណរះ** និពន្ធដោយ **វ៉ោយ ហូ~ម៉ែរ ប៊ុន**

១៧ -**សង្ឃឹមថាបានជាគូ** (+ឈួន ម៉ាឡៃ) និពន្ធដោយ **វ៉ោយ ហូ~ម៉ែរ ប៊ុន**

១៨ -**ស្វារាំម៉ុនឃីស** និពន្ធដោយលោក **ម៉ែរ ប៊ុន**

១៩ -**គូស្នេហ៍បាត់សូន្យ** និពន្ធទំនុកច្រៀងដោយអ្នកម្នាងផ្ទាល់

២០ -**រាំធាន់ខ្លួននៅក្មេង** និពន្ធដោយលោក **ម៉ែរ ប៊ុន**

ចំពោះបទ"**ស្វារាំម៉ុនឃីស**"នេះ ក្រោយមកលោក**ហាស់ សាឡុន** យកទៅឱ្យអ្នកស្រី **ម៉ែន រ៉ន** ច្រៀងឡើងវិញហើយនៅមានរូបរាងដល់បច្ចុប្បន្ន ។ រីឯទាក់ទងនឹងបទ "**ព្រោះតែស្រលាញ់**" អ្នកម្នាងរំលឹកឡើងវិញថា បទនេះប្រគុំថតដោយវង់ភ្លេងសុភាគាខ្មែរ SKD ហើយក្រោយមក ដោយឃើញមានអ្នកស្ដាប់ចូលចិត្តច្រើន ក្រុមហ៊ុន

ថតថាស **ចន្ទំឆាយ៉ា** ក៏ទិញយកមកបញ្ចូលថាសលក់រហូតមក ។ក្រោយមកទៀតដោយសារព្វបទនេះពិរោះ អ្នកស្រី **ឌី សាវ៉េត** ម្ចាស់ផលិតកម្ម "**សុវណ្ណគីរីភាពយន្ត**" ក៏មកទាក់ទងទិញបទនេះពីអ្នកម្នាងយកទៅថតជាខ្សែភាពយន្តទៀត ហើយដាក់ចំណងជើងរឿងនោះដូចបទ "**ព្រោះតែស្រលាញ់**" តាមបទចម្រៀងតែម្តង ។ អ្នកម្នាងចាំបានថា កាលនោះបទនេះលក់តម្លៃ **១២០០០** រៀល ហើយប្រាក់ទាំងនេះបែងចែកជាច្រើនចំណែក ដូចជាចែកទៅឱ្យក្រុមតន្ត្រីករ មេភ្លេង អ្នកនិពន្ធ និងអ្នកម្នាង ។ អ្នកម្នាងមានប្រសាសន៍ទៀតថា ប្រាក់ជំនាន់នោះថ្លៃណាស់ ។ អ្នកចម្រៀងធម្មតា ច្រៀងថតថាស ១ បទបាន ៣០០ រៀល ។

**អ្នកម្នាង សៀង ឌី នៅទីក្រុង ប៉ារីស**



ហើយពេលនិយាយអំពីបទ"**ព្រោះតែស្រលាញ់**"នោះក៏ធ្វើឱ្យអ្នកម្នាងនឹកឃើញលោក **យ៉ង់ ឈឿង** ហៅ **សំនៀងឬទ្ធី** ដែលជាអ្នកនិពន្ធបទនេះផងដែរ ។ អ្នកម្នាងរំឭកអានុស្សាវរីយ៍ខ្លះៗជាមួយលោក **យ៉ង់ ឈឿង** ថា បើបទណាដែលគាត់និពន្ធឱ្យច្រៀង គឺគាត់មកបង្ហាត់ផ្ទាល់ ដោយគាត់ច្រៀងឱ្យស្ដាប់ព្រមទាំងសំដែងកាយវិការ និងធ្វើមុខមាត់ឱ្យមើលទៀតផង ព្រោះគាត់ក៏ជាអ្នកចម្រៀងដែរ ។

និយាយពីវង់ភ្លេង"**យោធាតិរម្យ**"វិញ ក្រោយពេលអ្នកម្នាងចូលមកក្នុងវង់ភ្លេងនេះ លោក Jean Fernandes (**ហ្សង់ ហ្វែណង់ដេស**) ដែលកាលនោះជាមេភ្លេង "**យោធាតិរម្យ**"បានកួចលួចប្រតិពទ្ធ័ស្នេហាលើអ្នកម្នាង ក៏ប៉ុន្តែស្នេហានេះមិនបានដល់គោលដៅទេ ។



**អ្នកម្នាង សៀង ឌី នៅប៉ារីស ១៩៧៧**

ហេតុនេះដោយសារស្នេហាមិនដល់ត្រើយដូចចិត្តដែលប៉ង លោក **ហ្សង់ ហ្វែណង់ដេស** ក៏បាននិពន្ធចម្រៀង២បទបង្ហាញពីដួងចិត្តស្និតស្រពោននេះឱ្យអ្នកម្នាងច្រៀងនោះគឺបទ" **សង្ឃឹមចិត្តស្មោះ**" និងបទ "**ចង់តែជួបភក្រ្ត**" ។

បាទ ! ហើយជារឿងមួយអស្ចារ្យណាស់ ថ្វីបើបទនេះថតតាំងពីអំឡុងដើមទ.វឆ្នាំ **១៩៦០** និងបានបាត់រូបរាងទៅហើយក្ដី ប៉ុន្តែអ្នកម្នាងនៅចាំទំនុកច្រៀងបទទាំងនេះយ៉ាងច្បាស់រហូតមកដល់បច្ចុប្បន្ន ។ នេះជាទំនុកបទទាំងពីរដែលអ្នកម្នាង **សៀង ឌី** សរសេរយកមកឱ្យខ្ញុំដើម្បីចុះផ្សាយក្នុងសៀវភៅនេះ ។

# សង្ឃឹមចិត្តស្មោះ

| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
|---|---|
| ហ្សង់ ហ្វៀណាច់ដេស | សៀង ឌី |

I. គ្មានសល់ អ្វីឡើយក្រៅពីអានុស្សា ធម្មជាតិអស់មេត្តា
ប្រាថ្នាមកលើរូបយើង ។

II. ខ្ញុំចាំ ចាំច្បាស់នៅរាត្រីដែលថ្លៃ ប្រាប់រឿងសង្វេគក្រៃ
មានន័យថាយើងព្រាត់គ្នា ។

R. ទោះនៅសែនឆ្ងាយ កុំអាលនឿយណាយពីបណ្ដាំ អូនចាំរាល់គ្រា
បងរៀបឃ្លាតឃ្លា ថាមុកជារកអូនតាមពាក្យសច្ចា ។

III. សង្ឃឹម ចិត្តស្មោះជួយរំដោះទុក្ខា សង្ឃឹមវេលា
សង្ឃឹមស្នេហាវិលវិញ ។

# ចង់តែជួបភក្ត្រ

បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ
ហ្សង់ ហ្វៀណង់ដេស | សៀង ឌី

I. ឆ្ងាយកាន់តែឆ្ងាយ ឆ្ងាយអ្វីម្លេះ ? តើរស់ជាតិនេះគ្រាន់តែជាល្បែង
បញ្ឆោតលលេងវាសនាឬអ្វី ?

II. បង្ខិតបង្ខំបំព្រាត់រូបកាយ ចិន្តាខ្វល់ខ្វាយអភព្វ័ភក្តិ
ចង់តែជួបភក្ត្រ័រួមរក្សមេត្រី លុះថ្ងៃអវសាន្ត ។

R. សុបិនយប់ថ្ងៃ មមៃក្នុងប្រាណ ស្រមៃឃើញប្រុសបងបាន
វិលវិញជាថ្មី ។

III. ស្ដាយអើយសែនស្ដាយ ស្ដាយម្លេះទេ ជីវិតនឹងប្រែបែរជាឥតន័យ
បើមិនបានជួបប្រុសជារស្មី នៃក្ដីស្នេហ៍ខ្ញុំ ។

## -ស្នាដៃខាងភាពយន្ត

ទាក់ទងនឹងភាពយន្ត អ្នកម្នាងរំឭកថា ក្នុងអំឡុងឆ្នាំ **១៩៥៧** គឺក្រោយពេលដែលអ្នកប្រលងជាប់លេខ១ បានពីរឆ្នាំ និង ខណៈពេលអ្នកម្នាងអាយុបាន ១២ លោក **រឿម សុផុន** បានហៅអ្នកម្នាងថតកុនបាន១រឿង ឈ្មោះរឿង "**ត្រង់ស្លូតស្លាប់**" ដោយអ្នកម្នាងសំដែងជាតួឯកជាមួយលោក **កែម ភាណុ** ហើយរឿងនេះត្រូវបានគេដាក់បញ្ចាំងនៅរោងកុន **ភាពីតូល** ។ សូមបញ្ជាក់ថា លោក **រឿម សុផុន** ធ្វើការនៅព្រះបរមរាជវាំងប៉ុន្តែលោកបានទទួលអនិច្ចកម្មទៅហើយក្នុងរបប ប៉ុល ពត រីឯលោក **កែម ភាណុ** ក៏ស្លាប់តាំងពីជំនាន់នោះផងដែរ ។

អ្នកម្នាង សៀង ឌី នៅក្នុងភាពយន្តរបស់សម្ដេចឪ ថតនៅជំនាន់ក្រោយ



ដោយឡែក ក្រៅពីនេះ អ្នកម្នាងក៏មានកត្តិយសដ៏ខ្ពង់ខ្ពស់ច្រៀងនូវចម្រៀងដែល**សម្ដេចឪ ព្រះបិតាឯករាជ្យ ព្រះករុណាព្រះបាទនរោត្តមសីហនុ** និពន្ធផងដែរ ។ មិនតែប៉ុណ្ណោះ អ្នកម្នាងក៏បានចូលរួមសំដែងក្នុងខ្សែភាពយន្តដែលព្រះអង្គដឹកនាំសំដែងផងដែរ ដូចជារឿង "**រស់ដោយសប្បាយ**" ថតឆ្នាំ **១៩៦៨** រឿង "**អប្សរា**" ឆ្នាំ **១៩៦៦** និងរឿង"**ឆាយាលើអង្គរ**" ដែលថតនៅឆ្នាំ **១៩៦៧** ។

នៅក្នុងរឿង "**រស់ដោយសប្បាយ**"(La Joie de Vivre) អ្នកម្នាងសំដែងជាតួឯកពីរនាក់ជាមួយអ្នកស្រី **សាក់ស៊ីស្បោង** ចំណែកតួឯកប្រុសសំដែងដោយលោក **គង់ សំអឿន** សម្តេច ចក្រី **ញឹក ជូឡុង** និងព្រះរាជបុត្រសម្តេចឪឈ្មោះនរោត្តម **យុទនាថ** ។ នៅក្នុងរឿងនេះ អ្នកម្នាងបានច្រៀងបញ្ចូលពីរបទ គឺបទ "**ចម្រៀងអស់សង្ឃឹម**" និងបទមួយទៀតមានចំណងជើងថា "**រាំទាន់ខ្លួននៅក្មេង**" ដែលនិពន្ធដោយ **ហាស់ សាឡន** ប្រគុំជាចង្វាក់ A go go ។

ចំណែកនៅក្នុងរឿង "**អប្សរា**" តួឯកស្រីសំដែងដោយ **សម្តេចព្រះរាម បុប្ផាទេវី** ឯតួឯកប្រុសសំដែងដោយ **សម្តេច ជីវ័ន មុនីរ៉ាក់** ។ ហើយគឺនៅក្នុងរឿង "**អប្សរា**" នេះឯងដែលអ្នកម្នាងច្រៀងបទ "**រាត្រីដែលបានជួបភក្ត្រ័**" និងបទ "**រាត្រីខែត្លឹមភលេងរាំវង់**" ជាមួយលោក **ស៊ីន ស៊ីសាមុត** ដែលជាព្រះរាជនិពន្ធរបស់សម្តេចឪ ។ ហើយរឿងនេះនៅមានសេសសល់រហូតមកដល់បច្ចុប្បន្ន ។ បើសិនមិត្តអ្នកអានចង់ឃើញរូបអ្នកម្នាង **សៀង ឌី** និងរូបលោក **ស៊ីន ស៊ីសាមុត** និងក្រុមភ្លេង "**ព្រះបរមរាជវាំង**" សំដែងលើវេទិកា សូមទៅរករឿង "**អប្សរា**" និងរឿង "**ឆាយាលើអង្គរ**" ទស្សនាចុះ ប្រាកដជាឃើញមិនខាន ។ ចំពោះបទ "**រាត្រីដែលបានជួបភក្ត្រ័**" អ្នកម្នាងមានប្រសាសន៍ថា ពេលព្រះអង្គនិពន្ធរួចភ្លាមក៏ព្រះរាជទានឱ្យលោក **ស៊ីន ស៊ីសាមុត** និងអ្នកម្នាងហាត់ច្រៀងនិងថតភ្លាមនៅក្នុងព្រះរាជដំណាក់ចំការមនពេលនោះតែម្តង ។

សូមបញ្ជាក់ថា **សម្តេចឪ ព្រះបិតាឯករាជ្យជាតិខ្មែរ** ព្រះអង្គមិនត្រឹមតែជាព្រះមហាក្សត្រដ៏ឆ្នើមប៉ុណ្ណោះទេ ព្រះអង្គក៏ជាអ្នកនិពន្ធដ៏មានស្នាព្រះហស្តដ៏ខ្ពស់មួយអង្គផងដែរ គឺទ្រង់ចេះទាំងនិពន្ធបទភ្លេងនិងទំនុកច្រៀង ។ ហើយបទភ្លេងនិងទំនុកច្រៀងរបស់ទ្រង់ មានលក្ខណៈដាច់ស្រឡះពីស្នាដៃកវីនិពន្ធធម្មតាគឺស្តាប់ទៅមានលក្ខណៈបែប

អភិជនជាន់ខ្ពស់ហើយវិសេសវិសាលណាស់ ។ ជាក់ស្តែងដូចជាបទ"**រាត្រីជួបភក្ត្រ័**" នេះ ដែលរហូតមកដល់បច្ចុប្បន្ន គេនិយមលើកយកមកច្រៀងជាហូរហែរនៅក្នុងពិធីកំសាន្ត ដូចជាក្នុងពិធីរៀបមង្គលការជាដើម ។រីឯបទ"**បុប្ផាទៀងចន្ទ័**" "**សកវាធី**" និងបទ "**ភ្នំពេញ**" ក៏សុទ្ធសឹងមានបែបផែនដូច្នេះដែរ ។ រីឯចំពោះភាពយន្តដែលព្រះអង្គដឹកនាំថតនោះវិញ តួអង្គសំដែងភាគច្រើនជាតួអង្គពិតៗតែម្តង មានន័យថាតួជាឯកឧត្តម ជារដ្ឋមន្ត្រី ឬជាមេទ័ព គឺអ្នកនោះមានតួនាទីនិងឋានៈពិតបែបនោះ បូករួមទាំងព្រះអង្គផង គឺព្រះអង្គក៏សំដែងផ្ទាល់ក្នុងរឿងនោះដែរ ។



អ្នកម្នាង សៀង ឌី និងលោក ស៊ីន ស៊ីសាមុត ច្រៀងក្នុងរឿង "អប្សរា"របស់ សម្តេចឪ ថតឆ្នាំ ១៩៦៦ ។រឿងនេះនៅមានរហូត មានសេសសល់រហូតដល់បច្ចុប្បន្ន ។

អ្នកម្នាង **សៀង ឌី**
នៅក្នុងភាពយន្តរឿង
**"រស់ដោយសប្បាយ"**



បាទ ! ចំពោះការលើកឡើងរបស់អ្នកម្នាងថា ចម្រៀងដែលព្រះករុណានិពន្ធពិបាកហាត់នេះពិតជាត្រឹមត្រូវណាស់ ហើយតាមការវិភាគរបស់ខ្ញុំ ក៏យល់ឃើញបែបនេះដែរ ជាក់ស្តែងដូចជាបទ **"បុប្ផាទៀងចន្ទ"** **"ភ្នំពេញ"** **"ឪកែប"** **"ព្រៃប្រសិទ្ធ"** និងបទ **"សករវាតី"** ជាដើម .... យើងឃើញថា ចង្វាក់ភ្លេងនៃបទទាំងនេះ ឡើងចុះ ខ្ពស់ទាប និងលើកដាក់ បត់បែន ច្រើនណាស់ ។ ខ្ញុំចេះតែស្រមៃថា នៅពេលហាត់បទនេះ អ្នកចម្រៀងនានាបូករួមទាំងលោក **ស៊ីន ស៊ីសាមុត** ផង ដែលព្រះអង្គប្រទានឱ្យច្រៀងពិតជាព្យាយាមប្រឹងហាត់ល្អិតល្អន់ណាស់ ។ លើសពីនេះពាក្យពេចន៍របស់ព្រះអង្គក៏មានលក្ខណៈជាក្យត្រដែរ ជាពិសេសដូចជាបទ **"រាត្រីដែលបានជួបភក្ត្រ"** អ្នកស្តាប់នៅតែនិយមស្តាប់មិនជិនណាយ ហើយគេតែតែឃើញអ្នកចម្រៀងនានាលើកយកបទនេះមកច្រៀងជាហូរហែ ព្រោះបទនេះពិរោះណាស់ ពិសេសគឺបទភ្លេងតែម្តង ។

នេះគឺទំនុកបទ **"រាត្រីដែលបានជួបភក្ត្រ"** **"មកលេងរាំវង់"** ដែលអ្នកម្នាងច្រៀងជាមួយលោក **ស៊ីនស៊ីសាមុត**នៅក្នុងរឿង**"អប្សរា"**ដែលនិពន្ធដោយ**សម្តេចឪ** និងបទ **"បើយើងនឹងបែក"** ច្រៀងក្នុងរឿង**"ឆាយាលើអង្គរ"** ។



# រាត្រីដែលបានជួបភក្ត្រ

**បទភ្លេង ទំនុកច្រៀង**
**សម្តេចឪ នរោត្តម សីហនុ**

**ច្រៀងដោយ**
**ស៊ីន ស៊ីសាមុត + សៀង ឌី**

I. (ប) ពេលរាត្រីបានជួបថ្លៃគូសង្សារ នេះគឺជាវាសនា ដែលបានសាង ពីបុព្វេ ។

II. (ស) ចិត្តសំគាល់ថាអស់ខ្វល់លែងរិះរេ អូនមិនបែកចិត្តទេ ប្រុសស្នេហ៍ចូរ ចងចាំ ។

R. (ប) មុនដូចនាវារសាត់តាមវាតា បក់នាំទៅឆ្ងាយ ព្រោះរូបបងសោភា លក្ខិណាសឹងឆើតឆាយ (ស) បងអើយ...អូនសប្បាយ ។

III. (ស) ព្រោះអូនបាន ប្រុសពន្លកដូចបំណង (រួម) ដែលប៉ងជាគូគ្រង លុះគ្រាអវសាន្ត ។



# មកលេងរាំវង់

បទភ្លេង ទំនុកច្រៀង
សម្ដេចឪ

ច្រៀងដោយ
ស៊ីន ស៊ីសាមុត + សៀង ឌី

I. ពេលរាត្រីខែភ្លឺមកលេងរាំវង់ ប្រុសស្រីមានទ្រង់រូបល្អអស្ចារ្យ
រូបល្អគួរឱ្យអូនស្នេហា ល្អអើយល្អដូចជាទេវតា គួរឱ្យអូនប្រាថ្នា
លើរៀមរ៉ាយូរហើយ ។

R. នាងអើយសូមនាងមករាំលេង (២ដង) ពួកយើងក្មេងៗ
មករាំលេងទាំងអស់គ្នា ។
ថយ ថយ ថយ ថយ កុំបែរមើលក្រោយ នាំគ្នារាំកំសាន្ត ។

# បើយើងនឹងបែក

| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
|---|---|
| ក្រុមភ្លេង SKD ច្រៀងក្នុងរឿង "ស្រមោលលើអង្គរ" | សៀង ឌី |

I. បើយើងនឹងបែក បែកដោយក្ដីសុខ គ្រាន់ទុកជាគ្នា

ពឹងពាក់ នៅគ្រាវេទនា ក្រៀមក្រំ ។

II. បើយើងនឹងឃ្លាត ឃ្លាតឱ្យសមរម្យ កុំតាមចងពៀរ

ជេរផ្ដាំ ផ្ញើតាមគ្នីគ្នា ឱ្យអូនចុកឈាម ។

R. កោតណាស់ឆាប់ក្រឡាស់ ចិត្ត ឥតស្ដាយស្រី ក្រៀមក្រំឱរា

តែ នឹកឃើញកាលណា ឈឺចាប់ខ្លោចផ្សារ អួលណែន ។

III. ឱ ! សែនស្រណោះ តែរូបសម្ផស្ស ចិត្តប្រុសអប្រិយ

ប៉ិនណាស់ ខាងល្បិចក្បត់ស្រី ស្រីនៅតែខ្លាច ។

## -ការចូលរួមក្នុងវង់ភ្លេង SKD :

ដោយបានច្រៀងថតថាស និងថតបញ្ចូលក្នុងខ្សែភាពយន្តរបស់សម្ដេចឪ ធ្វើឱ្យកេរ្តិ៍ឈ្មោះអ្នកម្នាងកាន់តែល្បីខ្លាំងមួយកម្រិតថែមទៀត ។

មានពេលមួយនោះ ក្នុងអំឡុងឆ្នាំ **១៩៦២** អ្នកម្នាងនិងអ្នកចម្រៀងផ្សេងៗទៀតក្នុងវង់ភ្លេង"**យោធាភិរម្យ**"បានទៅច្រៀងនៅឯ **វិមានរដ្ឋចំការមន** ដែលជាកន្លែងអ្នកធំៗធ្វើការ ពិសេសខាងខ្សែស្រឡាយរាជវង្ស ។ ដោយមានរូបសម្ផស្សស្រស់ផូរផង់ និងមានសម្លេងពិរោះផងនោះ អ្នកម្នាងត្រូវបានព្រះអង្គម្ចាស់កម្លោះមួយអង្គចាប់ចិត្តស្នេហា គឺព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ដែលជាបុត្រារបស់ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ សិរីមតៈ** ។




ពេលនោះព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ទើបមានព្រះជន្ម **២១** វស្សានៅឡើយ និងទើបតែត្រលប់ពីសិក្សានៅប្រទេសបារាំង ។ ក្រោយមកអ្នកម្នាង និងព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ក៏ផ្ដើមទំនាក់ទំនងស្នេហានឹងគ្នាពីពេលនោះមក ។

ចំណែកព្រះអង្គម្ចាស់ **ចរិយា** ដែលមានទេពកោសល្យខាងសល្បះតន្ត្រី និងបានសិក្សាខាងតន្ត្រីនេះជាច្រើនឆ្នាំផង ព្រះអង្គក៏បានចូលមកគ្រប់គ្រងវង់ភ្លេងមួយឈ្មោះវង់ភ្លេង **សុរាគាខ្មែរ** SKD" ហើយដែលសម្ដេចចក្រី **ញឹក ជូឡុង** ជាអ្នកគ្រប់គ្រងធំ ។ ក្រោយមក ទំនាក់ទំនងរវាង អ្នកម្នាងនិងព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ក៏បានស៊ីជំរៅ គឺបានក្លាយជាស្វាមីភរិយានឹងគ្នា ។ ហេតុនេះដោយសារស្វាមីជាអ្នកគ្រប់គ្រងវង់ភ្លេង SKD នេះ ទើបមកដល់អំឡុងឆ្នាំ **១៩៦៤** អ្នកម្នាងក៏ចេញពីវង់ភ្លេង"**យោធាភិរម្យ**" ហើយចូលច្រៀងក្នុង "**វង់ភ្លេងសុរាគាខ្មែរ**SKD" វិញ ។ កាលនោះវង់ភ្លេងនេះ អ្នកចម្រៀងដែលល្បីជាងគេគឺលោក **ថេត សម្បត្តិ** និងម្នាក់ទៀតឈ្មោះលោក **ហ្សង់** ជាកូនខ្មែរតែដាក់ឈ្មោះបារាំង ។ **ហ្សង់** ជាកូនលោក**ប៉ុក សំអាន** ដែលជាមន្ត្រីធំមួយរូបនៅជំនាន់នោះ ហើយលោក **ប៉ុក សំអាន** ទើបទទួលអនិច្ចកម្មកាលពីប៉ុន្មានឆ្នាំមុននេះទេនៅប្រទេសកម្ពុជា ប៉ុន្តែលោក **ហ្សង់** នៅមានជីវិតនៅឡើយ គឺលោកកំពុងរស់នៅប្រទេសបារាំង ។

អ្នកម្នាងពិពណ៌នាអំពីលក្ខណៈសម្បត្តិនៃអ្នកចម្រៀងប្រុស២ដ៏ល្បីប្រចាំ"**វង់ភ្លេងសុរាគាខ្មែរ** SKD" ទាំងពីរនាក់នេះថា ពួកគេទាំងពីរសង្ហាដូចគ្នា ទុកសក់វែងដូចតួកុន តែជំនាញច្រៀងផ្សេងគ្នា គឺលោក **ថេត សម្បត្តិ** ច្រៀងខាងបទមនោសញ្ចេតនា រីឯលោក ហ្សង់ ច្រៀងខាងបទញាក់និងបទបរទេស ។ត្រង់នេះ អ្នកម្នាងប្រដូចទៅនឹង"**វង់ភ្លេងយោធាភិរម្យ**" ថា លោក **តូច តេង** ច្រៀងខាងបទមនោសញ្ចេតនា ចំណែកលោក **លីវ តឹក** ច្រៀងបទញាក់និងបទបរទេស រីឯលោក **មាស សាម៉ន** ច្រៀងបទកំប្លែង ។

ក្រោយពេលដែលអ្នកម្នាងចូលច្រៀងបានបន្តិច អ្នកម្នាងក៏ឃើញលោក **ស៊ីន ស៊ី**

**សាម្មុត** និងលោក **ម៉ែរ ម៉ុន** នាំនារីៗអ្នកចម្រៀង ២ នាក់មកបញ្ចូលបន្ថែមនៅក្នុងវង់ភ្លេង SKD ទៀត គឺនាង **ម៉ែន រ៉ន** និងនាង **រស់ សេរីសុទ្ធា** ។ ដោយឡែកខាងវង់ភ្លេង "**យោធាភិរម្យ**" ក្រោយពេលអ្នកម្នាងចេញមកវង់ភ្លេង SKD នេះគេក៏បានរើសអ្នកស្រី **កែវ មន្ថា** ឱ្យចូលជំនួសវិញដើម្បីបង្គ្រប់ជាមួយអ្នកស្រី **ម៉ៅ សារ៉េត** និងអ្នកស្រី **ឈួន ម៉ាឡៃ** ។

និយាយអំពីការរើសអ្នកចម្រៀងនិងតន្ត្រីករមកបញ្ចូលក្នុងវង់ភ្លេង SKD នេះ អ្នកម្នាងបញ្ជាក់ថា ព្រះអង្គម្ចាស់ **ចរិយា** រើសអ្នកយកតែក្មេងៗចាប់ពី១៨ ទៅខ្ទង់ជាង២០ ឆ្នាំប៉ុណ្ណោះ ។ ចំពោះហេតុផលដែលរើសតែក្មេងៗដូច្នេះ ដើម្បីយកទៅបណ្តុះបណ្តាលឱ្យមានការងារធ្វើ និងសំរាប់ប្រលងក្នុងពិធីសមាជជាតិនិងបុណ្យជាតិធំៗ ព្រោះបើវង់ភ្លេងណាលេងល្អហើយតន្ត្រីករនិងអ្នកចម្រៀងមានរូបសម្បត្តិស្អាតៗទៀតនោះ គឺពិតជាមានការគាំទ្រច្រើនពីមហាជនយ៉ាងផុសផុល ហើយចំណាត់ថ្នាក់ក៏ជាប់ទៅតាមនោះដែរ ។

ដូច្នេះហើយបានជាសិល្បករនិងតន្ត្រីករជំនាន់នោះសុទ្ធតែនឹកគុណព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ព្រោះក្រោយពេលពួកគេរៀនចេះលេងភ្លេងចេះច្រៀងនៅក្នុងវង់ភ្លេង SKD នេះហើយ ព្រះអង្គបាននាំពួកគេទៅឱ្យលេងភ្លេងតាមរង្គសាល និងតាមកន្លែងកំសាន្តនានាជាច្រើនទៀតក្នុងទីក្រុងភ្នំពេញ ដែលអាចឱ្យពួកគេមានការងារធ្វើ និងបានទទួលប្រាក់ខែចិញ្ចឹមជីវិតយ៉ាងគាប់ប្រសើរគ្រប់ៗគ្នា ។

បែរមកវង់ភ្លេង SDK វិញ តន្ត្រីករអចិន្ត្រៃយ៍ក៏មានចំនួនចាប់ពី **២២** ទៅ **២៥** នាក់នាក់ដូច "**វង់ភ្លេងយោធាភិរម្យ**" ដែរ ។ ទាក់ទងនឹងវង់ភ្លេងនេះ អ្នកម្នាង**សៀង ឌី** មានប្រសាសន៍ឱ្យដឹងទៀតថា ជំនាន់នោះវង់ភ្លេងនីមួយៗប្រជែងគ្នាណាស់ ។ ពេលចេញប្រគុំម្តងៗ ដូចជានៅក្នុងឱកាសប្រារព្ធពិធីសមាជជាតិនៅវាលមេរុ( វាលមេន) ខាង

ជើងព្រះបរមរាជវាំងរៀងរាល់ឆ្នាំ វង់ភ្លេងទាំងនោះប្រឹងបញ្ចេញអស់ទេពកោសល្យនិង សមត្ថភាពដើម្បីទាក់ទាញទស្សនិកជន ។ ក្នុងនោះមាន"**វង់ភ្លេងយោធាភិរម្យ**"របស់ កងទ័ព "**វង់ភ្លេងឃោសនាការ** " របស់វិទ្យុជាតិ "**វង់ភ្លេងរាជតម្រួតភិរម្យ**"របស់ កងនគរបាលជាតិ និង"**វង់ភ្លេងសុរាគារខ្មែរ**SKD"របស់ក្រុមហ៊ុនជាតិខាងផលិតស្រា ។ល ។និង ។ល ។

រៀងរាល់ឆ្នាំនៅក្នុងពិធីបុណ្យជាតិធំៗ គេតែងតែងឃើញវង់ភ្លេង"**យោធាភិរម្យ**" និងវង់ភ្លេង"SKD" ប្រគុំប្រកួតប្រជែងគ្នាដូចក្នុងពិធីប្រលងដែរ ដើម្បីចង់ទទួលបាននូវ ការគាំទ្រពីមហាជន ហើយព្រឹត្តិការណ៍នោះមានការនិយមចូលចិត្តទស្សនាណាស់ពីអ្នក ស្រលាញ់សិល្បៈតន្ត្រី ។



អ្នកម្នាង សៀង ឌី
នៅប៉ារីស ឆ្នាំ ១៩៩៣


សម សាខន (១៩៦៤) ឈុន ម៉ាឡៃ ម៉ៅ សារ៉េត សៀង ឌី


ឱស្វាយចន្ទី
Choix des Chansons Ramvong
Cambodgiennes
Chantées par les Célèbres Chanteurs et Chanteuses Cambodgiennes
INDEPENDANCE
MARQUE DEPOSEE
H-2708

## -ការលាឈប់ពីសិល្បៈ

លុះបានប្រមាណជាង ៣ឆ្នាំក្រោយ ក្នុងអំឡុងឆ្នាំ **១៩៦៨** ខណៈពេលអ្នកម្នាងនិងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ក្លាយជាស្វាមីភរិយានឹងគ្នា អ្នកម្នាងក៏ឈប់ច្រៀងតាំងពីពេលនោះរហូតមក ។ លុះអ្នកម្នាងឈប់ច្រៀង គេក៏រើសអ្នកចម្រៀងថ្មីៗមកបញ្ចូលជាបន្តបន្ទាប់ ដូចជាអ្នកស្រី **សៀវ វ៉ាន់ធី** ប្អូនស្រីអ្នកម្នាង អ្នកស្រី **ប៉ែន រ៉ម** ប្អូនរបស់អ្នកស្រី **ប៉ែន រ៉ន** និងអ្នកស្រី **ស៊ឹម ទូច** ជាដើម ។ ចំពោះអ្នកស្រី**សៀវ វ៉ាន់ធី** អ្នកម្នាងមានប្រសាសន៍ថា គេរើសគាត់ចូលក្រោយពេលដែលគាត់ប្រលងជាប់លេខ ១ នៅក្នុងសមាជជាតិនាអំឡុងឆ្នាំនោះ ។ ហើយក្រោយពេលដែលអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ស្វាមីអ្នកម្នាងលាឈប់ពីសិល្បៈ ទើបលោក **ហាស់ សាឡុន** ដែលជាតន្ត្រីករវិយូឡុងល្បីឯកដាច់គេនៅជំនាន់នោះ និងត្រូវជាបងថ្លៃអ្នកម្នាងផងនោះចូលមកគ្រប់គ្រងបន្ត ។ សូមបញ្ជាក់ឡើងវិញថា លោក **ហាស់ សាឡុន** ជាស្វាមីអ្នកស្រី **សូសាវិនណារ៉ា** បងស្រីបង្អស់របស់អ្នកម្នាង **សៀវ ឌី** ។

អ្នកម្នាងមានប្រសាសន៍ទៀតថា អ្នកស្រី **ប៉ែន រ៉ន** និងអ្នកស្រី **រស់ សេរីសុទ្ធា** ពេលថ្ងៃច្រៀងនៅវង់ភ្លេង SKD ពេលយប់ច្រៀងនៅរង្គសាល **ចតុមុខ** មាត់ទន្លេ ។ ហើយបទដែលអ្នកស្រី **ប៉ែន រ៉ន** ច្រៀងល្បីមុនគេកាលនៅច្រៀងក្នុងវង់ភ្លេង SKD នេះគឺបទ "**ក្តៅថ្ងៃមិនស្មើក្តៅចិត្ត**" ដែលនិពន្ធដោយលោក **វ៉ោយ ហូ** ។ ចំណែកអ្នកស្រី **ឈុន វណ្ណា** បទល្បីទី១ គឺបទ "**អូនស្រលាញ់តែបងមួយនាក់**" ច្រៀងដាក់វិទ្យុជាតិ ។ តែសូមបញ្ជាក់ថា អ្នកស្រី **ឈុន វណ្ណា** មិនមែនជាអ្នកចម្រៀងនៅក្នុងវង់ភ្លេង SKD ទេ ។ ចំពោះការលើកឡើងរបស់អ្នកម្នាងនេះ គ្រាន់តែដើម្បីរំលឹកទៅដល់សិល្បការិនីមួយចំនួនដែលអ្នកម្នាងនៅចាំបានប៉ុណ្ណោះ ។

# អ្នកម្នាង សៀង ឌី អ្នកស្រី ឌី សាវ៉េត និងលោក ម៉ម ប៊ុនណារ៉ាយ តន្ត្រីករ ជើងចាស់ជំនាន់អ្នកម្នាង (នៅសៀមរាប)



លុះក្រោយពេលស្វាមីនិងអ្នកម្នាងឈប់ប្រឡូកក្នុងសិល្បៈនៅអំឡុងឆ្នាំ **១៩៦៨** នោះ អ្នកម្នាងនិងស្វាមីបានងាកមកប្រកបអាជីពផ្សេងរៀង១ខ្លួនវិញ គឺព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** បានចូលទៅបំរើការងារជាអ្នក **ដេគ័រ**( តុបតែង)នៅក្នុងក្រុមហ៊ុន Magasin D'etat" ។ ឯអ្នកម្នាងមិនមែនធ្វើត្រឹមមេផ្ទះមួយមុខប៉ុណ្ណោះទេ ពេលនោះ

អ្នកម្នាងបើករង្គសាលមួយឈ្មោះ "**អប្សរា**" ជារង្គសាលបណ្តែតលើទឹក ស្ថិតនៅខាងមុខព្រះបរមរាជវាំង ហើយអ្នកម្នាងក៏បានហៅអ្នកស្រី **ម៉ែន វ៉ន** អ្នកស្រី **ម៉ៅ សារ៉េត** និងអ្នកស្រី **រស់ សេរីសុទ្ធា** ទៅច្រៀងនៅពេលយប់ៗផងដែរ ។ បន្ទាប់មកអ្នកម្នាងក៏បានបើកហាងលក់ម្ហូបអាហារនិងភេសជ្ជៈមួយទៀតឈ្មោះ **ប៊ូវ៉ែត** "Buvette" នៅខាងជើងស្តាតអូឡាំពិក ។ អ្នកម្នាងបានហៅពួកតន្ត្រីករក្មេងៗនៅវង់ភ្លេងSKD ទៅប្រគុំកំដរភ្ញៀវជារៀងរាល់យប់ដើម្បីហាត់លេងភ្លេងឱ្យកាន់តែស្ទាត់ជំនាញផង និងបានប្រាក់ចំណូលផង ។

និយាយមកដល់ចំណុចនេះ ជំនាន់នោះ គ្រួសារព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** និងអ្នកម្នាង **សៀង ឌី** មានសណ្តានចិត្តល្អណាស់គឺសុទ្ធតែមានគុណចំពោះអ្នកចម្រៀង និងតន្ត្រីករជាច្រើននាក់ ។ ហើយតន្ត្រីករនិងអ្នកចម្រៀងជំនាន់នោះស្រលាញ់គ្នានិងចេះជួយគ្នាទៅវិញទៅមក ។



**អ្នកម្នាង សៀង ឌី និងអ្នកម្នាង ឌី យ៉ាត (នៅស្រុកខ្មែរ)**



អ្នកម្នាង សៀង ឌី នៅប៉ារីស ឆ្នាំ ១៩៧៤)

## -ជីវិតក្រោយសម័យ "សង្គមរាស្ត្រនិយម"

នៅថ្ងៃទី **១៨** ខែ **មិនា** ឆ្នាំ **១៩៧០** ក្រុមលោកសេនាប្រមុខ **លន់ នល់** បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចឪពីរាជបល្លង្គនៃរបប "**សង្គមរាស្ត្រនិយម**" ។ សភាពការណ៍ប្រទេសជាតិមានការប្រែប្រួលយ៉ាងខ្លាំង ។ សង្គ្រាមចាប់ផ្តើមផ្ទុះឡើងជាបន្តបន្ទាប់ ។ ប្រជាជនទាំងនៅក្នុងទីក្រុងនិងតាមបណ្តាខេត្តនានាសុទ្ធតែមានការជ្រួលច្របល់ ។ អ្នកដែលមានធនធានក្រាស់ក្រែលបាននាំគ្នាភៀសខ្លួនទៅបរទេសជាបន្តបន្ទាប់ព្រោះមិនទុកចិត្តលើស្ថេរភាពសង្គមក្រោមរបបដឹកនាំថ្មីនេះ ។

ចំណែកអ្នកម្នាងនិងស្វាមីដែលជាប់ខ្សែរាជវង្សដឹងរឿងរ៉ាវកាន់តែច្បាស់នោះ ក៏នាំគ្នារៀបផែនការចាកចេញទៅក្រៅប្រទេសដែរ ។ លុះ ១ ឆ្នាំក្រោយ គឺនៅឆ្នាំ **១៩៧១** ខណៈពេលប្រសូត្របានបុត្រប្រុស១ អាយុ៤ ខែ អ្នកម្នាងនិងស្វាមីក៏សំរេចចិត្តនាំគ្នាចាកចេញពីស្រុកខ្មែរទៅកាន់ប្រទេសថៃដើម្បីរកច្រកទៅកាន់ប្រទេសទីបី ។ នៅប្រទេសថៃជិត១ឆ្នាំ នៅដើមឆ្នាំ **១៩៧២** អ្នកម្នាងនិងស្វាមីក៏ចេញទៅរស់នៅទីក្រុង**ហុងកុង** ។ លុះរស់នៅ **ហុងកុង** បានប្រហែល១ឆ្នាំ នៅឆ្នាំ **១៩៧៣** អ្នកម្នាងក៏បានចេញមករស់នៅទីក្រុង **ប៉ារីស** ប្រទេស**បារាំង** បន្ត ។ ហើយគឺទឹកដី **បារាំង** នេះឯងដែលជាទីសំចតវែងជាងគេក្នុងការចាកចេញទៅរស់នៅបរទេសរបស់អ្នកម្នាង ។ ទៅដល់ទីនេះអ្នកម្នាងបានរៀនខាងថ្នេម៉ូដសម្លៀកបំពាក់យ៉ាងស្ទាត់ជំនាញ ហើយក្រោយមកក៏បានបើកហាងកាត់ម៉ូដសម្លៀកបំពាក់នេះរហូតមក ។

លុះរស់នៅនិងធ្វើការនៅប្រទេសបារាំងនេះអស់ជាច្រើនឆ្នាំ គឺមកដល់ឆ្នាំ **១៩៨២** អ្នកម្នាង ស្វាមី និងកូនប្រុស ក៏ចាកចេញទៅរស់នៅ **ទីក្រុង ប៉េកាំង ប្រទេស ចិន** វិញដើម្បីធ្វើការបំរើសម្តេចឪ ។ លុះ៣ឆ្នាំក្រោយ គឺក្នុងឆ្នាំ **១៩៨៥** អ្នកម្នាងនិងស្វាមី

អ្នកម្នាង សៀង ឌី និងអ្នកចម្រៀងថៃ ឈ្មោះ ខាវី ច្រៀង



បានសំរេចចិត្តចាកចេញពី **ប្រទេសចិន** ទៅរស់នៅទីក្រុង **ឡុងប៊ិច** រដ្ឋ **កាលីហ្វ័ញ៉ា** (California) សហរដ្ឋអាមេរិច ។ ការមកប្រទេសភាគខាងលិចនេះ អ្នកម្នាងមានប្រសាសន៍ថា គឺមកដើម្បីយកកូនមកឱ្យរៀនផងនិងដើម្បីមកធ្វើការផង។ នៅទីនេះ ក៏មិនខុសពីប្រទេសបារាំងដែរ អ្នកម្នាងបានបើកហាងថ្មៃម៉ូដសម្លៀកបំពាក់មួយនៅក្បែរផ្សារ **បាយ៉័ន** (ផ្លូវលេខ១០) ដែលជាផ្សារលក់ផលិតផលចម្រុះរបស់លោក **ថាច់សួន** ដោយក្នុងនោះក៏មានលក់កាសែតចម្រៀងផងដែរ ។

**អ្នកម្នាង សៀង ឌី ជាមួយសិល្បករ សិល្បការិនី និងមិត្តភក្តិ នៅទីក្រុង ប៉ារីស ប្រទេស បារាំង ឆ្នាំ ២០០៣**



អ្នកម្នាង សៀង ឌី (ប្រទេសចិន ឆ្នាំ ២០០៧)





អ្នកម្នាង សៀង ឌី និងសម្ដេចឪ (ប៉ារីស ១៩៨២)



អ្នកម្នាង សៀង ឌី និងសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី (ព្រះមហាក្សត្របច្ចុប្បន្ន) (ប៉េកាំង ១៩៨៥)

អ្នកម្នាង សៀង ឌី និងសម្តេចឪ (នៅតូក្យូ ជប៉ុន




អ្នកម្នាង សៀង ឌី ជាមួយកូនប្រុស កូនប្រសារស្រី និងជន្លងប្រុស ព្រមទាំងសម្តេចឪ សម្តេចម៉ែ នៅប្រទេសចិន ឆ្នាំ ១៩៩២)



## ~ស្នាដៃសិល្បៈនៅអាមេរិច

ពេលមករស់នៅអាមេរិចក្នុងរដ្ឋ **កាលីហ្វ័រញ៉ា** នេះ ក្រៅពីប្រកបអាជីពជាអ្នកថ្មែម៉ូដសម្លៀកបំពាក់ លោក **ថាច់ សួន** ដែលជាថៅកែផ្សារបាយ័នហើយដែលបានស្គាល់ទឹកដមអ្នកម្នាងកាលដែលប្រឡូកសិល្បៈកាលពីជំនាន់លោក **ស៊ីន ស៊ីសាមុត** នោះក៏បានជម្រុញឱ្យអ្នកម្នាងពង្រស់សម្លេងដែលខានប្រើការអស់ជាច្រើនសិបឆ្នាំនោះ ឱ្យមានសូរសៀងឡើងវិញ ។ ពេលនោះលោក **ថាច់ សួន** បានស្នើរឱ្យអ្នកម្នាងលើកយកបទចាស់ៗរបស់អ្នកម្នាងនិងបទចាស់របស់អ្នកចម្រៀងផ្សេងៗទៀតមកថតច្រៀងឡើងវិញដើម្បីដាក់លក់លើទីផ្សារជូនបងប្អូនខ្មែរនៅទឹកដីអាមេរិចនោះបានស្តាប់ជាថ្មី ។ពេលនោះដោយលោក **ថាច់ សួន** លើកទឹកចិត្តនិងធានារ៉ាប់រងក្នុងការចំណាយទាំងអស់ បូករួមទាំងផ្តល់ប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ដល់អ្នកម្នាងផង អ្នកម្នាងក៏សំរេចចិត្តវិលចូលសិល្បៈវិញតាមការសំណូមពរនេះ ។ ពេលនោះអ្នកម្នាងក៏បានរើសបទចាស់ៗមកថតជាកាសែតបានរាប់សិបបទដោយមានស្វាមីអ្នកម្នាងគឺព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ជាអ្នករៀបសម្រួលតន្ត្រី ហើយលោក **សាន គឹមសៀន** ជាអ្នកដេញហ្គីតាសូឡូ និងប្រគុំថតដោយវង់ភ្លេង **អប្សរា** ។

បទចម្រៀងដែលអ្នកម្នាងលើកមកច្រៀងឡើងវិញ ថតដាក់កាសែតទី ១ ឈ្មោះកាសែត"**អន់ចិត្តរឿងអ្វី?**" នោះរួមមានបទ :

១- **ទឹកភ្នែកមុនថ្ងៃលិច** បទដើមរបស់អ្នកម្នាង

២- **ប្រុស ១** បទដើមអ្នកស្រី **សៀង វ៉ាន់ធី**

៣- **អន់ចិត្តរឿងអ្វី ?** បទដើមអ្នកស្រី **សៀង វ៉ាន់ធី**

៤- **រាំវង់ឆ្នាំថ្មី** បទដើម.........?

៥- ឧន្លេ សូឡូ (Solo) បទដើមអ្នកស្រី ឈួន ម៉ាឡៃ

៦- ស្លឹកឈើចាកមែក បទដើមលោក ស៊ីន ស៊ីសាមុត

៧- ព្រែកឯងអស់សង្ឃឹម បទដើមលោក ស៊ីន ស៊ីសាមុត

៨- ព្រែកឆ្លូង បទដើមលោក សុះ ម៉ាត់

៩- អូនស្រលាញ់តែបងមួយ បទដើមអ្នកស្រី ហួយ មាស

១០- បុប្ផារីកមាត់បង្អួច បទដើមលោក ស៊ីន ស៊ីសាមុត

ក្រៅពីនេះ នៅមានចម្រៀងជាច្រើនបទទៀតប៉ុន្តែអ្នកម្នាងភ្លេចអស់ទៅហើយ។

## ស្រោមកាសែត ទី ១ "អន់ចិត្តរឿងអ្វី ?"



អ្នកម្នាងនិងព្រះអង្គម្ចាស់ ចរិយា (នៅរដ្ឋ Virginia (USA) ១៩៧៨)




អ្នកម្នាង សៀង ឌី ជាមួយសម្តេចព្រះរាម បុប្ផាទេវី និងអ្នកម្នាង អារុណរស្មី នៅ New York ១៩៩១)



លុះនៅរដ្ឋនេះដល់ឆ្នាំ **១៩៨៧** អ្នកម្នាងនិងស្វាមីក៏ចេញទៅរស់នៅរដ្ឋ **វ៉ាស៊ីនតោន** (Washington DC) បន្ត ។ លុះដល់ចុងទ.វឆ្នាំ **១៩៨០** គឺ អំឡុងឆ្នាំ **១៩៨៩** អ្នកម្នាងនិងស្វាមីក៏វិលមករស់នៅទីក្រុង **ឡុងប៊ិច** រដ្ឋ **កាលីហ្វ័រញ៉ា** (California) វិញ ។ ដល់ឆ្នាំ **១៩៩១** អ្នកម្នាងបានវិលទៅទីក្រុង New York ចំនួន២សប្តាហ៍ ។ ហើយនៅឆ្នាំដដែលនោះអ្នកម្នាងនិងស្វាមីក៏បានវិលមករស់នៅប្រទេសបារាំងវិញ ។ ការវិលមកប្រទេសបារាំងវិញ លើកនេះក៏មិនខុសពីលើកមុនដែរ អ្នកម្នាងបានរស់នៅទីនេះយូរ និងប្រកបការងារជាអ្នកច្នៃម៉ូដសម្លៀកបំពាក់ជាថ្មី ។



**អ្នកម្នាង សៀង ឌី នៅរដ្ឋ កាលីហ្វ័រញ៉ា ឆ្នាំ ១៩៨៧**

អ្នកម្លាងនិងព្រះបរមនាថ ព្រះបាទ សីហមុនី (ប៉ារីស ១៩៨២)





អ្នកម្លាងនិងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ចរិយា (ប៉ារីស ១៩៩៣)



អ្នកម្នាងសៀង ឌីនិងគ្រួសាររាជវង្សនៅបារាំង ឆ្នាំ ១៩៨២



អ្នកម្នាង សៀង ឌី និងអ្នកស្រី ឌី សាវ៉េត នៅបារាំង ឆ្នាំ ១៩៧៨





អ្នកម្នាង សៀង ឌី និងអ្នកស្រី ឌី សាវ៉េត (ប៉ារីស ១៩៩៣)





អ្នកម្នាងជាមួយលោក ម៉ុល កាម៉ាច និងលោក ហួ ឡូញ (ប៉ារីស ឆ្នាំ ១៩៩១)

## ៚អានុស្សាវរីយ៍ជាមួយលោក កែវ សារ៉ាត់ :

ដូចយើងបានឃើញមកហើយនូវវត្តមានអ្នកម្នាង **សៀង ឌី** ដែលបានមករស់នៅទឹកដីអាមេរិច និងការប្រឡូកនៅក្នុងសិល្បៈជាថ្មីនៅទីនេះ ។ ចំណែកហាងច្នៃម៉ូដរបស់អ្នកម្នាងគឺនៅជាប់ផ្សារបាយ័នរបស់លោក **ថាច់ សួន** ។ បាទ ! គឺដោយសារតែការមកដល់អាមេរិចនេះហើយ ដែលជាដើមហេតុនាំឱ្យអ្នកម្នាងបានស្គាល់អ្នកចម្រៀងថ្លាមខ្លា**កែវ សារ៉ាត់** ហើយក្រោយមកអ្នកម្នាងនិងអ្នកចម្រៀងដែលមានប្រភពមកពីទីជនបទដាច់ស្រយាលនៃខេត្ត បាត់ដំបង រូបនេះបានសាងអានុស្សាវរីយ៍ក្នុងរង្វង់សិល្បៈរួមគ្នាជាច្រើនរហូតធ្វើឱ្យកេរ្តិ៍ឈ្មោះលោក **កែវ សារ៉ាត់** កាន់តែល្បីល្បាញថែមទៀត ។

ទាក់ទងទៅនឹងដំណើររឿងទាំងស្រុងក្នុងវេលានោះ អ្នកម្នាង **សៀង ឌី** មានប្រសាសន៍រំឭកឡើងវិញថា ខណៈដែលអ្នកម្នាងមកដល់រដ្ឋ**កាលីហ្វ័រញ៉ា សហរដ្ឋអាមេរិច** នៅឆ្នាំ**១៩៨៥** ហើយបើកហាងកាត់ម៉ូដសម្លៀកបំពាក់នៅជាប់ **ផ្សារបាយ័ន** របស់លោក **ថាច់សួន** នោះ ។ លុះប្រហែល២ឆ្នាំក្រោយ គឺក្នុងអំឡុងឆ្នាំ **១៩៨៧** មានថ្ងៃមួយ ពេលអ្នកម្នាងកំពុងកាត់ម៉ូដក្នុងហាង ស្រាប់តែឮគេចាក់ចម្រៀងរបស់លោក **កែវ សារ៉ាត់** លឿយៗពីផ្សារបាយន័នោះ ប៉ុន្តែពេលនោះអ្នកម្នាងមិនទាន់ស្គាល់ឈ្មោះលោក **កែវ សារ៉ាត់** ទេ ។

នៅពេលឮសម្លេងអ្នកចម្រៀងនោះ អ្នកម្នាងក៏នឹកក្នុងចិត្តម្នាក់ឯងថា ***ចុះសម្លេងអ្នកណាអីក៏ពិរោះម្លេះ ? ....*** ដោយអត់ទ្រាំមិនបាន អ្នកម្នាងក៏ដើរមកផ្សារបាយ័ននោះហើយសួរលោក **ថាច់ សួន** ថា តើអ្នកចម្រៀងនេះឈ្មោះអ្វី ? ពេលនោះលោក **ថាច់ សួន** ប្រាប់មកវិញថា ឈ្មោះ **កែវ សារ៉ាត់** ។ ពេលឮលោក **ថាច់ សួន** ប្រាប់អំពីឈ្មោះអ្នកចម្រៀងនេះ អ្នកម្នាងបានប្រាប់លោក **ថាច់ សួន** វិញថា អ្នកចម្រៀងនេះ

មានសម្លេងពិរោះណាស់ ប៉ុន្តែបើសិនយកមកបង្ហាត់បង្ហាញបន្ថែមទៀតហើយឱ្យច្រៀងបទបែបទីក្រុង ពិតជាកាន់តែពិរោះនិងល្បីខ្លាំងមិនខាន ។ បង្ហាញហេតុផលរួច អ្នកម្នាងក៏ពឹងឱ្យលោក **ថាច់ សួន** ជូនទៅជួបលោក **កែវ សារ៉ាត់** តែលោក **ថាច់ សួន** ប្រាប់មកវិញថា លោក **កែវ សារ៉ាត់** នៅឆ្ងាយណាស់ គឺនៅ **ស្តុកតុន** (Stocton) ឯណោះ តែពេលនោះលោក **ថាច់ សួន** ប្រាប់ថា ចាំគាត់រកមនុស្សឱ្យហៅលោក **កែវ សារ៉ាត់** មកជួបអ្នកម្នាង ។ ពេលនោះលោក **ថាច់ សួន** ក៏បានពឹងលោក **សែម** ដែលជាអតីតតន្ត្រីករជើងចាស់មួយរូបនៅក្នុងវង់ភ្លេងព្រះបរមរាជវាំង ឱ្យធ្វើដំណើរទៅកាន់ទីក្រុង **ស្តុកតុន** ដើម្បីអញ្ជើញលោក **កែវ សារ៉ាត់** មកជួបអ្នកម្នាងនៅ **ឡុងប៊ិច** ។

លុះពេលជួបលោក**កែវ សារ៉ាត់** ហើយ អ្នកម្នាងក៏ប្រាប់ពីបំណងដែលចង់អញ្ជើញគាត់ឱ្យច្រៀងថតដាក់កាសែតនិងការជ្រោមជ្រែងឱ្យមានកេរ្តិ៍ឈ្មោះកាន់តែល្បី ។ ពេលនោះ លោក**កែវ សារ៉ាត់** ក៏យល់ស្របតាមអ្វីដែលអ្នកម្នាងលើកឡើង រួចក៏កំណត់ថ្ងៃថតជាផ្លូវការ ។



ពេលនិយាយត្រូវគ្នាជាមួយលោក **កែវ សារ៉ាត់** ហើយ អ្នកម្នាងនិងព្រះអង្គម្ចាស់**ស៊ីសុវត្ថិ ចរិយា** ជាស្វាមីក៏ជំនុំគ្នារើសបទចម្រៀងល្អៗជំនាន់ដើម ដែលអ្នកម្នាងគិតថាស៊ីគ្នានឹងសម្លេងលោក **កែវ សារ៉ាត់** ទុកឱ្យអ្នកចម្រៀងវ័យក្មេងនេះច្រៀង ។ សូមបញ្ជាក់ថា កាលនោះលោក **កែវ សារ៉ាត់**

មានអាយុមិនទាន់៣០ឆ្នាំនៅឡើយទេ ។

ក្រោយពីចំណាយពេលអស់ជាច្រើនថ្ងៃ អ្នកម្នាងនិងស្វាមីរើសបានចម្រៀង៥បទទុកឱ្យលោក **កែវ សារ៉ាត់** សំរាប់ថតក្នុងកាសែតវ៉ុលទី១ នេះរួមមានបទ :

១- **ដួងនេត្រា** បទដើមលោក **ស៊ីន ស៊ីសាមុត**

២- **អានុស្សាវរីយ៍បាត់ដំបង** (វត្តដំរីស) បទដើមលោក **ស៊ីន ស៊ីសាមុត**

៣- **កន្សែងស្រីបាក់** បទដើមលោក **ស៊ីន ស៊ីសាមុត**

៤- **លលកញីឈ្មោល** បទដើមលោក **មាស ហុកសេង**

៥- **ឆ្នាំមុន** បទដើមលោក **អ៊ឹម សុងសឺម**

ពេលនោះអ្នកម្នាងដាក់ឈ្មោះកាសែតនោះថា "កាសែត"**ដួងនេត្រា**" ហើយក៏បានរើសចម្រៀងចាស់៥បទដែលអ្នកម្នាងបានច្រៀងកាលពីជំនាន់លោក **ស៊ីន ស៊ីសាមុត** ដើម្បីច្រៀងដាក់បញ្ចូលក្នុងវ៉ុលទី១នេះដែរ ។ បទទាំងនោះរួមមាន :

១- **ចម្រៀងអស់សង្ឃឹម**

២- **ក្មេងកែបឱសថនិព្វ**

៣- **ព្រោះតែស្រលាញ់**

៤- **សម្រស់ខេត្តមណ្ឌលគីរី**

៥- **ចរិយា**

បន្ទាប់ពីរើសចម្រៀងរួចហើយ ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ក៏បានទិញម៉ាស៊ីនថតសម្លេងមួយគ្រឿងដែលមានទំហំប្រមាណ៥សង់ទីម៉ែតទុកថតបទភ្លេងដែលព្រះអង្គលេងចេញពីអ៊ិកនិងទុកថតសម្លេងលោក **កែវ សារ៉ាត់** បញ្ចូលជាមួយបទភ្លេងនោះ ។ ឧបករណ៍ភ្លេងនោះមាន ៤ Track សំរាប់ថតភ្លេងនិងសម្លេង ។

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ចរិយា (កាលីហ្វ័រញ៉ា ១៩៨៧)



អ្នកម្នាងមានប្រសាសន៍ថា : កាលថតបទទាំងនេះគឺពុំមានអ្នកភ្លេងអ្វីទេ គឺសុទ្ធតែជាស្នាព្រះហស្តព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** កែច្នៃលេងតែម្នាក់ឯងគត់ ។ គឺបើបទនេះមានសម្លេងហ្គីតា ព្រះអង្គចុចអ៊ីកចេញជាសម្លេងហ្គីតាថតបញ្ចូលក្នុងម៉ាស៊ីននោះទុក ។ ហើយបើមានសម្លេងស្គរ ព្រះអង្គចុចអ៊ីកចេញជាសម្លេងស្គរថតក្នុងម៉ាស៊ីននោះដែរ ឬបើមានសម្លេងឧបករណ៍ភ្លេងអ្វីផ្សេងៗទៀត គឺព្រះអង្គធ្វើបែបនោះទាំងអស់ ។ លុះលេងភ្លេងថតទុករួចទើបព្រះអង្គច្របាច់ភ្លេងទាំងនោះបញ្ចូលគ្នា (Mixភ្លេង) ឱ្យទៅបទភ្លេងតែមួយ រួចទើបអ្នកចម្រៀងចូលមកច្រៀងថតបញ្ចូលជាក្រោយ ។ ត្រង់ចំណុចនេះ យើងគួរឱ្យកោតសរសើរដល់ព្រះអង្គម្ចាស់ណាស់ គឺពូកែលេងភ្លេងមែនទែន ហើយមូលហេតុដែលព្រះអង្គអាចធ្វើភ្លេងទាំងនោះតែមួយអង្គឯងបាន ក៏ព្រោះតែព្រះអង្គធ្លាប់ជាមេភ្លេងនៅវង់ភ្លេង SKD កាលជំនាន់ដើមនោះឯង ។ហើយបើយើងបានស្តាប់បទទាំងនោះ គឺដូចបទទាំងនោះលេងដោយតន្ត្រីករច្រើនគ្នាប្រគុំក្នុងពេលតែមួយដូច្នេះដែរ ប៉ុន្តែការពិត គឺស្នាព្រះហស្តព្រះអង្គម្ចាស់ **ចរិយា** ធ្វើតែមួយអង្គឯងគត់ ហើយកាលនោះ ពុំទាន់មានតន្ត្រីករណាចេះលេងឧបករណ៍ភ្លេងម៉ាស៊ីនបែបនេះដូចព្រះអង្គនៅឡើយទេ ។

លុះធ្វើអ្វីៗបានចប់សព្វគ្រប់ហើយអ្នកម្នាងក៏ហៅលោក **កែវ សារ៉ាត់** មកថត ។ ពេលនោះ ស្ទូឌីយោ (Studio) គឺអ្នកម្នាងបានរៀបជាបន្ទប់មួយនៅក្នុងហាងកាត់ម៉ូដរបស់អ្នកម្នាងនោះតែម្តង ។ ទោះបីរៀបក្នុងហាងនោះមែន តែគ្មានសម្លេងឆ្លងទេ ព្រោះអ្នកម្នាងបានទិញក្បាលមេក្រូប្រភេទដ៏ល្អរបស់អាមេរិចកាំងគឺស្រូបតែសម្លេងអ្នកច្រៀងប៉ុណ្ណោះ រីឯសម្លេងរំខានផ្សេងៗដែលនៅចម្ងាយ១ម៉ែតជុំវិញគឺមិនឆ្លងចូលឡើយ ។

អ្នកម្នាងមានប្រសាសន៍ឱ្យដឹងបន្ថែមថា : កាលថតដំបូងនោះ លោក កែវ សារ៉ាត់ ច្រៀងបានពិរោះល្អណាស់ ថតមិនសូវខុសច្រើនឡើយ ហើយពេលនោះ**សម្តេចព្រះរាម**

**បុប្ផាទេវី** ក៏គង់នៅក្នុងស្ទូឌីយោ (Studio) ជាមួយព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ទតលោក **កែវ សារ៉ាត់** ច្រៀងដែរហើយ **សម្តេចព្រះរាម បុប្ផាទេវី** សព្វព្រះទ័យនឹងសម្លេងលោក **កែវ សារ៉ាត់** ណាស់ ។

**អ្នកម្នាង សៀង ឌី ជាមួយសម្តេចព្រះរាម បុប្ផាទេវី និងមិត្តភក្តិ (កាលីហ្វ័រញ៉ា ១៩៨៧)**



លុះពេលលោក **កែវ សារ៉ាត់** និងអ្នកម្នាងច្រៀងថតរួចទាំងអស់គ្នា អ្នកម្នាងក៏ហៅលោក **កែវ សារ៉ាត់** ទៅតុបតែងខ្លួនយ៉ាងស្រស់សង្ហាថតរូប ដើម្បីផ្ដិតដាក់គំរបកាសែត ។ពេលនោះអ្នកម្នាងបានសុំខ្ចីសម្លៀកបំពាក់របស់ស្វាមីឱ្យលោក **កែវ សារ៉ាត់** ស្លៀកពាក់ថត ។ ដោយសាជាអ្នកច្នៃម៉ូដស្រាប់ហើយស្រលាញ់ការតុបតែងខ្លួនតាំងពីដើមនោះ អ្នកម្នាងបានយកចិត្តទុកដាក់យ៉ាងអស់ពីចិត្តពីថ្លើមចំពោះការតុបតែងខ្លួន និងការស្លៀកពាក់ឱ្យលោក **កែវ សារ៉ាត់** ។ ហេតុនេះនៅពេលថតផ្ដិតចេញមក រូបលោក **កែវ សារ៉ាត់** ស្អាតសង្ហាណាស់ នរណាឃើញក៏ស្រលាញ់ដែរ ។



លោក កែវ សារ៉ាត់

លុះអ្នកម្នាងនិងលោក **កែវ សារ៉ាត់** ថតរួច ហើយបំរុងយកចម្រៀងទាំងនោះប្រគល់ឱ្យលោក **ថាច់ សួន** ថតអាត់ជាកាសែតដើម្បីចែកចាយបោះដុំលក់លើទីផ្សារ ស្រាប់តែដំណឹងនេះបានលេចឮដល់លោក **សែម សុវណ្ណដេត** និងអ្នកស្រី **ឡុង ស៊ីដា** ជាភរិយា ។ភ្លាមនោះអតីតគូស្វាមីភរិយាទាំងពីរក៏មកជួបអ្នកម្នាងហើយសុំទិញសិទ្ធិយកបទទាំងនោះទៅថតលក់ផ្ដាច់មុខតែម្ដង ។ ពេលនោះលោក **សែម សុវណ្ណដេត** បានឱ្យតម្លៃ **៥000** ដុល្លារអាមេរិចសំរាប់ចម្រៀងលោក **កែវ សារ៉ាត់** ៥ បទនោះ ។ ចំណែកចម្រៀង៥បទរបស់អ្នកម្នាង លោក **សែម សុវណ្ណដេត** មិនបានយកទេ ព្រោះអ្នកស្រី **ឡុង ស៊ីដា** ចង់ច្រៀងបញ្ចូលក្នុងកាសែតនោះវិញដើម្បីផ្សព្វផ្សាយសម្លេងឱ្យល្បីជាមួយលោក **កែវ សារ៉ាត់** ។ ពេលនោះអ្នកម្នាងក៏បានលក់សិទ្ធិបទទាំងនោះទៅលោក **សែម សុវណ្ណដេត** ។ ពេលនោះលោក **សែម សុវណ្ណដេត** បានយកបទចម្រៀងទាំងនោះទៅអាត់ជាកាសែតរហូតដល់៥ម៉ឺនកាសែត(Tape) រួចបោះដុំលក់ក្នុងមួយកាសែត **៣ ដុល្លារកន្លះ** (៣.៥ដុល្លារ) ។ ចំណែកអ្នកលក់រាយ គេលក់ ៥ ដល្លារក្នុង១កាសែត ។ លុះពេលរដូវចូលឆ្នាំ គេបានដាក់កាសែតទាំងនោះលក់ស្រាប់តែកាសែតរបស់លោក **កែវ សារ៉ាត់** លក់ដាច់គ្មានសល់មួយឡើយ ។ បងប្អូនខ្មែរទាំងឡាយស្ទើរតែគ្រប់រដ្ឋនៅអាមេរិចសុទ្ធទិញកាសែតទាំងនោះគ្រប់ៗគ្នា ។ ដោយឃើញពីលទ្ធផលនេះទាំងអ្នកលក់ដុំនិងអ្នកលក់រាយលោតហក់អរសប្បាយរីករាយក្រៃលែងព្រោះពួកគេបានទទួលប្រាក់ចំណេញកប់ក្ដោងទាំងអស់គ្នា ។ ប៉ុន្តែចំពោះលោក **កែវ សារ៉ាត់** ពេលនោះថត១បទបានតែ **១00** ដុល្លារប៉ុណ្ណោះ ។ ដូច្នេះ៥បទនេះ លោកបានទទួល **៥00** ដុល្លារពីអ្នកម្នាង **សៀង ឌី** តែអ្វីដែលបានលើសពីប្រាក់ **៥00** ដុល្លារអាមេរិចនោះ គឺកេរ្តិ៍ឈ្មោះរបស់លោកដែលត្រូវបានគេស្គាល់យ៉ាងទូលំទូលាយនិងល្បីល្បាញយ៉ាងខ្លាំង ។



លោក សែម អ្នកនាំយកលោក កែវ សារ៉ាត់ មកជួបអ្នកម្នាង និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ចរិយា

លោក ថាច់ សួន និងលោក ហាំង ថៅ (តួកុនខ្មែរល្បីជាប់អន្តរជាតិ)



# ក្រដាសផ្សាយពាណិជ្ជកម្មកាសែត "ដួងនេត្រា" ឆ្នាំ ១៩៨៧



រូបថតលោក កែវ សារ៉ាត់ ដែលអ្នកម្នាង សៀង ឌី តុបតែងឱ្យ




អ្នកម្នាង **សៀង ឌី** មានប្រសាសន៍ថា ពេលនោះតាមរយៈកាសែត"**ជួននេត្រា**" វ៉ុលទី ១ នោះ ក្រៅពីមហាជនចូលចិត្តសម្លេងរបស់លោក គឺមានស្រីៗជាច្រើនទាំងនៅ **ឡុងប៊ិច** និងនៅរដ្ឋផ្សេងៗបានជិះយន្តហោះស្កាត់មករកលោក **កែវ សារ៉ាត់** គ្រប់ៗគ្នាព្រោះពួកគេសុទ្ធតែលង់ស្នេហ៍លោក **កែវ សារ៉ាត់** តាមរយៈសម្លេងដ៏ពិរោះនិងរូប

របស់គាត់ធ្វើឱ្យអ្នកស្រី **ចន្ធូ** ប្រពន្ធរបស់លោករករឿងលោកយ៉ាងខ្លាំង ។

ក្រោយមក អ្នកម្នាងបានផ្លាស់ចេញពីរដ្ឋ **កាលីហ្វ័រញ៉ា** (California) ទៅរស់នៅទីក្រុងNew York វិញរហូតដល់ឆ្នាំ **១៩៨៩**ទើបអ្នកម្នាងត្រលប់មករស់នៅទីក្រុង **ឡុងប៊ិច** នៃរដ្ឋនេះជាថ្មី ។លុះពេលត្រលប់មកវិញ ហើយនឹកឃើញពីភាពជោគជ័យនៃកាសែត"**ដួងនេត្រា**"នោះ អ្នកម្នាងនិងព្រះអង្គម្ចាស់ **ចរិយា** ជាស្វាមីក៏ផ្តួចផ្តើមគំនិតផលិតចម្រៀងជាមួយលោក **កែវ សារ៉ាត់** ម្តងទៀត ។ ហើយសូមបញ្ជាក់ផងដែរថា មកដល់ឆ្នាំនោះ គ្រួសារលោក**កែវ សារ៉ាត់**ក៏បានផ្លាស់ពី **ស្តុកតុន** មករស់នៅទីក្រុង **ឡុងប៊ិច** ផងដែរ ហើយផ្ទះលោក **កែវ សារ៉ាត់** នៅមិនឆ្ងាយពីផ្ទះអ្នកម្នាងទេ ។

**លោក កែវ សារ៉ាត់ និងអ្នកស្រី ចន្ធូ (ភរិយា**



ចំពោះបំណងនៃការថតចម្រៀងវ៉ុលថ្មីនេះ អ្នកម្នាងនិងស្វាមីបានជំនុំគ្នាជ្រើសរើសចម្រៀងជំនាន់មុន ៥ បទទៀតសំរាប់ឱ្យលោក **កែវ សារ៉ាត់** ច្រៀង ។ ក្នុងនោះរួមបទពិរោះៗដូចជា

១- **ភ្លើងលោកិយឆួល** បទដើមលោក **ស៊ីនគ្រី**

២- **រំដួលសុរិន** បទដើមលោក **ស៊ីន ស៊ីសាមុត**

៣- **បុប្ផារីកមាត់បង្អួច** បទដើមលោក **ស៊ីន ស៊ីសាមុត**

៤- **ស្លឹកឈើចាកមែក** បទដើមលោក **ស៊ីន ស៊ីសាមុត**

៥- **ផ្កាកុលាបស** បទដើមលោក **ស៊ីន ស៊ីសាមុត**

ចំណែកអ្នកម្នាងក៏បានជ្រើសរើសចម្រៀងចាស់ៗចំនួន ៥ បទសំរាប់ថតបញ្ចូលក្នុងកាសែតវ៉ុលទី២នេះជាមួយលោក **កែវ សារ៉ាត់** ដែរ ។ ដែលក្នុងនោះរួមមានបទ ៈ

១- **ព្រោះតែស្រលាញ់** បទដើមរបស់អ្នកម្នាង

២- **ចម្រៀងអស់សង្ឃឹម** បទដើមរបស់អ្នកម្នាង

៣- **ក្រមុំកែបខ្ញិសថនិព** បទដើមរបស់អ្នកម្នាង

៤- **សម្រស់ខេត្តមណ្ឌលគិរី** បទដើមរបស់អ្នកម្នាង

៥- **ចរិយា** បទដើមរបស់អ្នកម្នាង

លុះជ្រើសរើសចម្រៀងរួចរាល់ហើយ ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** ស្វាមីអ្នកម្នាងក៏ចាត់ចែងសម្រួលថតបទភ្លេងជាបន្តបន្ទាប់ដើម្បីទុកឱ្យអ្នកម្នាង និង លោក **កែវ សារ៉ាត់** ថតបញ្ចូល ក៏ប៉ុន្តែលើកនេះការច្រៀងថតត្រូវជួបឧបសគ្គជានិច្ចគឺមិនស្រួលដូចលើកមុនឡើយតែឧបសគ្គនោះមិនមែនមកពីអ្នកម្នាងទេគឺមកពីលោក**កែវ សារ៉ាត់** ។

អ្នកម្នាងមានប្រសាសន៍ថា កាលថតលើកមុន លោក **កែវ សារ៉ាត់** ច្រៀងបាន

ពិរោះហើយមិនសូវខុសឡើយ ហើយថតតែប៉ុន្មានថ្ងៃប៉ុណ្ណោះរួចរាល់តែម្ដង ប៉ុន្ដែលើកនេះ សម្លេងលោក **កែវ សារ៉ាត់** មិនសូវល្អ ហើយសុខភាពលោកហាក់ទ្រុឌទ្រោមមែនទែន ។ ជួនកាលមួយអាទិត្យទើបអាចថតបាន១បទ ។ហើយចំពោះការច្រៀងនេះទៀតសោត ពេលខ្លះខណៈកំពុងច្រៀងបានល្អហើយនោះ ស្រាប់តែគាត់ចាប់ផ្ដើមបែកញើសជោគខ្លួន និងទប់ខ្លួនស្ទើរមិននឹង ។ ហើយជួនកាលទើបតែច្រៀងបានបន្ដិច ស្រាប់តែគាត់សុំត្រលប់ទៅផ្ទះវិញ ធ្វើឱ្យការថតត្រូវអាក់ខានជាញឹកញាប់ ។

ឃើញអាការៈប្លែកដូច្នេះ អ្នកម្នាងក៏សួរគាត់ថា :

-តើសារ៉ាត់ឯងមានបញ្ហាអីក្នុងខ្លួនឬបានជាច្រៀងមិនសូវត្រូវ ? ហើយទឹកមុខមិនសូវល្អបែបនេះ ?

ពេលនោះគាត់ប្រាប់មកអ្នកម្នាងវិញថា :

-ខ្ញុំដេកមិនសូវបាន ទើបចេះតែធីងធោងបែបនេះ ?

ដោយមិនអស់ចិត្ត អ្នកម្នាងសួរបញ្ជាក់ :

-សារ៉ាត់ឯងដើរលេងយប់ច្រើនពេកទេដឹង ?

លោក កែវ សារ៉ាត់ នៅតែឆ្លើយដដែល :

-ទេ ! ការពិតមកពីខ្ញុំមិនសូវដេកលក់ស្រួល

ឮគាត់ប្រាប់ដូច្នេះ អ្នកម្នាងក៏មិនបានសួរដេញដោលអ្វីច្រើនទៀតដែរ ។ ហើយការថតក៏ចេះតែពន្យាពេលកាន់តែយូរទៅៗមិនអាចថតចប់សោះ ប៉ុន្ដែចំពោះរឿងនេះ អ្នកម្នាងមានប្រសាសន៍ថា លោក **កែវ សារ៉ាត់** មានជំងឺក្នុងខ្លួនយ៉ាងធ្ងន់ តែគាត់មិនប្រាប់អ្នកម្នាងឱ្យដឹង ទើបធ្វើឱ្យអ្នកម្នាងយល់ខុសចំពោះគាត់ ព្រោះជួនកាលអ្នកម្នាងសឹងតែដេញគាត់ចេញពីបន្ទប់ថតព្រោះគាត់ច្រៀងខុសច្រើនពេក ។ លុះដំណាក់កាលចុងក្រោយ

ឆ្លងចូលមកដល់ឆ្នាំ **១៩៩១** ពេលច្រៀងលែងកើត ទើបអ្នកម្នាងដឹងគាត់ឈឺធ្ងន់ ហើយពេលនោះអ្នកម្នាងក៏បានទៅសួរសុខទុក្ខគាត់ដល់ផ្ទះ ។ ខណៈនោះគាត់នៅអាចក្រោកដើរបានខ្លះតែសុខភាពទ្រុឌទ្រោមមែនទែន ។ ជាមួយគ្នានោះដែរ ដោយលែងមានកម្លាំងស្រែកច្រៀងនិងធ្វើដំណើរទៅណាមកណាបាន គាត់បានខ្ចីម៉ាស៊ីនថតសម្លេងដែលអ្នកម្នាងទិញសំរាប់ឱ្យស្វាមីថតភ្លេងនោះមកស្តាប់នៅផ្ទះតែម្តងព្រោះគាត់ចង់ស្តាប់ចម្រៀងចុងក្រោយពីរ-បីបទដែលបានថតរួចរាល់នោះ ដូចជាបទ"**ភ្លើងលោកិយឆួល**"នងបទ"**ស្លឹកឈើចាកមែក**" ជាដើម ។ អ្នកម្នាងបានប្រគល់ម៉ាស៊ីននោះឱ្យគាត់ស្តាប់ដោយសេចក្តីអាណិតអាសូរ តែក៏មិននឹកស្មានថាលោក **កែវ សារ៉ាត់** នឹងបាត់បង់ជីវិតយ៉ាងលឿនក្នុងវេលានោះដែរ ។ លុះប៉ុន្មានខែក្រោយមក ក្នុងឆ្នាំ **១៩៩១** សម្តេចឪបានកោះហៅអ្នកម្នាងនិងស្វាមីទៅជួបនៅទីក្រុង New York ។ ពេលនោះអ្នកម្នាងក៏បានរៀបចំខ្លួនដើម្បីចេញទៅជាមួយស្វាមី ទោះបីចម្រៀងវ៉ុលទី២នេះមិនទាន់បានថតចប់រួចរាល់ក៏ដោយ ព្រោះការកោះហៅរបស់ សម្តេចឪ លើកនេះជាការងារប្រទេសជាតិ ព្រោះឆ្នាំ **១៩៩១** នោះ ក្រុមបក្សទាំង៣របស់កម្ពុជាកំពុងរៀបចំចរចា"**សន្និសីទទីក្រុងប៉ារីស**" តែមុននឹងចេញទៅ អ្នកម្នាងបានផ្តែផ្តាំក្រុមភ្លេង និង តន្ត្រីករនានាដែលអ្នកម្នាងស្គាល់ទាំងប៉ុន្មានឱ្យជួយមើលលោក **កែវ សារ៉ាត់** ផង ព្រោះជំងឺនោះមិនសូវស្រួលទេ ប៉ុន្តែគួរឱ្យអនិច្ចា ប៉ុន្មានថ្ងៃក្រោយមក នៅវេលាព្រឹកពេលអ្នកម្នាងនិងស្វាមីឡើងយន្តហោះពួកក្រុមអ្នកភ្លេងដែលអ្នកម្នាងបានផ្តែផ្តាំនោះបានចុចទូរសព្ទមកប្រាប់អ្នកម្នាងថាលោក **កែវ សារ៉ាត់** បានទទួលអនិច្ចកម្មទៅហើយ ។ គ្រាន់តែឮដំណឹងដ៏ក្រៀមក្រំនេះ អ្នកម្នាងនិងព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយា** រន្ធត់ចិត្តយ៉ាងខ្លាំងដោយនឹកស្តាយស្រណោះចំពោះអ្នកចម្រៀងដ៏ស្លូតបូតនិងមានសម្លេងពិរោះពិបាករកបានរូបនេះ ។ អានុស្សាវរីយ៍

ទាំងប៉ុន្មានហាក់ផុសឡើងវិញទាំងអស់ក្រោយពេលមរណភាពរបស់គាត់ ។ ថ្វីបើជាអ្នកចម្រៀងស្រករក្រោយតែលោក**កែវ សារ៉ាត់**ជាមនុស្សមានទេពកោសល្យច្រើនណាស់ គឺក្រៅពីជាអ្នកចម្រៀងសម័យ មានសម្លេងពិរោះនោះ គាត់ធ្លាប់មានប្រាប់អ្នកម្នាងថា មុនពេលមកដល់សហរដ្ឋអាមេរិចនិងក្លាយជាអ្នកចម្រៀង គឺគាត់ធ្លាប់ធ្វើជាអ្នកច្រៀងល្ខោនបាសាក់កាលដែលគាត់ភៀសខ្លួនទៅរស់នៅជំរុំខាវអ៊ីដាងនិងជំរុំស្រះកែវជាយដែនខ្មែរ-ថៃក្នុងអំឡុងដើមទ.វឆ្នាំ **១៩៨០** ។ ហើយពេលគាត់និយាយប្រាប់នោះ គាត់ថែមទាំងសម្តែងកាយវិការជាតួល្ខោនដោយយកក្រមាចងចង្កេះបង្ហាញអ្នកម្នាង សម្តេចព្រះរាម **បុប្ផាទេវី** និងព្រះអង្គម្ចាស់ **ចរិយា** ទស្សនាទៀតផង ធ្វើឱ្យអ្នកម្នាងនិងអ្នកមើលនោះផ្ទុះសំណើចនូវកាយវិការកំប្លុកកំប្លែងរបស់គាត់គ្រប់ៗគ្នា ក៏ប៉ុន្តែពេលនេះ ជារឿងមួយស្មានមិនដល់ មច្ចុរាជបានផ្តាច់យកសង្ខារគាត់ទៅទាំងវ័យក្មេង ដែលមានអាយុទើបតែ **៣៦** ឆ្នាំនៅឡើយ ។

**ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ចរិយា ជាមួយលោក ម៉ា ឡៅពី និងភរិយា នៅស្តុកតុន ឆ្នាំ ១៩៨៦**



ម៉ា ឡៅពី

ត្រង់ចំណុចនេះ ខ្ញុំបាទសូមបញ្ជាក់ជូនមិត្តអ្នកអានឱ្យបានជ្រាបថា កាលនៅក្នុងសៀវភៅ "**មាសស្រោបនគរ**" ភាគទី **៣** ដែលនិយាយអំពីប្រវត្តិលោក **កែវ សារ៉ាត់** ខ្ញុំមិនទាន់បានសរសេរអំពីឆ្នាំកំណើតរបស់គាត់ឡើយ ព្រោះឯកសារដែលខ្ញុំទទួលបានគេក៏មិនបញ្ជាក់ពីឆ្នាំកំណើតរបស់គាត់ដែរដោយប្រាប់តែស្រុកកំណើតគាត់ប៉ុណ្ណោះគឺជាអ្នកខេត្តបាត់ដំបង ប៉ុន្តែកាលពីប៉ុន្មានខែមុននេះគឺកាលពីថ្ងៃទី **២៣** ខែ**វិច្ឆិកា** ឆ្នាំ**២០១០** (១ថ្ងៃក្រោយព្រឹត្តិការណ៍ជាន់គ្នាស្លាប់លើស្ពានកោះពេជ្រ) ខ្ញុំបានជួបអ្នកស្រី **ចន្ធូ** ភរិយារបស់លោក **កែវ សារ៉ាត់** ដែលធ្វើដំណើរពីអាមេរិចមកលេងបងប្អូននិងបុណ្យអុំទូក ពេលនោះខ្ញុំបានជួបសម្ភាសន៍គាត់ជិតមួយម៉ោងដើម្បីយកមកចាក់ផ្សាយក្នុងនារី "**រឿងរ៉ាវពិត ជីវិតពិត**" នៃវិទ្យុទន្លេ FM 102.5 Mhz ។ ហើយខណៈនោះ អ្នកស្រី **ចន្ធូ** បានរៀបរាប់ប្រាប់ខ្ញុំជាច្រើន ក្នុងនោះគាត់ក៏បានប្រាប់ផងដែរថា លោក **កែវ សារ៉ាត់** ស្វាមីអ្នកស្រី កើតនៅក្នុងអំឡុងឆ្នាំ **១៩៥៦** ត្រូវនឹង **ឆ្នាំវក** ។ ដូច្នេះពីឆ្នាំ **១៩៥៦** មកដល់ឆ្នាំ **១៩៩១** គឺមានអាយុ **៣៥** ឆ្នាំ (រាប់តាមឆ្នាំសាកល) តែបើរាប់តាមឆ្នាំខ្មែរគឺអាយុ **៣៦** ឆ្នាំ ។

ដោយឡែក ចំពោះអ្នកម្នាង ក្រោយពេលលោក **កែវ សារ៉ាត់** ស្លាប់ជាច្រើនឆ្នាំ លោក **ឆាន ឆូ** ម្ចាស់ផលិតកម្ម **មយូរ៉ា** នៅអាមេរិចដែលត្រូវជាបងធម៌លោក **កែវ សារ៉ាត់** និងដែលជាអ្នកនិពន្ធបទចម្រៀងឱ្យលោក **កែវ សារ៉ាត់** ច្រៀងបានពឹងឱ្យលោក **មិញ សុធីវណ្ណ** ទិញបទ "**ភ្លើងលោកិយឆួល**" ពីអ្នកម្នាងដែលបទនេះអ្នកម្នាងបានឱ្យលោក **កែវ សារ៉ាត់** ច្រៀងក្នុងកាសែត វ៉ុលទី២ ដែលថតមិនទាន់ចប់គ្រប់បទនោះ ។ ពេលនោះលោក **ឆាន ឆូ** បានឱ្យតម្លៃ **២០០០ ដុល្លារអាមេរិច** សំរាប់ចម្រៀងមួយបទនោះ ។ ដោយគិតថា មិនចង់កប់បទចុងក្រោយរបស់លោក **កែវ សា**

**រ៉ាត់** អ្នកម្នាងក៏លក់បទនោះឱ្យលោក **ឆាន ឆួ** តាមតម្លៃនោះ ។ ប៉ុន្តែអ្នកម្នាងមិនត្រឹមតែប្រគល់បទ"**ភ្លើងលោកិយឆួល**" ប៉ុណ្ណោះទេ គឺប្រគល់បទផ្សេងៗទៀតដែលថតរួចរាល់ដូចជា "**ស្លឹកឈើចាកមែក**" ... ជាដើមឱ្យទាំងអស់តែម្តងដើម្បីឱ្យចម្រៀងនោះចេញផ្សាយលើទីផ្សារ ហើយឱ្យប្រជាពលរដ្ឋខ្មែរស្តាប់ឮទាំងអស់គ្នា ។ រីឯចំណែកលោក **ឆាន ឆួ** វិញ ពេលនោះក៏បានផ្ញើរូបថតមួយសន្លឹកដែលលោកថតជាមួយលោក **កែវ សារ៉ាត់** កាលឆ្នាំ **១៩៨៧** ជូនអ្នកម្នាងដើម្បីទុកជាអានុស្សាវរីយ៍ផងដែរ ។

មកដល់ថ្ងៃនេះ ទោះបីលោក **កែវ សារ៉ាត់** បានស្លាប់ទៅអស់រយៈពេល **២០** ឆ្នាំក៏ពិតមែន ប៉ុន្តែពេលឃើញរូបថតលោក**កែវ សារ៉ាត់**ធ្វើឱ្យអានុស្សាវរីយ៍ពីអតីតកាលទាំងឡាយបានផុសឡើងវិញទាំងអស់ហើយតែងតែដក់ជាប់ក្នុងដួងចិត្តអ្នកម្នាងជានិច្ច ។

**លោក កែវ សារ៉ាត់ និងលោក ឆាន ឆួ (ថតឆ្នាំ ១៩៨៧)**



អ្នកម្នាង សៀង ឌី ជាមួយស្វាមី ជាមួយលោក សែម និងសម្តេចឪនៅទីក្រុង New York ឆ្នាំ ១៩៩១



លោក សែម

## អ្នកម្នាង និងសម្ដេចម៉ែ (New York ឆ្នាំ ១៩៩២)



### ‿ជីវិតបច្ចុប្បន្ន

លុះរហូតមកដល់ឆ្នាំ **១៩៩៤** ក្រោយពេលសម្ដេចឪ យាងចូលកម្ពុជា និងក្រោយពេលកម្ពុជាវិលមកកាន់របប **"រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ"** វិញ ទើបអ្នកម្នាងនិងស្វាមីបានវិលមករស់នៅកម្ពុជារហូតមកដល់បច្ចុប្បន្ន ។ ប៉ុន្ដែកាលមុននេះបន្ដិច គឺនៅឆ្នាំ **១៩៩៣** អ្នកម្នាងក៏បានមកលេងស្រុកខ្មែរចំនួន **៣** ខែម្ដងរួចហើយដែរ ប៉ុន្ដែមិនទាន់មករស់នៅជាផ្លូវការទេ គឺរហូតដល់តែមកដល់ឆ្នាំ **១៩៩៤** ទើបវិលមកសាងជីវិតជាថ្មី

នៅមាតុភូមិកំណើតពិតប្រាកដ ។

នៅកម្ពុជា អ្នកម្ទាងបានបង្ហាញស្នាដៃជាអ្នកច្នៃម៉ូដជាច្រើន ។ ក្នុងនោះ នៅអំឡុងឆ្នាំ**១៩៩៦** ខណៈកម្ពុជាបង្កើតពិធីប្រលងបវរកញ្ញានៅសាលចតុមុខ **សម្តេចព្រះរាមបុប្ផាទេវី** បានសព្វព្រះរាជហឫទ័យឱ្យអ្នកម្ទាងច្នៃម៉ូដឱ្យអ្នកបង្ហាញម៉ូដពីអ្នកជាប់លេខ ១ ដល់លេខ ១០ ។ ហើយនៅក្នុងឆ្នាំ **១៩៩៧** អ្នកម្ទាងបានច្នៃម៉ូដសម្លៀកបំពាក់អ្នកបំរើលើយន្តហោះក្នុងពិធីប្រកួតប្រជែងដ៏ធំមួយដែលមាន **១៨**ហាងកាត់ខោអាវធំៗមកពីប្រទេសផ្សេងៗបានចូលរួម ក្នុងនោះរួមមានប្រទេសបារាំង សឹង្ហបុរី និងម៉ាឡេស៊ី ...។ ពេលនោះ ស្នាដៃអ្នកម្ទាងបានទទួលចំណាត់ថ្នាក់លេខ **១** ដោយប្រកាសនៅសណ្ឋាគារកាំបូឌីយ៉ាណា (Cambodiana) ។




ទាក់ទងនឹងបុត្រាវិញ អ្នកម្ទាងមានប្រសាសន៍ថា បុត្រាតែមួយនោះមានឈ្មោះថា**ស៊ីសុវត្ថិ ចរិឌី** សព្វថ្ងៃរស់នៅប្រទេសអង់គ្លេស និងមានភរិយារួចហើយជាជនជាតិអង់គ្លេស ឈ្មោះ **ស៊ីសុវត្ថិ ភាទ្រីណា** ។ មកដល់ពេលនេះ បុត្រានិងភរិយាជនជាតិអង់គ្លេសនោះបានបង្កើតចៅឱ្យអ្នកម្ទាងបានពីរនាក់ហើយ (ស្រីទាំងពីរ) ។

១- ចៅស្រីទី១ស៊ីសុវត្ថិ រតនៈទេវី

២- ចៅស្រីទី២ ស៊ីសុវត្ថិ កេតនាដេវី ។



រហូតមកដល់សព្វថ្ងៃ ថ្វីបើអ្នកម្នាងមានអាយុជាង **៦០** ឆ្នាំហួយទៅហើយក្តី តែអ្នកម្នាងនៅតែស្រលាញ់វិស័យសិល្បៈតន្ត្រីដូចកាលដែលអ្នកម្នាងធ្លាប់ប្រឡូកនៅជំនាន់លោក **ស៊ីន ស៊ីសាមុត** ដដែល ។ ជាញឹកញាប់ ប្រជាពលរដ្ឋខ្មែរជំនាន់នេះបូករួមទាំងរូបខ្ញុំផងតែងតែបានឃើញរូបអ្នកម្នាងផ្តល់កត្តិយសចូលរួមនៅក្នុងកម្មវិធីសិល្បៈផ្សេងៗតាមរយៈកញ្ចក់ទូរទស្សន៍នានានៅស្រុកខ្មែរ ។ ជាមួយគ្នានោះ អ្នកម្នាងក៏បានបង្កើតកម្មវិធីលិស្បៈផ្សេងៗទៀតដើម្បីបណ្តុះបណ្តាលកុលបុត្រ កុលធីតាខ្មែរជំនាន់នេះឱ្យចូលរួមលើកស្ទួយសិល្បៈវប្បធមិជាតិឱ្យបានរុងរឿងដូចជំនាន់អ្នកម្នាងផងដែរ ដូចជាបង្កើតកម្មវិធី "**សៀង ឌី** Show" នៅទូរទស្សន៍ប៉ុស្តិ៍លេខ ៩ ជាដើម ។ ហើយតាមរយៈកម្មវិធីនេះ អ្នកម្នាងបានអញ្ជើញមិត្តភក្តិសិល្បករនិងសិល្បការិនីនានាមកសម្ភាសន៍ដើម្បីរំឭកឡើងវិញអំពីអានុស្សាវរីយ៍ជាច្រើនដែលបានកន្លងផុតទៅ ។ ក្នុងនោះរួមមានដូចជាអ្នកស្រី **ឌី សាវ៉េត** អ្នកស្រី **សេង បុទុម** អ្នកស្រី **វីរៈតារា** និងអ្នកស្រី **ឈួន ម៉ាឡៃ** ជាដើម ។

**អ្នកម្នាងសៀង ឌី និងអ្នកស្រី ឈួន ម៉ាឡៃ**





អ្នកម្នាង សៀង ឌី អ្នកស្រី វីរៈតារា និងអ្នកស្រី សេង បុទុម

ក្រៅពីនេះអ្នកម្នាងក៏ឆ្លៀតពេលថតបទចម្រៀងចាស់ៗរបស់អ្នកម្នាងឡើងវិញផង ដែរដោយមានក្មួយអ្នកម្នាងឈ្មោះ **រ៉េតធី ជួណា** កូនប្រុសរបស់អ្នកស្រី **សៀង វ៉ាន់ធី** និងលោក **មិញ សុធីវណ្ណ** ជាអ្នកសម្រួលតន្ត្រី ។ ជាមួយគ្នានោះក្រៅពីច្រៀងអ្នកម្នាងក៏បានថតចម្រៀងកាយវិការទុកជាអានុស្សាវរីយ៍មួយចំនួនផងដែរ ។ ដែលទាំងនេះបញ្ជាក់ឱ្យយើងឃើញថា សំរាប់អ្នកម្នាង **សៀង ឌី** សិល្បៈគឺជាផ្នែកមួយនៃជីវិតរបស់អ្នកម្នាងដែលមិនអាចកាត់ដាច់ពីគ្នាបានឡើយ ។





អ្នកម្នាងក្រុមគ្រួសារ នៅក្រុងព្រះសីហនុ ឆ្នាំ១៩៩៣

នីកូ តាតា អ្នកម្នាង_សាវិនណារ៉ី_សៀង ម៉ាន់ធី_ជូណា

អ្នកម្នាងនិងបវរកញ្ញាកម្ពុជាដែលអ្នកម្នាងច្នៃម៉ូដសំរាប់ស្លៀកពាក់ប្រលង



មកដល់ថ្ងៃនេះ ទោះបីពេលវេលាកន្លងទៅអស់រយៈពេលជាងកន្លងស.វទៅហើយក្ដី ប៉ុន្តែមរតកតូរតន្ត្រីមាសរបស់សិល្បករ សិល្បការនីជំនាន់ដើមដែលបន្សល់ទុករាប់រយពាន់បទនោះនៅតែពិរោះក្នុងដួងចិត្តពលរដ្ឋខ្មែរជាអមតៈ ទោះបីជំនាន់នេះមានសិល្បករ សិល្បការនីក្មេងៗកំពុងប្រជែងគ្នាដើម្បីកេរ្តិ៍ឈ្មោះរកមេឃដាក់គ្មានក៏ដោយ ។ ពលរដ្ឋខ្មែរទូទៅនៅតែស្រលាញ់សម្លេងលោក **ស៊ីន ស៊ីសាមុត** លោក **ស៊ុះ ម៉ាត់** លោក **មាស សាម៉ន** ...អ្នកស្រី **ហួយ មាស** អ្នកស្រី **រស់ សេរីសុទ្ធា** អ្នកស្រី **ប៉ែន រ៉ន** និងអ្នកស្រី **ម៉ៅ សារ៉េត** ... ។ល ។និង ។ល ។ រៀមច្បងបានលាចាកផែនដីនេះពិត តែបទចម្រៀងមាសទាំងនោះនៅរស់ជានិច្ច ខុសពីជំនាន់នេះ ដែលម្ចាស់សម្លេងនៅរស់ តែបទចម្រៀងស្លាប់បាត់មុនម្ចាស់អស់ទៅហើយ ។

ដោយមើលឃើញចំណុចនេះ ទើបអ្នកម្នាងមានប្រសាសន៍ផ្ដាំផ្ញើទៅសិល្បករ និងសិល្បការនីជំនាន់នេះថា គួរតែកសាងស្នាដៃចេញពីខួរក្បាលខ្លួនឯងឱ្យបានច្រើនទើបបទចម្រៀងទាំងនោះរស់បានយូរអង្វែង មិនគួរយកបទភ្លេងបរទេសមកកែបំភ្លៃធ្វើជារបស់ខ្លួនទេ ព្រោះវានាំឱ្យអព្ភ័ឱនមុខមាត់ដល់ជាតិសាសន៍យើង ។ អ្វីដែលបានមកពីកាតលួចបន្លំគេមិនមែនជារបស់ថ្លៃថ្នូរទេ ។ នេះជាដំបូន្មានដ៏ល្អដែលកូនខ្មែរជំនាន់នេះ ជាពិសេសក្រុមសិល្បករ សិល្បការនីនានាគួរតែចងចាំដើម្បីអភិវឌ្ឍន៍សមត្ថភាពខ្លួនទៅថ្ងៃអនាគតឱ្យមានជោគជ័យដូចជំនាន់អ្នកម្នាងដែលយើងហៅថាជា "**មាសស្រោបនគរ**" នោះ ។

# ចប់





# ឆ្លងចិត្តប្រុស

បទភ្លេង ទំនុកច្រៀង ច្រៀងដោយ

ពៅ ស៊ីផូ សៀង ឌី

I. ក្នុងសួនច្បារផ្កាស្រស់ ពួកកម្លោះត្រេកចង់បាន

ខ្លះខំកែប្រាណ ព្រោះតែចង់បានបុប្ផាស្រស់ ។

II. ប្រុសចិត្តសែនសាវ៉ា ក្តីប្រាថ្នាពុំចេះអស់

អួតខ្លួនកម្លោះ ឱ្យស្រីជឿខុសលើក្តីប្រាថ្នា ។

R. ខ្លាចហើយសូមកុំជួបទៀត ដប់ទាំងដប់ចិត្តប្រុសដូចគ្នា

ផ្អែមណាស់វាចា ដល់អស់ស្នេហាកដោះដៃ ។

III. ខ្ញុំខ្លាចហើយស្នេហា ខ្លាចឱវាទក្អឹងរ៉ៃ

កម្លោះសម័យ តែងចេះសំដីបោកស្រីឱ្យស្មគ្រ័ ។

# កុលាបអូនស្នេហ៍

**បទភ្លេង ទំនុកច្រៀង ច្រៀងដោយ**

**ពៅ ស៊ីផូ សៀង ឌី**

I. កុលាបស្រស់ម្លេះណា ឱ្យចិន្តាប៉ងស្នេហ៍ រាល់ថ្ងៃយល់តែភក្រ្ត
ជំពាក់ចិត្តស្នេហ៍មេត្រី ផ្កាក្រអូបម្លេះណា មេត្តាវាចាប្រាប់មកណាថ្លៃ
ចិត្តអូនគួចមេតី ភក្តីស្នេហ៍ស្នង ។

II. នៅរាល់ពេលរាត្រី អូនស្រមៃឃើញភក្ត្រ ស្រមៃឃើញរូបអ្នក រួមរក្ស
ចិត្តស្នេហ៍សាសង អូនរងចាំគ្រប់គ្រា រៀមរ៉ាមេត្តាអាសូរស្រីផង
ជាតិនេះមានបំណងប៉ុនប៉ងស្នេហ៍មួយ ។

R. កុលាបស្នេហ៍អូនថែរាល់ថ្ងៃ ចិត្តអូនស្មោះឥតប្រែពីរបី ប្រុសថ្លៃកុំព្រួយ
ស្នេហ៍អូនពិតគឺតែបងមួយ អូនប្រាថ្នាជាតិនេះជាតិក្រោយជួបតែរៀមរ៉ា។

III. ឃើញភក្ត្របងញញឹម អូនសង្ឃឹមក្នុងចិត្ត ថាបងស្នេហ៍អូនពិត
ឥតប្រែពីអូនឡើយណា ជាតិនេះមានរស្មី ដោយសារចិត្តប្រុសមានក្តី
មេត្តា ជាតិនេះមានខ្លឹមសារក្នុងស្នេហ៍សុខសាន្ត ។

IV. កុលាបមានអូនអើយ ឆ្លើយប្រាប់មកអូនថា បងពិតជាមេត្តា
ស្នេហាស្មោះអស់ពីប្រាណ យើងមានចិត្តតែមួយឥតរោយដូចផ្កា
គេបោះបង់បាន ស្នេហ៍លុះគ្រាអវសានឥតមានហ្មងឡើយ ។





# ព្រះសុរិយា

| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
|---|---|
| ពៅ ស៊ីផូ | សៀង ឌី |

I. ព្រះសុៗរិយា រះបំភ្លឺលោកាថ្មីៗ

បក្សាបក្សី សប្បាយក្រៃនឹងរស្មីភ្លឺថ្លា

វាយោផាត់ផាយ រសាយក្លិនផ្កា ហ៊ឺ...ហ៊ឺ...

ធ្វើឱ្យដួងចិន្តា អាល័យ តើឱ្យខ្ញុំធ្វើម្តេច នឹងបានៗរស្មីសុរិយា ?...

# ឱ! ផ្កាយបីចម្លែក



បទភ្លេង ទំនុកច្រៀង ប្រជាប្រិយ

ច្រៀងដោយ សៀង ឌី

I. ឱ ! ផ្កាយលើមេឃ ផ្កាយបីចម្លែកគួរឱ្យស្នេហា

ផ្កាយនេះជាផ្កាយរបស់ទេវតា គួរឱ្យស្នេហាក្នុងពេលរាត្រី (២ដង) ។

II. ឱ ! ផ្កាយចំណាប់ អូនឈោងដៃចាប់ ផ្ការសាត់ឆ្ងាយ

អូនសង្ឃឹមផ្កាដូចសង្ឃឹមផ្កាយ ផ្ការសាត់ឆ្ងាយឱ្យអូនវេទនា ។

# គន់មើលផ្កាយ



**បទភ្លេង ទំនុកច្រៀង ប្រជាប្រិយ** **ច្រៀងដោយ សៀវ ឌី**

I. គន់មើលផ្កាយ សព្វសាយនៅលើមេឃា
គន់មើលចន្ទ្រា ចន្ទរស្មីពន្លឺភ្លឺច្បាស់ ។

II. ក្នុងសួនច្បារ ផ្កាក្រអូបសព្វសាយ
នាំឱ្យចិត្តរីករាយ សែនសប្បាយក្នុងពេលរាត្រី ។

# រាំវង់ល្ងាចថ្ងៃសៅរ៍



| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
|---|---|
| ប្រជាប្រិយ | សម សាខន-សៀង ឌី-ឈួន ម៉ាឡៃ |

I. ប្រជុំគ្នារីករាយសប្បាយចិត្ត ចូលរាំឱ្យស្និទ្ធចូលជិតកុំឱ្យហ្មងសៅរ៍
យើងរាំតាមភ្លេង តាមភ្លេងអាធ្រាតយប់ជ្រៅ ពេលល្ងាចថ្ងៃសៅរ៍
ជាថ្ងៃឈប់សំរាកកាយ ។
ហិបពីយ៉ា យ៉ាៗ ហិបពីយ៉ា អាហិបពីយ៉ា យ៉ាៗ អាហិបពីយ៉ា
អាហិបពីយ៉ា អាហិបពីយ៉ា អាហិបពីយ៉ា ៗៗៗ.........

II. ប្រជុំគ្នារីករាយសប្បាយចិត្ត ចូលរាំឱ្យស្និទ្ធចូលជិតកុំឱ្យហ្មងសៅ
យើងរាំតាមភ្លេង តាមភ្លេងអាធ្រាតយប់ជ្រៅ ពេលល្ងាចថ្ងៃសៅរ៍
ជាថ្ងៃឈប់សំរាកកាយ ។
ហិបពីយ៉ា យ៉ាៗ ហិបពីយ៉ា អាហិបពីយ៉ា យ៉ាៗ អាហិបពីយ៉ា
អាហិបពីយ៉ា អាហិបពីយ៉ា អាហិបពីយ៉ា ៗៗៗ.........

# រាំតាមសិល្បករ



បទភ្លេង ទំនុកច្រៀង ប្រជាប្រិយ

ច្រៀងដោយ សៀង ឌី

I. រាំសិល្បករ ចិត្តស្មោះសមកច្រៀងរាំ
លេងតាមលំនាំ យើងច្រៀងរាំតាមសិល្បករ ។
គូនេះរាំសមឬមិនសម ? យើងច្រៀងយើងរាំតាមសិល្បករ ។

II. រាំសិល្បករ ចិត្តស្មោះសមកច្រៀងរាំ
លេងតាមលំនាំ យើងច្រៀងរាំតាមសិល្បករ ។
គូនេះរាំសមឬមិនសម ? យើងច្រៀងយើងរាំតាមសិល្បករ ។




# ឱ! ស្វាយចន្ទី

បទភ្លេង ទំនុកច្រៀង ច្រៀងដោយ

ប្រជាប្រិយ សម សាខន~សៀង ឌី~សូ សាវិនណារ៉ា

I. ឱ ! ស្វាយចន្ទី អ្នកប្រុសបងអើយបែកមែកសាខា (២ដង)

ធ្វើបុណ្យកាលណា ខ្ញុំសូមប្រាថ្នាឱ្យជួបថ្លៃ ។

II. សាច់សសៃនសម អ្នកប្រុសបងអើយកុំអាលដោះដៃ (២ដង)

បើបងចូលស្ដី តាមស៊ីវិល័យប្រពៃណីខ្មែរ (២ដង) ។

III. ឱ ! ស្វាយចន្ទី នារីបែកមែកសាខា (២ដង)

ធ្វើបុណ្យកាលណា ខ្ញុំសូមប្រាថ្នាជួបស្រី (២ដង) ។

IV. សាច់សសៃនសម ក្រមុំអូនអើយកុំអាលមានប្ដី (២ដង)

ចាំបងធ្វើមន្ត្រី បងទិញឡានថ្មីឱ្យស្រីជិះលេង (២ដង) ។

# ចន្ទ័រះពេញ



បទភ្លេង ទំនុកច្រៀង ប្រជាប្រិយ

ច្រៀងដោយ សៀង ឌី

I. ចន្ទ័រះពេញ កុំទោម្តេញអ្វីសោះឡើយ
ពួកយើងនេះហើយស្រលាញ់គ្នាទាន់សាសនា
ពួកយើងរាល់គ្នាមកលេងរាំវង់ ។

R. តែអ្នកនេះរាំសម ! (ប) រាំសមពីកាលណា ?
តែអ្នកនេះប្តីខ្ញុំ (ប) ប្តីអ្នកឯងពីកាលណា ?
អឺ...អឺ...អឺ...អើយ...ហេ...តុង...ហេ...តុង...អើយ...តុងៗ
ហេ...តុង...ហេ...តុង...អើយ...តុងៗ..

# លើកដៃឡើងរាំ





បទភ្លេង ទំនុកច្រៀង ប្រជាប្រិយ

ច្រៀងដោយ សៀង ឌី-ម៉ៅ សារ៉េត

I. លើកដៃឡើងរាំ សមអើយសែនសមពាក់នាឡិកា
ពាក់អាវប៉ោងស្នា សក់អ៊ុតស្លេក្តោប លាបថ្ពាល់ក្រហម
មកលេងរាំវង់ ។

II. លើកដៃឡើងរាំ សមអើយសែនសមពាក់នាឡិកា
ពាក់អាវប៉ោងស្នា សក់អ៊ុតស្លេក្តោប លាបថ្ពាល់ក្រហម
មកលេងរាំវង់ ។






# ព្រោះតែស្រលាញ់

| | |
|---|---|
| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
| យ៉ង់ ឈឿន ហៅ សំនៀងមន្ត្រី | សៀង ឌី |

I. ព្រោះតែស្រលាញ់ បានជាខ្ញាញ់ក្តិចហើយអង្កែល
អង្វរដោយក្តីស្មោះស កម្រដូចចិត្តអូនស្នេហ៍ពិត ។

II. ព្រោះតែអាណិត បានជាចិត្តច្រណែនប្រចណ្ឌហើយហ៊ាន
រំលោភបំពាន ហាក់គ្មានក្រែងចិត្តថ្លៃ ។

R. ឃើញចិត្តឬនៅពៅប្រុសបង បំណងផ្សងនិស្ស័យ
បើធ្វើមិនយល់ដោយអស់អាល័យ សៀវភៅស្នេហ៍
ក្ស័យសង្ខាស្នេហ៍អភព្វ ។

III. ព្រោះតែថាគូ បានជាស៊ូទ្រាំចាំមើលផ្លូវជានិច្ច
បើចង់បំភ្លេច ម្តេចមិនចេញវាចា ។




# សួនកំសត់ខ



**បទភ្លេង ទំនុកច្រៀង** **ច្រៀងដោយ**

**យ៉ង់ ឈឿន ហៅ សំនៀងឫទ្ធី** **សៀង ឌី**

I. ឱ ! ទីឧទ្យានវិមានស្នេហ៍ខ្ញុំ ធម្មជាតិសុខុមជាតន្ត្រីស្រាប់

ពេលណាបានស្ដាប់ ដួងចិត្តរំភើប ព្រឺព្រួចស្មើបខ្លាចមេឃគ្មានភ្លៀង ។

II. ផ្ការីកផ្ការោយចាកត្រួយចាកមែក អំពិលអំពែកជំនួសចង្កៀង

ស្លឹកឈើចាកមែកប្រែជាចម្រៀង បញ្ជិតបញ្ជៀងផ្ដោះផ្ដងស្នេហា ។

R. ឱ ! សួនកំសត់បើបាត់រូបខ្ញុំ ហ៊ឺ...ហ៊ឺ...ដែលធ្លាប់ថែទាំខួបប្រាំងវស្សា

ហា ! ហា ! ខ្ញុំលាអ្នកក្សយព្រោះព្រាត់សង្សារ សូមទុកសួនច្បារ

ជាផ្នូរតទៅ ។

III. ឱ ! ទីកន្លែងយើងតែងជួបគ្នា ឱ ! សួនបុប្ផាធ្លាប់ជ្រកយប់ជ្រៅ

ឱ ! សួនកំសត់ខំឃាត់ខំហៅ ចិត្តចើកល្វង់ខ្លោចចេសចោលខ្ញុំ ។






# ក្រុងកែបឱសថទិព្វ

| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
|---|---|
| យ៉ង់ ឈឿង ហៅ សំនៀងឫទ្ធី | សៀង ឌី |

I. ក្រុងសួគ៌ា ផ្ទៃគង្គាក្រាលដោយពេជ្រ

ឆ្លុះរំលេច ប្រណាំងនឹងរស្មីច័ន្ទ ។

II. ទេពអប្សរ និង កិន្នរឋានសុវណ្ណ

ស្ម័គ្រមកកាន់ ច្រៀងរាំលំអក្រុងកែប ។

R. វិមានអើតពីជំរាលភ្នំ ពពកជុំៗផ្ដុំអង្អែល

ចិត្តស្នេហ៍ស្រើបស្រៀវហាក់ប្រហែល ផ្ដោះហោះហែល

ដែនអាកាសកៃលាសា ។ (ឋានឫភ្នំ កៃឡាស់)

III. កែបក្រអូប ខ្ញុំសូមស្រូបស្រង់គន្ធា ព្រោះអ្នកជាឱសថទិព្វ

ទេពឥន្ទ្រព្រហ្ម ។






# ស្រណោះស្រុកស្រែអំបិល

| បទភ្លេង ទំនុកច្រៀង | ច្រៀងដោយ |
|---|---|
| យ៉ង់ ឈឿន ហៅ សំនៀងឫទ្ធី | សៀង ឌី |

I. ខ្ញុំឃ្លាតចាកឆ្ងាយពីឆ្នេរ កាត់គង្គាដ៏ធំធេង លាហើយឆ្ងាយហើយ

ចិត្តសង្រេង ខ្លាចក្រែងមិនបានដូចក្តីប្រាថ្នា ។

II. កណ្តាលជលសៃធំក្រៃពេក មើលជើងមេឃហាក់ដូចជា

ជំនោរបក់មករែងរងា ផ្តន្ទារូបខ្ញុំឱ្យឃ្លាតចេញឆ្ងាយ ។

R. ឱ ! ដែសមុទ្រ ដែលខ្ញុំឃ្លាតផុតគួរឱ្យខ្ញុំនឹកស្តាយ

ស្រែអំបិលធ្លាប់សប្បាយ សែនស្តាយម្លេះណា ។

III. រាត្រីបណ្តែតតាមនាវា ក្រោមចន្ទ្រាដ៏ភ្លឺថ្លា

ចម្រៀងឱ្យច្រៀងសកវាទី ឱ ! អនិច្ចាខ្ញុំឃ្លាតចេញឆ្ងាយ ។





# សម្រស់ខេត្តមណ្ឌលគិរី

| បទភ្លេង ទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| ម៉ៅ ហូ | ហាស់ សាឡន | សៀង ឌី |

I. ទីតាំងវាំងវាលចាំងច្រាលសុរិយា ប្រក់ព្រំព្រឹក្សាខៀវខ្ចី
មណ្ឌលគិរីទីថ្មី ថ្លែងអាល័យក្ដីសុខសាន្ត ។

II. ដែនភ្នំធំធេងវាលវែង វែងសែនឆ្ងាយ
សោភ័ណឆើតឆាយសោភា យល់ហើយទ្រូងស្មើយមួយគ្រា
មិនចង់លាៗសោះឡើយ ។

R. លំអកេសរផ្កា ល្ហងលោមភូមិរាសាសងឆ្លងឆ្លើយ
ផ្កាអើយចេះក្បៀកកើយឱ្យអាល័យ ។

III. ខេត្តខណ្ឌនិមលមណ្ឌលគិរីអើយ ខ្ញុំមិនភ្លេចឡើយណាថ្លៃ
ចាំជាក់ដួងភក្ត្រប្រិមប្រិយ ល្បាស់ព្រៃចខ្ចីនៃមណ្ឌល ។





# ទឹកភ្នែកមុនថ្ងៃលិច

| បទភ្លេង ទំនុកច្រៀង | សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| វ៉ោយ ហូ | ហាស់ សាឡន | សៀង ឌី |

I. មេឃក្រហមឆ្អៅ អាទិត្យយាងទៅកាន់សុមេរ៉ា

ចាំងចោលរស្មីច្រាលផ្ទៃជលសា ភ្លឺថ្លាដូចពេជ្រ ។

II. សមុទ្រអន្លាយ មើលមេឃខ្ពស់ឆ្ងាយឱ្យកាយនែបនិត្យ

ស្នេហ៍បាត់បង់ទៅនៅតែទឹកភ្នែកហូរ ស្រែកអាល័យ ។

R. សង្សារអ្នកនៅទីណា មេត្តាប្រណី អាសូរដល់ស្រី

រង់ចាំប្រុសថ្លៃរីងរៃឱរា ។

III. សុរិយាអើយរូបខ្ញុំនេះហើយ ឥតស្បើយឡើយណា

សូមជួយរំលែកទឹកភ្នែកស្នេហា ក្នុងគ្រានេះផង ។





# ចម្រៀងអស់សង្ឃឹម

បទភ្លេង ទំនុកច្រៀង សម្រួលតន្ត្រី ច្រៀងដោយ

ហាស់ សាឡុន សៀង ឌី

I. ចម្រៀងច្រៀងអស់សង្ឃឹម ផ្គរលាន់គ្រឹមៗតែគ្មានភ្លៀងសោះ

ដីបែកក្រហែងធម្មជាតិក្រៀមក្រោះ គ្មានសង្ឃឹមសោះ

ថាសង្សារវិលវិញ ។

II. ចម្រៀងលាយនឹងតន្ត្រី ដូចជាបក្សីយំស្រែកខ្សៀវខ្វា

យំនឹករលឹកដល់គូសង្សារ ដែលខ្ញុំប្រាថ្នាជាគូជីវិត ។

R. រន្ទះបាញ់ឮឆាំងៗ ខ្លួនខ្ញុំភ័យខ្លាំងរន្ធត់កាយា ដូចសំប៉ាននៅកណ្តាល

ជលសា គ្មានកោះត្រើយណានឹងបានជ្រកផង ។

III. ចម្រៀងលាយក្តីកង្វល់ រសាត់តាមខ្យល់ទៅដល់ទីណា

បើបងឮហើយសូមបងមេត្តា វិលវិញកុំខានណា អូនចាំជានិច្ច ។

# នុះហ្ន៎! មើលពួកកម្លោះ

| បទភ្លេង ទំនុកច្រៀង សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|
| ហាស់ សាឡន | សៀង ឌី |

I. នុះហ្ន៎ ! មើលពួកកម្លោះ ឆា ឆា ឆា ! ឆា ឆា ឆា

ស្លៀកពាក់យ៉ាងស្រស់អស្ចារ្យ កាច់រាងថាខ្លួនសង្ហា ហាំ ! (២ដង)

ចង់រាំចារកស្រី ។

II. កម្លោះឥឡូវខូចណាស់ ឆា ឆា ឆា ! ឆា ឆា ឆា

មុខក្រាស់ដើរឌឺតស្រីៗ មិនគិតថាខ្លួនក្មេងខ្ចី ហាំ ! (២ដង)

ស្រីៗស្អប់មុខណាស់ ។

R. មើលគេភ្លេចភ្លាំងស្មារតីហើយ លោកអើយជួយមើលចុះ នុះហ្ន៎ !

រុយទំក៏មិនរវល់ដែរ (២ដង) ឱ្យតែបានឃើញស្រី ។

យើងនាំគ្នារាំ ឆា ឆា ! ឆា ឆា ឆា ! ឆា ឆា ឆា !

III. សង្ហាដាក់ប្រុសអប្រិយ ឆា ឆា ឆា ! ឆា ឆា ឆា

ចូលចិត្តតែបោកស្រី (២ដង) ឱ្យស្រីទ្រាំមិនបាន ។





# រាំទាន់ខ្លួននៅក្មេង

**បទភ្លេង ទំនុកច្រៀង សម្រួលតន្ត្រី ច្រៀងដោយ**

**ហាស់ សាឡន សៀង ឌី**

I. រាំទាន់ខ្លួននៅក្មេង យើងរាំតាមភ្លេងចង្វាក់អាហ្គោ ហ្គោ
លើកដៃលើកជើងក្បាលងក់ងីងើ អ្ហែក !
បង្លីវាចាថាយើងរាំសមមែន សមមែន សមមែន ៗៗ
យើងរាំសប្បាយទាន់ខ្លួននៅក្មេង ។

...........ភ្លេង........

II. រាំទាន់ខ្លួននៅក្មេង យើងរាំតាមភ្លេងចង្វាក់អាហ្គោ ហ្គោ
លើកដៃលើកជើងក្បាលងក់ងីងើ អ្ហែក !
បង្លីវាចាថាយើងរាំសមមែន សមមែន សមមែន ៗៗ
យើងរាំសប្បាយទាន់ខ្លួននៅក្មេង ។





# ស្វារាំម៉ុនឃីស

បទភ្លេង ទំនុកច្រៀង សម្រួលតន្ត្រី ច្រៀងដោយ
មែរ ប៊ុន សៀង ឌី

I. ខ្ញុំឃើញស្វាមួយរាំម៉ុនឃីស ស្វានោះសែនចេះប្រៀបមិនបាន
ពេលរាំម្ដងៗ ញាក់ខ្លួនញាក់ប្រាណ ធ្វើមុខស្មេញស្វាញ
សើច ហាស់...ហាំ....ម៉ុនឃីស ។
ហាស់ហាំ ! ហាស់ហាំ ! ហាស់ហាំ ! ហាស់ហាំ !
ម៉ុនឃីស ! ហាស់ហាំ ! ហាស់ហាំ ! ពួកខ្ញុំរាំដែរ ។

II. ខ្ញុំឃើញស្វាមួយរាំម៉ុនឃីស ស្វានោះសែនចេះប្រៀបមិនបាន
ពេលរាំម្ដងៗ ញាក់ខ្លួនញាក់ប្រាណ ធ្វើមុខស្មេញស្វាញ
សើច ហាស់...ហាំ....ម៉ុនឃីស ។
ហាស់ហាំ ! ហាស់ហាំ ! ហាស់ហាំ ! ហាស់ហាំ !
ម៉ុនឃីស ! ហាស់ហាំ ! ហាស់ហាំ ! ពួកខ្ញុំរាំដែរ ។

# ក្រុងព្រះសីហនុ





**បទភ្លេង ទំនុកច្រៀង** **ច្រៀងដោយ**

**.........? (ច្រៀងឆ្នាំ ១៩៥៧) សុះ ម៉ាត់~សៀង ឌី**

I. (ប) នែ៎ ! ធីតា (ស) វាចាហៅខ្ញុំធ្វើអ្វី ? (ប) អញ្ជើញស្រីទៅ

លេងក្រុងព្រះសីហនុ (ស) នៅដល់ទីណា រៀមរ៉ាវាចាមកចុះ

(ប) ជិតទេឱ្យតែនាងស្មោះចំពោះថាទៅប្រាកដ ។

II. (ស) ខ្ញុំចង់ស្គាល់ (ប) និមលកុំព្រួយសោះឡើយ (ស) យូរថ្ងៃ

ហើយចិត្តចង់ឃើញសមុទ្រ (ប) សែនសប្បាយឆោមឆាយ

រីករាយបំផុត (ស) ឮថាទៅខ្ញុំចង់ស្ងួត ដូចផុតពីក្តីទុក្ខា ។

R. (ប) ផ្ទះថ្មទាំងឡាយសង់នៅលើភ្នំ បង្កើតជាក្តីសុខុមមូលផ្តុំដល់យើង

(ស) បើសប្បាយមែនដូចពាក្យប្រុសថា ចាំខ្ញុំជំរាបម៉ាក់ប៉ា មេត្តាជូនយើងទៅផង ។

III. (ប) កុំអួនស្រីម្តេចថ្លៃវាចាដូច្នេះ នារីស្រស់ត្រូវស្មោះដើរជាមួយបង

(ស) ដើរពីរនាក់បញ្ជាក់ជាខុសបំណង (ប) ឱ ! មិនអីទេនួនល្អង

ចាំបងតាមប្រពៃណី ។






# អកលាខ្រូនំ

| ទំនុកច្រៀង | បទភ្លេង | ច្រៀងដោយ |
|---|---|---|
| ស្វាយ សំអឿ | មៃរ ម៉ុន (ច្រៀងឆ្នាំ ១៩៥៧) | សាមុត~សៀង ឌី |

I. (ប) បងសូមលាស្រីហើយ អូនអើយនៅសុខា បងលាទៅរកមច្ឆា
ឱ្យបុត្រានិងស្រីពៅ ។

II. (ស) បើបងចាកទៅហើយ បងអើយឆាប់វិលមកលំនៅ ប្អូនទ្រាំរង់ចាំមើលផ្លូវ
ប្រុសកុំទៅយូរឡើយណា ។

R. (ប) បងទៅឆាប់ទេ សូមស្រីមាសស្នេហ៍ បីបមថ្នមថែបុត្រទាំងទ្វេរហា

(ស) កុំបីបងគិតដល់បុត្រឡើយណា ប្អូននៅរក្សា ចូរប្រុសជីវ៉ាកុំបារម្ភឡើយ ។

III. (ប) បើពិតដូចវាចា ស្នេហាបងសូមលាស្រីហើយ នៅថ្នមបុត្រឱ្យបានស្បើយ
អូនអើយនាងកុំបារម្ភ ។



# ចរិយា



| ទំនុកច្រៀង | បទភ្លេង | ច្រៀងដោយ |
|---|---|---|
| ម៉ា ឡៅពី | បរទេស (ឆ្នាំ ១៩៦២) | សៀង ឌី |

ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា

ឡា ឡា ឡា ឡា

I. ចរិយា ម្ចាស់ចិត្តជីវិតថ្លើមស្នេហា របស់អូន ចរិយា គួសង្សារចិន្តាមេត្តា វាសនាអូន ចរិយា ខ្ញុំស្នេហាស្នេហាស្មើជីវិត ស្រលាញ់ទុកជាគូស្នេហ៍ របស់អូន ចរិយា របស់បងឱម្ចាស់ ឱម្ចាស់ នឹកណាស់ស្ទើរបែកទ្រូង

II. ចរិយា គ្រប់ពេលវេលាខ្ញុំសច្ចា ជួបតែបង ចរិយា គ្រប់ពេលវេលាខ្ញុំប្រាថ្នា សូមផ្ញើខ្លួន ចរិយា ខ្ញុំប្រាថ្នាលុះអស់សង្ខារ លើអ្នកឥតប្រែប្រួលឡើយ ម្ចាស់ស្នេហ៍អូន ចរិយា ម្ចាស់ស្នេហ៍អូន ចរិយា

ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ឡា ចរិយា....





# គេងទៅកូន

**បទភ្លេង ទំនុកច្រៀង សម្រួលតន្ត្រី**
**ម៉ែរ ប៊ុន**

**ច្រៀងដោយ**
**សៀង ឌី**

I. គេងទៅកូន ម្តាយនៅបង្ហើយ យប់ណាស់ហើយ កូនយំដល់ណា ?

ឬមួយកូនយំទន្ទឹងផ្លូវប៉ា ដើរសង្ហាចោលបានៅផ្ទះ ។

II. គេងទៅកូន ម្តាយនៅយោលបា មើលផ្លូវប៉ា ម្តាយព្រួយចិត្តណាស់

យប់យូរហើយ មិនទាន់ដល់ផ្ទះ សប្បាយណាស់ ភ្លេចផ្ទះសម្បែង ។

R. ព្រួយគ្មានលោះមួយថ្ងៃ ព្រួយព្រោះមានប្តីគ្មានចិត្តមេត្តា ចោលម្តាយ

ឱ្យខ្លោចផ្សា តែឯងឯកា អនិច្ចាខ្លួនស្រី ។

III. គេងទៅកូន កុំឱ្យម្តាយព្រួយ បានកូនមួយគ្រាន់ជារស្មី

បំភ្លឺម្តាយបំភ្លេចទុក្ខភ័យ គេងទៅថ្ងៃកុំនៅចាំប៉ា ។






# សែនស្នោះ

| ទំនុកច្រៀង | បទភ្លេង សម្រួលតន្ត្រី | ច្រៀងដោយ |
|---|---|---|
| ស្វាយ សំអឿ | មែរ ប៊ុន | សៀង ឌី |

I. មើលទៅមេឃឆ្ងាយសែនយោជ ខែរនោចយាងទៅឆ្ងាយ

ដួងតារាភ្លឺព្រោងព្រាយ ក្នុងចិត្តអូនសែនខ្វល់ខ្វាយ រកនិយាយពុំបាន ។

II. មើលទឹកហូរៗគ្មានដាច់ ដួងចន្ទ័លិចបំបាំងប្រាណ

ក្នុងចិត្តអូនរែងរំខាន គេងកើយពុំយល់ដាន បងភ្លេចប្រាណអូនទៅហើយ ។

R. ប្អូននៅរង់ចាំ តាមបណ្តាំពុំឃើញឡើយ ទុក្ខប្អូនគ្មានស្បើយ

ឱ ! បងអើយសូមមេត្តា ។

III. ចិត្តប្រុសម្តេចបើមិនទៀត រដូចភ្លៀងត្រូវវាតា រស្មីស្នោះដូចតារា

នៅខ្ពស់ឆ្ងាយពីពសុធា ដូចចន្ទ្រាលិចបាត់ទៅ ។






# លាហើយក្ដីស្នេហ៍

| | |
|---|---|
| បទភ្លេង ទំនុកច្រៀង សម្រួលតន្ត្រី | ច្រៀងដោយ |
| ម៉េរ ប៊ុន | សៀង ឌី |

I. ចន្ទ្រាចែងចាំងលើពសុធា ដួងចិត្តកំព្រា នឹកឃើញដល់គ្រាក្បៀកកើយ

បងសច្ចាថាមិនចោលអូនឡើយ ឥឡូវកន្តើយ បែរខ្នងព្រងើយភ្លេចអស់ ។

II. នឹកខ្ញុំខ្លះទេឬបែបបែរ ចាកចោលក្ដីស្នេហ៍ ចិត្តបងកែប្រែបង់បោះ

ឥតមេត្តា ឬស្សាគ្មានស្រណោះ ស្គាល់ក្លិនហើយ ដោះដៃគ្មានអាឡោះ

អាល័យសោះឡើយ ។

R. នេះជាមេរៀនក្នុងឆាកជីវិត ឱ្យយើងដឹងពិត ថាត្រូវរិះគិតឱ្យហើយ

ស្គាល់រសជាតិស្នេហ៍ រងទុក្ខគ្មានស្បើយ ឱរាខ្ញុំអើយគ្រាំគ្រាឥតល្ហើយទេណា ។

III. លាហើយស្នេហាដែលមិនស្មោះ ខ្ញុំបានជាខុសមិនដឹងចិត្តប្រុសសាវ៉ា

ដួងចិត្តឈឺចាប់រកាំខ្លោចផ្សា តែឯងឯកា ឥតមាននរណាចរចាសាសង ។





# សំបុត្រជាវិញ្ញាណស្នេហា

បទភ្លេង ទំនុកច្រៀង សម្រួលតន្ត្រី ហាស់ សាឡន

ច្រៀងដោយ សៀង ឌី

I. យូរខែយូរឆ្នាំមកហើយ បងបានសន្យា ប្អូនខ្លោចផ្សាឃើញប្រុសថ្លៃ អ្នកធ្វើកន្តើយ ។

II. រាត្រី ប្អូនគេងយល់សប្តិ បងមានគូថ្មី ប្អូនអាល័យថ្លៃពេកណាស់ ប្អូនគេងពុំលក់ ។

R. សំបុត្រ វិញ្ញាណស្នេហា ធ្លាក់ក្នុងឱរា ថាយើងបានជួបគ្នាទៅអនាគត ឥឡូវប្រែជារលត់ មិនឮដំណឹង ។

III. សត្វចាបហើរចុះ ហើរឡើង ធ្វើឫកសង្ហា ចិត្តសាវ៉ា ចាកចេញចោល ពីទ្រនំចាស់ ។

# សេចក្តីជូនដំណឹង

មិត្តអ្នកអានជាទីនឹករលឹក ! ខ្ញុំបាទសូមមានសេចក្តីរំភើបរីករាយពន់ពេកណាស់ចំពោះអ្នកទាំងអស់គ្នា ទាំងក្នុងនិងក្រៅប្រទេសដែលបានគាំទ្រនូវរាល់ស្នាដៃរបស់ខ្ញុំ...ដូច្នេះតាមរយៈការគាំទ្រនេះ ខ្ញុំបាទ **សេង តារា** សន្យាថានឹងខិតខំប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការស្រាវជ្រាវនូវប្រវត្តិជីវិតនិងស្នាដៃរបស់សិល្បករខ្មែរយើងទាំងអស់ពីសម័យមុនមកជូនអ្នកទាំងអស់គ្នាឱ្យបានជ្រាប... ប៉ុន្តែចំពោះការខ្វះខ្នែងតែខ្ញុំម្នាក់ឯងនេះ ពិតជាចំណាយពេលវេលាយូរអង្វែងនិងមានឧបសគ្គច្រើនណាស់ ហេតុនេះខ្ញុំបាទសូមឆ្លៀតឱកាសជូនដំណឹងទៅដល់មិត្តអ្នកអានទាំងឡាយ ប្រសិនអ្នកណាបានដឹងរឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងបទចម្រៀងជំនាន់ដើម ឬស្គាល់សាច់ញាតិសិល្បករជំនាន់ដើមសូមជួយផ្តល់ដំណឹងដល់ខ្ញុំបាទផង ដើម្បីខ្ញុំបាទចុះទៅស្រាវជ្រាវបានឆាប់រហ័ស ។

ពេលនេះ ខ្ញុំកំពុងស្រាវជ្រាវរកប្រវត្តិ រូបថត និងសាច់ញាតិ សិល្បករមួយចំនួនដូចជា : កវី **យ៉ង់ ឈឿង** ហៅ **សំនៀងឫទ្ធិ** កវី **ញ៉ែម ផុន** ហៅ **ភុក** កវី **វ៉ោយ ហូ** អ្នកនិពន្ធបទភ្លេង **សម សាខន** (ប្តីអ្នកស្រី ម៉ៅ សារ៉េត) អ្នកស្រី **នៅ ណារិន** លោក **យស អូឡារាំង** លោក **ឡឹក សាវ៉ាត** លោក **សាំង សារុន** អ្នកស្រី **ចេក ម៉ាច** (អ្នក សំដែងល្ខោនបាសាក់) តា **ពូថៅដៃ** (អ្នកច្រៀងចាប៉ី) និងសិល្បករ សិល្បការិនីផ្សេងៗទៀត....។

សង្ឃឹមថា មិត្តអ្នកអាននឹងចូលរួមសហការណ៍ជាមួយខ្ញុំយ៉ាងរីករាយ...

**សូមអរគុណ !**

# ឧបករណ៍ភ្លេងសម័យចម្រុះ

## ឧបករណ៍ភ្លេងខ្សែ



# ឧបករណ៍ភ្លេងសម័យចម្រុះ

## ឧបករណ៍សំរាប់វ៉ៃ ជាន់ និង ក្រឡុក



ស្គរអកកេះ (Zazz)



ស្គរត្លោះ (Canga)



កាស់ស្តាញៀត(ក្រឡុក)
(Castagnet)



រនាតដែកអ៊ឺរ៉ុប
Sylophone

# ឧបករណ៍ភ្លេងសម័យចម្រុះ

## ឧបករណ៍សំរាប់ចុច



ព្យ៉ាណូធំ
Grand Piano



ព្យ៉ាណូធំប្រភេទផ្សេង
Appaito Piano



ព្យ៉ាណូធម្មតា
Normal Piano



អ័រគ័
Organe



អាក់គ័រដេអុង
Accordeon

# ឧបករណ៍ភ្លេងសម័យចម្រុះ

## ឧបករណ៍សំរាប់ផ្លុំ




ត្រុំប៉ែត(ធម្មតា)
Trompette

ត្រុំប៊ន
Trombone

ក្លារីណែត
Clarinette



សាក់សូធំ(តេន័រ)
Saxophone Tenor

សាក់សូ មធ្យម(អាល់តូ)
Saxophone Alto

សាក់សូ សូប្រាណូ
Saxophone Soprano


ឧបករណ៍ភ្លេងសម័យចម្រុះ
ឧបករណ៍សំរាប់ផ្លុំ
គំរណោ
Corne
ក្លេរ៉ុង
Clairon
ខ្លុយដែក
Flute
អាម៉ូនីកា
Harmonica
ព្យ៉ានីកា
Pianica
ស្នែង
Horn
French Horn
ទូបា
Tuba

# ឧបករណ៍ភ្លេងសម័យចម្រុះ

## ឧបករណ៍សំរាប់ផ្លុំ



អាល់តូ
Alto



បារីតុន
Baryton



គ្រឿងផ្លុំមួយប្រភេទទៀត
Recorder



បាស់
Bass



បាស់តូច
Small Bass



សាក់សូហ្វូន
Saxophone

# ឧបករណ៍ភ្លេងសម័យចម្រុះផ្សេងៗទៀត









French Horn





ស្គរអកកេះទំនើបមួយបែបទៀត

# តន្ត្រីករ កវីនិពន្ធ តារាភាពយន្ត និងផលិតករភាពយន្ត ដែលនៅមានជីវិត និង ស្លាប់ជីនាន់ក្រោយនេះ

## អ្នកចម្រៀងដែលនៅរស់ដល់សព្វថ្ងៃ

១- អ្នកស្រី **ឈុន វណ្ណា** អាមេរិច

២- អ្នកស្រី **ឌី សាខន** អាមេរិច

៣- អ្នកស្រី **សូ សាវឿន** បារាំង

៤- អ្នកស្រី **ហែម សុវណ្ណ** ភ្នំពេញ

៥- អ្នកស្រី **ម៉ៅ ស៊ីថន** ភ្នំពេញ នៅវត្តកោះ)

៦- លោក **ថាច់ សូលី** កំពង់ឆ្នាំង

៧- អ្នកម្នាង **សៀង ឌី** ភ្នំពេញ

៨- លោក **មាស ម៉េងហ៊ាង** បារាំង ( ប្អូនលោក **មាស ហុកសេង**)

៩- លោក **វ៉ា សារុន** ភ្នំពេញ

១០- លោក **កុល សែម** ភ្នំពេញ

## អ្នកស្លាប់ជំនាន់នេះ :

១- អ្នកស្រី **ប៉ែន រ៉ម** ( ប្អូនប៉ែន រ៉ន) ស្លាប់អំឡុងឆ្នាំ ២០០៣ នៅអាមេរិច

២- លោក **ទូច សាលី** ស្លាប់ឆ្នាំ ២០០៩

៣- អ្នកស្រី **សៀង វ៉ាន់ធី** ស្លាប់ឆ្នាំ ២០០៩

៤- អ្នកស្រី **ឈួន ម៉ាឡៃ** អាមេរិច ( ទើបស្លាប់ឆ្នាំ ២០១២)

## តន្ត្រីករ និង អ្នកនិពន្ធនៅរស់ដល់សព្វថ្ងៃ

១- លោក អ៊ុំ ដរ៉ា កវីនិងជាតន្ត្រីករវិទ្យុឡុង ភ្នំពេញ
២- លោក ឯល ប៊ុនណា កវីនិងជាតន្ត្រីករខ្លុយដែក ភ្នំពេញ
៣- លោក អ៊ុក សំអាត កវីនិងជាតន្ត្រីករខ្លុយដែក ភ្នំពេញ
៤- លោក ម៉ម ប៊ុតណារ៉ាយ និពន្ធបទភ្លេងនិងសម្រួលតន្ត្រី ភ្នំពេញ
៥- លោក ស្វាយ ស តន្ត្រីករ អាក់គរ័ដឺអុង ខេត្ត កណ្ដាល
៦- លោក ហេ ជុនសិ វិយូឡុង និពន្ធបទភ្លេង សៀមរាប
៧- លោក គន្ធ ប៊ុនឈឿន កវីម្ចាស់ស្ទឹងសង្កែ ប្រទេស ន័រវ៉េ
៨- អ្នកស្រី ម៉ុក ចាន់មាលី អ្នកនិពន្ធទំនុកច្រៀង អាមេរិច
៩- លោក ឯិន សកវាន់ តន្ត្រីករ ភ្នំពេញ
១០- លោក ទូច ឆត្ថា ហ្គីតា អ្នកចម្រៀង ភ្នំពេញ
១១- លោក ទូច សៀង និពន្ធបទភ្លេង ទំនុកច្រៀង ភ្នំពេញ
១២- លោក ម៉ៅ អាយុទ្ធ ទំនុកច្រៀង ល្ខោននិយាយ ភ្នំពេញ

### អ្នកស្លាប់ជំនាន់ក្រោយ ៖

១- លោក យិន ឌីការ កវី តន្ត្រីករខ្លុយដែក ស្លាប់ឆ្នាំ ១៩៩២
២- លោក អ៊ឹម អួន កវី តន្ត្រីករព្យ៉ាណូ ស្លាប់ឆ្នាំ ១៩៩៦
៣- លោក ម៉ា ឡៅពី កវីសេកមាស ស្លាប់ឆ្នាំ ១៩៩៧
៤- លោក វ៉ែន ផាត អ្នកនិពន្ធ ស្លាប់ឆ្នាំ ២០០៩
៥- លោក ម៉ា សំភុល អ្នកចម្រៀង ស្លាប់ឆ្នាំ .......?
៦- លោក ហេង ហ្វវ៉េង អ្នកនិពន្ធ ស្លាប់ឆ្នាំ ២០១២

## ផលិតករភាពយន្តដែលនៅរស់ដល់សព្វថ្ងៃ

១- លោក **លី ប៊ុនយឹម** ម្ចាស់ផលិតកម្ម **វន្នះពេជ្ជភាពយន្ត** ភ្នំពេញ

២- លោក **លី យូស្រ៊ាង** ម្ចាស់ផលិតកម្ម **ហេមពាន្តភាពយន្ត** ភ្នំពេញ

៣- លោក **អ៊ី វង់ហែម** ផលិតកម្ម **បក្សាឋានសួគ៌ភាពយន្ត** ភ្នំពេញ

៤- លោក **ឌា លឹមគុណ** ម្ចាស់ផលិតកម្ម **តារារត្ន័ភាពយន្ត** កាណាដា

## តារាភាពយន្តដែលនៅរស់ដល់សព្វថ្ងៃ

១- អ្នកស្រី **ឌី សាវ៉េត** ភ្នំពេញ

២- អ្នកស្រី **វិរៈតារា** ភ្នំពេញ

៣- អ្នកស្រី **ពៅ ទេវី** ភ្នំពេញ

៤- អ្នកស្រី **ឈូករត្ន័** បារាំង

៥- អ្នកស្រី **កែវ មន្ថា** ភ្នំពេញ

៦- អ្នកស្រី **សាក់ ស៊ីសេឿង** អាឡឺម៉ង់

៧- អ្នកស្រី **ពៅ ទេវី** ភ្នំពេញ

៨- អ្នកស្រី **ភួង ផល្លី** ភ្នំពេញ

# កវីនិពន្ធ និង តន្ត្រីករជើងចាស់ដែលនៅមានជីវិត




អ្នកចម្រៀងជើងចាស់ដែលនៅមានជីវិត
អ្នកម្នាង
ស៊ៀង ឌី
ជួប សារឿន
កែវ សេដ្ឋា
ឈុន វណ្ណា
អ្នកអគ្គម្ចាស់ ស៊ីសុវត្ថិ
ប៉ាណ្ណារ៉ា សិរីវុឌ្ឍ
មាស ម៉េងហ៊ាង
ឌី សាខន
សូ សាវឿន
ក្លុល សែម
វ៉ាំ សារ៉ុន
ថាច់ សូលី
ទេព សទ្វារ
ហែម សុវណ្ណ

# ស្នាដៃដែលចេញផ្សាយរួច

ក- ប្រលោមលោក :


១- ស្វាយលើរឿងខ្ញុំ ឆ្នាំ ២០០៤

២- កោះប្រាក់អន្ទាក់ជីវិត ឆ្នាំ ២០០៥

៣- ផ្កាជ្រុះលើគក់ ឆ្នាំ ២០០៦

៤- កន្លែងគង់អន្លង់កម្ម ឆ្នាំ ២០០៦

៥- ព្រាយក្រឡាភ្លើង ឆ្នាំ ២០០៧

៦- ថ្ងៃ ១២ កក្កដា ឆ្នាំ ២០១០


ខ- មាសស្រោបនគរ : ប្រវត្តិជីវិតអ្នកចម្រៀង កវីនិពន្ធ តន្ត្រីករ...


| | | | |
|---|---|---|---|
| ១- | មាសស្រោបនគរ ភាគ ១ | សាមុត-សុទ្ធា | ២០០៧ |
| ២- | មាសស្រោបនគរ ភាគ ២ | សុះ ម៉ាត់-ហួយ មាស-អាប់ឌុល សារី | ២០០៧ |
| ៣- | មាសស្រោបនគរ ភាគ ៣ | អ៊ឹម សុងសឺម-មាស សាម៉ន-កែវ សារ៉ាត់ | ២០០៧ |
| ៤- | មាសស្រោបនគរ ភាគ ៤ | គង្គ ប៊ុនឈឿន-ឯល ប៊ុនណា-ហេង ហួរ៉េង | ២០០៧ |
| ៥- | មាសស្រោបនគរ ភាគ ៥ | ពៅ ស៊ីផូ-ស្វាយ សំអឿ-អ៊ុំ ដរ៉ា | ២០០៨ |
| ៦- | មាសស្រោបនគរ ភាគ ៦ | ម៉ៅ សារ៉េត-ហែម សុវណ្ណ | ២០០៩ |
| ៧- | មាសស្រោបនគរ ភាគ ៧ | កុល សែម-វ៉ៃ សារុន | ២០០៩ |
| ៨- | មាសស្រោបនគរ ភាគ ៨ | ម៉ុក ចាន់មាលី-ហៃ ជុនសិ | ២០០៩ |
| ៩- | មាសស្រោបនគរ ភាគ ៩ | ជុំ កែម-ទូច សាលី | ២០១០ |
| ១០- | មាសស្រោបនគរ ភាគ ១០ | ញឹក ឌីម-តាំង ស៊ីឡេង | ២០១០ |
| ១១- | មាសស្រោបនគរ ភាគ ១១ | យិន ឌីកាន-អ៊ូម អួន | ២០១០ |
| ១២- | មាសស្រោបនគរ ភាគ ១២ | មាស ហុកសេង | ២០១១ |

ខ- ថ្ងៃលិចឯនាយសមុទ្រ : ប្រវត្តិបទចម្រៀង

១- ថ្ងៃលិចឯនាយសមុទ្រ ភាគ ១ ឆ្នាំ ២០០៨

១- ថ្ងៃលិចឯនាយសមុទ្រ ភាគ ២ ឆ្នាំ ២០០៨

១- ថ្ងៃលិចឯនាយសមុទ្រ ភាគ ៣ ឆ្នាំ ២០០៨

១- ថ្ងៃលិចឯនាយសមុទ្រ ភាគ ៤ ឆ្នាំ ២០០៩

១- ថ្ងៃលិចឯនាយសមុទ្រ ភាគ ៥ ឆ្នាំ ២០០៩

១- ថ្ងៃលិចឯនាយសមុទ្រ ភាគ ៦ ឆ្នាំ ២០១០

១- ថ្ងៃលិចឯនាយសមុទ្រ ភាគ ៧ ឆ្នាំ ២០១០

គ- សៀវភៅពិសេស "អធិរាជឆ្លងដែន" ឆ្នាំ ២០១០ ១ភាគចប់

ឃ- ការវិវត្តន៍នៃតូរតន្ត្រីខ្មែរ (២០១២) ភាគ ១ កំណើតភ្លេងសម័យ...

ង- ផ្កាំងសំពត់ស (២០១២) ភាគ ១ ប្រវត្តិតារាភាពយន្ត

## សូមរង់ចាំអានភាគបន្តបន្ទាប់

## ដែលនឹងចេញផ្សាយនៅពេលឆាប់ៗនេះ

## សូមអរគុណ !

# សេចក្តីជូនដំណឹង

មិត្តអ្នកអានជាទីនឹករលឹក ! ខ្ញុំបាទសូមមានសេចក្តីរំភើបរីករាយពន់ពេកណាស់ចំពោះអ្នកទាំងអស់គ្នា ទាំងក្នុងនិងក្រៅប្រទេសដែលបានគាំទ្រទូវរាល់ស្នាដៃរបស់ខ្ញុំ...ដូច្នេះតាមរយៈការគាំទ្រនេះ ខ្ញុំបាទ **សេង តារា** សន្យាថានឹងខិតខំប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការស្រាវជ្រាវនូវប្រវត្តិជីវិតនិងស្នាដៃរបស់សិល្បករខ្មែរយើងទាំងអស់ពីសម័យមុនមកជូនអ្នកទាំងអស់គ្នាឱ្យបានជ្រាប... ប៉ុន្តែចំពោះការខ្នះខ្នែងតែខ្ញុំម្នាក់ឯងនេះ ពិតជាចំណាយពេលវេលាយូរអង្វែង និងមានឧបសគ្គច្រើនណាស់ ហេតុនេះខ្ញុំបាទសូមឆ្លៀតឱកាសជូនដំណឹងទៅដល់មិត្តអ្នកអានទាំងឡាយ ប្រសិនអ្នកណាបាដឹងរឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងបទចម្រៀងជំនាន់ដើម ឬស្គាល់សាច់ញាតិសិល្បករជំនាន់ដើមសូមជួយផ្តល់ដំណឹងដល់ខ្ញុំបាទផង ដើម្បីខ្ញុំបាទចុះទៅស្រាវជ្រាវបានឆាប់រហ័ស ។

ពេលនេះ ខ្ញុំកំពុងស្រាវជ្រាវរកប្រវត្តិ រូបថត និងសាច់ញាតិ សិល្បករមួយចំនួនដូចជា : កវី **យ៉ង់ ឈឿង** ហៅ **សំនៀងឬទ្ធី** កវី **ញ៉ែម ផុន** ហៅ **ភុក** កវី **វ៉ោយ ហូ** អ្នកនិពន្ធបទភ្លេង **សម សាខន** (ប្តីអ្នកស្រី ម៉ៅ សារ៉េត) អ្នកស្រី **នៅ ណារិន** លោក **យស អូឡារាំង** លោក **ឡឹក សាវ៉ាត** លោក **សាំង សារុន** អ្នកស្រី **ចេក ម៉ាច** (អ្នក សំដែងល្ខោនបាសាក់) តា **ពូថៅវ៉ៃ** (អ្នកច្រៀងចាប៉ី) ....។

សង្ឃឹមថា មិត្តអ្នកអាននឹងចូលរួមសហការណ៍ជាមួយខ្ញុំយ៉ាងរីករាយ...

សូមអរគុណ !

# ចូលរួមឆ្លើយសំនួរ!

-តើយើងគួរបណ្តោយឱ្យមានការលួចបទចម្រៀងពីដើមៗមក "កែភ្លេង កែទំនុក" បន្តទៀត ឬ ត្រូវទប់ស្កាត់ ? "

-តើការយកបទចម្រៀងរៀមច្បងជំនាន់ដើមមក "ក្រឡៃ" ដូចសព្វថ្ងៃនេះ មានប្រយោជន៍ដល់សង្គមនិងវប្បធម៌មែនទេ ទើបគេមិនឈឺក្បាលបែបនេះ ?

-ពាក្យស្លោកមួយឃ្លាពោលថា "វប្បធម៌រលត់ជាតិរលាយ "ដូច្នេះក្នុងនាមយើងជាពលរដ្ឋខ្មែរ តើត្រូវធ្វើយ៉ាងណា ពេលឃើញខ្មែរបំផ្លាញខ្មែរដូចគ្នាដូចសព្វថ្ងៃនេះ ?

ជួយឆ្លើយគ្នា ...!

# សេចក្តីជូនដំណឹង

មិត្តអ្នកអានជាទីមេត្រី ! បើសិនអ្នកទាំងអស់គ្នាមាន "ថាសខ្មៅ" ឬដឹងថា អ្នកណាមាន "ថាសខ្មៅ" ឬមាន "សៀវភៅចំរៀង "ជំនាន់ដើម" សូមមេត្តាជួយ ផ្តល់ដំណឹងដល់ខ្ញុំបាទផង ព្រោះរបស់ទាំងនេះជាជំនួយចំពោះការស្រាវជ្រាវ របស់ខ្ញុំ ដើម្បីគាស់កាយស្នាដៃរៀមច្បងសិល្បករ កវីនិពន្ធយើងជំនាន់ដើម។

**នេះជាគំរូ "ថាសខ្មៅ" សំរាប់ថតចំរៀងនៅជំនាន់**

**លោកស៊ិន ស៊ីសាមុត**



# ដំណឹងពិសេស

ខ្ញុំបាទ សេង តារា បានស្រាវជ្រាវនិងរៀបរៀងចម្រៀងពិរោះៗ ឡើងវិញជា ស៊ីឌី (CD) តាមច្បាប់ដើមនូវកម្រងចម្រៀងទាំងអស់ដែលផលិតករ និង កវីនិពន្ធជំនាន់នោះថតជា "ស៊េរីកាសែត" ចាប់ពីឆ្នាំ 1973-1975 ដូចជាស៊េរី "ពស់មាស" ស៊េរី "អានុស្សាវរីយ៍បាត់ដំបង" និងស៊េរី "អានុស្សាវរីយ៍ប៉ៃលិន"...ជាដើម ។ល។

ខ្ញុំបាទសូមបញ្ជាក់ជូនមិត្តអ្នកអាន និង មិត្តអ្នកស្តាប់ថា ដោយសារការរៀបរៀងបទចម្រៀងទាំងនោះយកតាមលំនាំ "ស៊េរីកាសែត" ដើម ហេតុនេះ ចម្រៀងទាំងនោះសូម្បីតែមួយបទក៏មិនជាន់គ្នាដែរ។ ហើយគំរបCD ទាំងនោះក៏ខ្ញុំយករូបភាពគំរបកាសែតដើមជំនាន់នោះមកដាក់ផងដែរ ។ មិនតែប៉ុណ្ណោះ ខ្ញុំថែមទាំងវាយអក្សរបញ្ជាក់បន្ថែមអំពីឆ្នាំថត "ស៊េរីកាសែតចម្រៀង" និង "ឈ្មោះកវីនិពន្ធ" "អ្នកដឹកនាំភ្លេង" ដែលនិពន្ធបទចម្រៀងទាំងនោះនៅលើគំរបខាងមុខ និង ចំណងជើងខាងក្រោយទៀតផង ។ដូច្នេះក្រៅពីបានស្តាប់បទចម្រៀងពិរោះៗទាំងនោះអ្នកទាំងអស់គ្នាថែមទាំងដឹងអំពីអ្នកនិពន្ធនិងឆ្នាំថតនៃបទចម្រៀងទាំងនោះយ៉ាងច្បាស់ៗបំផុត ។ ហើយក្នុងចំណោមស៊េរីចម្រៀងទាំង

នោះ មានមួយភាគធំជា"ភ្លេងដើម" តែម្តង ដែលយើងកម្របានស្តាប់ណាស់ព្រោះសព្វថ្ងៃយើងបានឮតែចម្រៀងដែលបញ្ចូលភ្លេងថ្មីប៉ុណ្ណោះ ហើយគេរៀបបទជាន់គ្នារដឹក *"មិនដឹងបទណាទៅសេរីណា ឬ ឆ្នាំណាឡើយ"* ។

ប្រសិនមិត្តអ្នកអាននិងមិត្តអ្នកស្តាប់ចង់ជាវ "សេរីចម្រៀង" ដែលខ្ញុំរៀងរៀងឡើងវិញតាមច្បាប់ដើមទាំងនោះ អ្នកទាំងអស់គ្នាអាចទំនាក់ទំនងមកខ្ញុំផ្ទាល់តាមទូរសព្ទ័របស់ខ្ញុំគឺ 012 306 853 ។

អ្នកទាំងគ្នាគួរមានបទចម្រៀងទាំងនេះសំរាប់ស្តាប់ និងតំកល់ទុកជាឯកសារផ្ទាល់ខ្លួនតាមផ្ទះរៀងៗខ្លួនដើម្បីបង្ហាញកូនចៅទៅជំជំនាន់ក្រោយទៀត ។

.... **សូមអរគុណ !**

ចូលទៅមើលគេហទំព័រ Youtube

រួចវាយឈ្មោះខ្ញុំបាទជាភាសាអង់គ្លេស seng dara

អ្នកទាំងអស់គ្នានឹងបានឃើញខ្ញុំនិយាយអំពីប្រវត្តិបទចម្រៀង

រាប់រយបទជារូបភាពវីដេអូដែលខ្ញុំនិយាយជាប្រចាំសប្តាហ៍ផ្សាយ

តាមទូរទស្សន៍ CTN បណ្តាញខ្សែកាបក្រៅប្រទេស

# ឧបករណ៍ភ្លេងបុរាណខ្មែរចម្រុះ



ស្គរធំ(ពិណពាទ្យ)



ស្គរតើរី



ស្គរយីកេ



សម្ភោរ



ស្គរអារក្សក្អួយ



ស្គរធំ(បាសាក់)



ស្គរថូន



រនាតធុង



រនាតដែក



ក្រាប់មូល



ស្គរឆៃយ៉ាំ



ស្រឡៃ(ធំ_តូច)

# ឧបករណ៍ភ្លេងបុរាណខ្មែរចម្រុះ



សេរីកាសែតចម្រៀងដែលថតពីឆ្នាំ ១៩៧៣ដល់ឆ្នាំ ១៩៧៥ ហើយដែលខ្ញុំស្រាវជ្រាវ និងរៀបរៀងដាក់ស៊ីឌីឡើងវិញតាមច្បាប់ដើមរួមមាន :

1. -កាសែត **ពស់មាស** លេខ ១ ថតឆ្នាំ ១៩៧៣
   -កាសែត **ពស់មាស** លេខ ២ ថតឆ្នាំ ១៩៧៣
   -កាសែត **ពស់មាស** លេខ ៣ ថតឆ្នាំ ១៩៧៤
   -កាសែត **ពស់មាស** លេខ ៤ ថតឆ្នាំ ១៩៧៤
   -កាសែត **ពស់មាស** លេខ ៥ ថតឆ្នាំ ១៩៧៥

2. -កាសែត **ទៅយ ហូ** លេខ ១ ថតឆ្នាំ ១៩៧៣
   -កាសែត **ទៅយ ហូ** លេខ ២ ថតឆ្នាំ ១៩៧៣
   -កាសែត **ទៅយ ហូ** លេខ ៣ ថតឆ្នាំ ១៩៧៤
   -កាសែត **ទៅយ ហូ** លេខ ៤ ថតឆ្នាំ ១៩៧៤
   -កាសែត **រាំវង់ ទៅយ ហូ** លេខ ១ ថតឆ្នាំ ១៩៧៤
   -កាសែត **រាំវង់ ទៅយ ហូ** លេខ ២ ថតឆ្នាំ ១៩៧៤
   -កាសែត **អានុស្សាវរីយ៍ខ្មែរអាកាសចរណ៍** ថតឆ្នាំ ១៩៧៤
   -កាសែត **"យុវជនខូចចិត្ត"** ថតឆ្នាំ ១៩៧៤

3. -កាសែត **អានុស្សាវរីយ៍ប៉ៃលិន** ទី១ ថតឆ្នាំ ១៩៧៤
   -កាសែត **អានុស្សាវរីយ៍ប៉ៃលិន** ទី ២ ថតឆ្នាំ ១៩៧៤
   -កាសែត **អានុស្សាវរីយ៍ប៉ៃលិន** ទី ៣ ថតឆ្នាំ ១៩៧៤

4. -កាសែត **អានុស្សាវរីយ៍បាត់ដំបង** ទី ១ ថតឆ្នាំ ១៩៧៤

-កាសែត **អានុស្សាវរីយ៍បាត់ដំបង** ទី ២ ថតឆ្នាំ ១៩៧៥

5. -កាសែត **ស៊ីន ស៊ីសាមុត** ទី ១ ថតឆ្នាំ ១៩៧៤

-កាសែត **ស៊ីន ស៊ីសាមុត** ទី ២ ថតឆ្នាំ ១៩៧៥

6. -កាសែត **គីម សំអែល** ទី ១ ថតឆ្នាំ ១៩៧៤

-កាសែត **គីម សំអែល** ទី ២ ថតឆ្នាំ ១៩៧៤

-កាសែត **គីម សំអែល** ទី ៣ ថតឆ្នាំ ១៩៧៤

-កាសែត **គីម សំអែល** ទី ៤ ថតឆ្នាំ ១៩៧៤

7. -កាសែត **ពៅ ស៊ីផូ** ទី ១ ថតឆ្នាំ ១៩៧៤

-កាសែត **ពៅ ស៊ីផូ** ទី ១ ថតឆ្នាំ ១៩៧៥

8. -កាសែត **ទ្វីស ! ទ្វីស ! ខ្ញុំ** (ឯល ប៊ុនណា ១) ថតឆ្នាំ ១៩៧៣

-កាសែត **ម្លប់ពោធិ៍បាក់ខែង** (ឯល ប៊ុនណា ២) ថតឆ្នាំ ១៩៧៣

9. -កាសែត **កម្លោះហុងដា កញ្ញាប៉េសេ** ថតឆ្នាំ ១៩៧៤

១០. -កាសែត **រំដួលស្ទឹងសង្កែ** ថតឆ្នាំ ១៩៧៤

11. -កាសែត **សំណព្វចិត្ត** ថតឆ្នាំ ១៩៧៥
12. -កាសែត **រូបអូនហ្លឹងហើយ** ថតឆ្នាំ ១៩៧៥
13. -កាសែត **អានុស្សាវរីយ៍បីខេត្ត** ថតឆ្នាំ ១៩៧៥
14. -កាសែត **ភម្លោះឡានក្រហម** ថតឆ្នាំ ១៩៧៥
15. -កាសែត **អានុស្សាវរីយ៍ផ្ទៃសមុទ្រខ្មែរ** ថតឆ្នាំ ១៩៧៥
16. -កាសែត **ក្រមុំមិនមែនមេម៉ាយ** ថតឆ្នាំ ១៩៧៣
17. -កាសែត **កំតែមតែខ្លួន** ថតឆ្នាំ ១៩៧៤
18. -កាសែត **ភកាភិភី** ថតឆ្នាំ ១៩៧៤

-ចម្រៀងស្នេហាជាតិ ទី ១ ដើមទ.វឆ្នាំ ១៩៧០

-ចម្រៀងស្នេហាជាតិ ទី ២ ដើមទ.វឆ្នាំ ១៩៧០

-ចម្រៀងស្នេហាជាតិ ទី ៣ ដើមទ.វឆ្នាំ ១៩៧០

-ចម្រៀងស្នេហាជាតិ ទី ៤ ដើមទ.វឆ្នាំ ១៩៧០

-បទសម្ភាសន៍ អ្នកស្រី **ហួយ មាស** ជាមួយ អ្នកស្រី **ម៉ៅ សារ៉េត**

-បទសម្ភាសន៍ អ្នកស្រី **ហួយ មាស** ជាមួយ អ្នកស្រី **ស៊ឹម ទូច**

-បទសម្ភាសន៍ អ្នកស្រី **ហួយ មាស** ជាមួយ លោក **ស៊ុះ ម៉ាត់**

-ចម្រៀងថតថាស **ស៊ីន ស៊ីសាមុត** សុទ្ធ មាន ៤៦ វ៉ុល

-ចម្រៀងថតថាស **រស់ សេរីសុទ្ធា** សុទ្ធ មាន ២៣ វ៉ុល

-ចម្រៀងថតថាស **ប៉ែន រ៉ន** សុទ្ធ មាន ១០ វ៉ុល

-ចម្រៀងថតថាសឆ្លើយឆ្លង សាមុត-ប៉ែន រ៉ន មាន ៦ វ៉ុល

-ចម្រៀងថតថាសឆ្លើយឆ្លង សាមុត-សុទ្ធា មាន ១៣ វ៉ុល

-ចម្រៀងលោក អ៊ុង ណារី សុទ្ធ មាន ៦ វ៉ុល

-ចម្រៀងលោក អ៊ិន យ៉េង សុទ្ធ មាន ៣ វ៉ុល

-ចម្រៀងលោក ស៊ុះ ម៉ាត់ សុទ្ធ មាន ៤ វ៉ុល

-ចម្រៀងលោក មាស សាម៉ន សុទ្ធ មាន ៤ វ៉ុល

-ចម្រៀងលោក អ៊ឹម សុងសឺម សុទ្ធ មាន ៣ វ៉ុល

-ចម្រៀងលោក យិន ឌីកាន សុទ្ធ មាន ២ វ៉ុល

-ចម្រៀងលោក មាស ហុកសេង សុទ្ធ មាន ២ វ៉ុល

-ចម្រៀងលោក ជា សាវឿន សុទ្ធ មាន ២ វ៉ុល

-ចម្រៀងលោក ថេត សម្បត្តិ សុទ្ធ មាន ១ វ៉ុល

-ចម្រៀងលោក តូច តេង-អ៊ូ សន-តាត សំណាង មាន ១ វ៉ុល

-ចម្រៀងលោក គង់ ផាណូ-គង់ សំអឿន-គង់ ចន្ថា មាន ១ វ៉ុល

-ចម្រៀងលោក ទ័រ សារុន សុទ្ធ មាន ១ វ៉ុល

-ចម្រៀងលោក ទូច ចំរើន-ត្រង់ជី មាន ១ វ៉ុល

-ចម្រៀងលោក ឌុច គឹមហាក់ សុទ្ធ មាន ១ វ៉ុល

-ចម្រៀងលោក យស អូឡារាំង សុទ្ធ មាន ១ វ៉ុល

-ចម្រៀងអ្នកស្រី ហួយ មាស សុទ្ធ មាន ៦ វ៉ុល

-ចម្រៀងអ្នកស្រី ស៊ូ សាវឿន សុទ្ធ មាន ៦ វ៉ុល

-ចម្រៀងអ្នកស្រី ម៉ៅ សារ៉េត សុទ្ធ មាន ៣ វ៉ុល

- ចម្រៀងអ្នកស្រី ឈុន វណ្ណា សុទ្ធ មាន ២ វ៉ុល
- ចម្រៀងអ្នកស្រី ឈួន ម៉ាឡៃ សុទ្ធ មាន ១ វ៉ុល
- ចម្រៀងអ្នកស្រី តារា ចោចន័ សុទ្ធ មាន ១ វ៉ុល
- ចម្រៀងអ្នកស្រី កែវ មន្ថា សុទ្ធ មាន ១ វ៉ុល
- ចម្រៀងអ្នកស្រី ហៃ សុខុម-នូវ ណារិន មាន ១ វ៉ុល
- ចម្រៀងអ្នកស្រី កែវ សុខា-កែវ សេដ្ឋា-ឌី សាខន-ជួប សារឿន មាន ១ វ៉ុល
- ចម្រៀងអ្នកស្រី សៀង វ៉ាន់ធី-កុយ សារឹម-ប៉ែន រ៉ម មាន ១ វ៉ុល
- ចម្រៀងអ្នកស្រី ពៅ វណ្ណារី មាន ៣ វ៉ុល
- ចម្រៀង ឆ្លោះ (បទភ្លេងដូចគ្នា តែច្រៀងម្តងម្នាក់) មាន ១១ វ៉ុល
- ចម្រៀងព្រះរាជនិពន្ធដោយ សម្តេចឪ មាន ១ វ៉ុល
- ភាពយន្ត "អប្សរា" មានរូបលោក ស៊ីន ស៊ីសាមុត ក្នុងនោះ មាន ១ វ៉ុល

## ចម្រៀងជ្រើសរើសតាមចង្វាក់សុទ្ធ

- ជ្រើសរើសចង្វាក់ រាំវង់ សុទ្ធ មាន ២៥ វ៉ុល
- ជ្រើសរើសចង្វាក់ រាំក្បាច់ សុទ្ធ មាន ៥ វ៉ុល
- ជ្រើសរើសចង្វាក់ សារ៉ាវ៉ាន់ សុទ្ធ មាន ៧ វ៉ុល
- ជ្រើសរើសចង្វាក់ ឡាំលាវ សុទ្ធ មាន ៣ វ៉ុល
- ជ្រើសរើសចង្វាក់ តាលុង សុទ្ធ មាន ២ វ៉ុល
- ជ្រើសរើសចង្វាក់ ប្រពៃណី (ភ្លេងការ) សុទ្ធ មាន ៧ វ៉ុល
- ជ្រើសរើសចង្វាក់ បូឡេរ៉ូ សុទ្ធ មាន ៦ វ៉ុល

-ជ្រើសរើសចង្វាក់ ឆា ឆា ឆា សុទ្ធ មាន ៩វ៉ុល

-ជ្រើសរើសចង្វាក់ ម៉ាឌីហ្សុន សុទ្ធ មាន ១ វ៉ុល

-ជ្រើសរើសចង្វាក់ Jerk សុទ្ធ មាន ១១ វ៉ុល

-ជ្រើសរើសចង្វាក់ Twist សុទ្ធ មាន ៤ វ៉ុល

-ជ្រើសរើសចង្វាក់ Tango សុទ្ធ មាន ៣ វ៉ុល

## ចម្រៀងជ្រើសរើសតាមខេត្ត-ក្រុង

-ចម្រៀងខេត្ត បាត់ដំបង សុទ្ធ មាន ៤ វ៉ុល

-ចម្រៀងខេត្ត ប៉ៃលិន សុទ្ធ មាន ២ វ៉ុល

-ចម្រៀងខេត្ត កណ្ដាល សុទ្ធ មាន ២ វ៉ុល

-ចម្រៀងខេត្ត ភ្នំពេញ សុទ្ធ មាន ២ វ៉ុល

-ចម្រៀង អុំទូក សុទ្ធ មាន ២ វ៉ុល

-ចម្រៀង ភ្ជុំបិណ្ឌ សុទ្ធ មាន ២ វ៉ុល

-ចម្រៀងខេត្ត កំពត សុទ្ធ មាន ១ វ៉ុល

-ចម្រៀងខេត្ត កំពង់ឆ្នាំង សុទ្ធ មាន ១ វ៉ុល

-ចម្រៀងខេត្ត សៀមរាប សុទ្ធ មាន ១ វ៉ុល

-ចម្រៀងខេត្ត ពោធិសាត់-បន្ទាយមានជ័យ មាន ១ វ៉ុល

-ចម្រៀងខេត្ត រតនគិរី-មណ្ឌលគិរី មាន ១ វ៉ុល

-ចម្រៀងខេត្ត កំពង់ធំ-តាកែវ-ស្ទឹងត្រែង មាន ១ វ៉ុល

-ចម្រៀងខេត្ត កំពង់ស្ពឺ-ក្រចេះ-ឧត្តរមានជ័យ មាន ១ វ៉ុល

## ចម្រៀងជ្រើសរើសេង.វឆ្នាំ ១៩៨០

_ចម្រៀងលោក កែវ សារ៉ាត់ មាន ១៦ វ៉ុល

_ចម្រៀងលោក ធីង ស៊ុន មាន ៣ វ៉ុល

_ចម្រៀងលោក កុយ វណ្ណា មាន ៣ វ៉ុល

_ចម្រៀងលោក ឈួយ សុភាព សុទ្ធ មាន ២០ វ៉ុល

_ចម្រៀងលោក ម៉ុន ចាន់ថន មាន ៤ វ៉ុល

_ចម្រៀងលោក ម៉ុន ចាន់ថន មាន ១ វ៉ុល

_ចម្រៀងលោក គាង យុទ្ធហាន

_ចម្រៀងលោក នី សាលឿន

_ចម្រៀងលោក ពៅ ហ៊ុន

_ចម្រៀងលោក រ៉ម រ៉ុន_ធីង ភិរម្យ......

_ចម្រៀងអ្នកស្រី សុង សេងហ៊ន មាន ៦ វ៉ុល

_ចម្រៀងអ្នកស្រី មាស សុម៉ាលី មាន ២ វ៉ុល

_ចម្រៀងអ្នកស្រី ឆោម ឆវិន មាន ៣ វ៉ុល

_ចម្រៀងអ្នកស្រី ស៊ិន សុវណ្ណារី មាន ១ វ៉ុល

_ចម្រៀងអ្នកស្រី អ៊ុន សុផល មាន ១ វ៉ុល

_ចម្រៀងអ្នកស្រី មាស សុម៉ាលី មាន ២ វ៉ុល

_ចម្រៀងអ្នកស្រី ឡុង ស៊ីដា មាន ២ វ៉ុល

និងអ្នកចម្រៀងល្បីៗជាច្រើនទៀត...........


សេង តារា
ឆ្នាំ ១៩៧៣
ឆ្នាំ ១៩៧៤









សេង តារា
កែវ សារ៉ាត់
ទី២
បងសុំថតមួយ

# សូមកុំភ្លេច !

ប្រសិនបើមិត្តអ្នកអានចង់បានចម្រៀងពិរោះៗ
ដែលរៀបរៀងតាមច្បាប់ដើមទាំងនោះស្តាប់
កំសាន្តនិងតំកល់ទុកជាឯកសារផ្ទាល់ខ្លួនតាម
ផ្ទះសូមទាក់ទងខ្ញុំបាទ សេង តារា
តាមរយៈ ០១២ ៣០៦ ៨៥៣ ២

បើយើងមានចម្រៀងទាំងនោះតំកល់តាមផ្ទះ មានន័យថា
យើងទាំងអស់គ្នាគឺជាអ្នកចូលរួមចំណែកយ៉ាងធំធេងក្នុង
ការថែរក្សា ការពារនូវ"មរតកមាស"និងវិស័យ
តូរតន្ត្រីរបស់ជាតិយើងរបស់ជាតិយើងមិនឱ្យ
ឱ្យបាត់បង់តាមពេលវេលាឡើយ

**សូមអរគុណ !**

# កវីនិពន្ធខ្មែរ

## ដែលយើងគ្រប់គ្នាគួរតែ

## ស្គាល់ និង ចងចាំ

# កំពូលកវីជើងចាស់ទាំងពីរ





# កំពូលកវីមនោសញ្ចេតនាទាំងពីរ





# កំពូលតន្ត្រីករវីយូឡុងទាំងពីរ



ហាស់ សាឡន



# កំពូលតន្ត្រីករខ្លុយដែកទាំងពីរ





# កំពូលអ្នកនិពន្ធបទភ្លេង និងសម្រួលតន្ត្រី



ហោល ហ្វើម



ហ៊ឹម ស៊ីវន

# អ្នកនិពន្ធបទភ្លេង ទំនុកច្រៀង និងសម្រួលតន្ត្រី



គឹម សំអេត



ម៉ែរ ប៊ុន

# កវីសំបូរវោហាស័ទាំងពីរ





## អ្នកនិពន្ធបទភ្លេង ទំនុកច្រៀង និងតន្ត្រីករវីយូឡុង





# កំពូលតន្ត្រីករត្រុំប៉ែតដ៏ល្បីល្បាញទាំងពីរ



ទូច ឈៀង



ហ៊ឹម ស៊ីវន

តន្ត្រីករអាក់គំរដេអុង អ្នកនិពន្ធបទភ្លេង ទំនុកច្រៀង



ហ៊ាយ ស៊ី



យិន សំអូរ

## តន្ត្រីករត្រុំប៉ែត អ្នកនិពន្ធបទភ្លេង និងសម្រួលតន្ត្រី





## កំពូលអ្នកវាយស្គរដ៏ល្បីល្បាញទាំងពីរ





តន្ត្រីករផ្លុំសាក់សូ



ប៉ាន់ រស្មី

តន្ត្រីករហ្គីតាសូឡូ



ប៉ាន់ ស៊ីផុន

អ្នកនិពន្ធបទភ្លេង ទំនុកច្រៀង



ហ៊ឹម សារិន

អ្នកទំនុកច្រៀង ល្ខោននិយាយ



មាណុ គុម

## អ្នកនិពន្ធទំនុកច្រៀង អ្នកនិពន្ធរឿងល្ខោននិយាយ






## កំពូលវិចិត្រករជក់ទិព្វ អ្នកនិពន្ធប្រលោមលោកដ៏ល្បីល្បាញ







ប៉ឹម ប៊ុនណារ៉េយ



ទៀង នឌី



ហួ ឡៀ

តន្ត្រីករហ្គីតា



អ្នកអង្គម្ចាស់

ស៊ីសុវត្ថិ ចិណ្ណាពី សីវុឌ្ឍ

ម្ចាស់បទ" អានី និង បាត់អូន"

# អ្នកចំរៀងជំនាន់មុន ដែលកូនខ្មែរគួរតែ ស្គាល់ និង ចងចាំ





អធិរាជសំឡេងមាស រាជនីសំឡេងមាស

ស៊ីន ស៊ីសាមុត រស់ សេរីសុទ្ធា





អ៊ុះ ង៉ាវ
ម្ចាស់បទ "ផ្ញើកងចងដៃ"

ប៉ែន រ៉ន
ម្ចាស់បទ "ជើងមេឃពណ៌ខ្មៅ"



មាស ហុកសេង

ម្ចាស់បទ "លលកញីពេញ្ញាល"



ហ៊ៅ សារ៉េត

ម្ចាស់បទ "មេឃខ្មៅងងឹត"



ហាស សាម៉ឺន

ម្ចាស់បទ "មេឃុំកម្លោះ"



រស់ សាបឿត

ម្ចាស់បទ "ស្ពានកំពង់ហ្លួង"



វ៉ាន់ ស៊ែនហុង
ម្ចាស់បទ"ស្រីខ្មៅមាសបង"



ប៉ែន សេរ៉ុម
ម្ចាស់បទ"កាត្រីដួងតាត្រី"



ស៊ន ទេស
ម្ចាស់បទ"ញញឹមណាក់ខ្ពង់"



ប៉ែន ស្ងួន
ម្ចាស់បទ"ក្លិនថាប់ណាតរា"



អ៊ឹម សុងសឺម

ម្ចាស់បទ "ខ្មៅអើយខ្មៅ"



អ្នកម្នាង សៀង ឌី

ម្ចាស់បទ "គន់មើលផ្កាយ"



អ៊ឹង ស៊ើម

ម្ចាស់បទ "ឈាត្តីភ្លើងថ្មី"



សៀង វ៉ាន់ធី

ម្ចាស់បទ "សារិកាក្នុងទ្រុងដែក"



ជា សាវឿន
ម្ចាស់បទ "វាលស្រែមួយរយ"



ហួយ មាស
ម្ចាស់បទ "រាត្រីសេគុង"



អ៊ឹម សឹម
ម្ចាស់បទ "ស្រណោះភ្លៀង"



ប៉ែន រ៉ន
ម្ចាស់បទ "ខ្យល់កំពូលភ្នំ"



ម្ចាស់បទ"ខ្ញើស ! ខ្ញើស ! ខ្ញុំ"



ម្ចាស់បទ"កំប្រុកខាំដៃ"



ម្ចាស់បទ"ពលទោរអើញ"



ម្ចាស់បទ"អែមាស"



ឡុង ណារិន
ម្ចាស់បទ"ភក្តីស្នេហ៍"



ហ៊ែម សុវណ្ណ
ម្ចាស់បទ"អូនអើយស្លាប់ផ្ការ"



ប៉ិក ណារុន
ម្ចាស់បទ"ម៉ាក់ស៊ីនាវី"



ពៅ វណ្ណារី
ម្ចាស់បទ"ទឹកហូរ"



ម៉ង់ គឹមហាក់

ម្ចាស់បទ"អណ្ដាតអស់ឆ្អឹង"



អ៊ឹង ឈួ

ម្ចាស់បទ"ថ្ងៃជំជីវិតគុក"



ម សុខុត

ម្ចាស់បទ"សំណោកភ្នំតាម៉ៅ"



ទាត ចោមច័ន្ទ

"បងនៅស្នេហ៍អូនដូចថ្ងៃមុនទេ ?"



ប៉ែន សារឿន

ម្ចាស់បទ "មុខហ្នឹងរាងហ្នឹង"



ម៉ុល ណារ៉ាទិ

ដៃគូលោក ស សុខុម



ពេជ្រ សារឿន

ម្ចាស់បទ "ប្តីលាក្រចេះ"



សុត សុខា

ម្ចាស់បទ "ប្លែកណាស់ថ្ងៃនេះ"



ក្រាំ ឈឿសារ

ម្ចាស់បទ"ស្ទឹងស្លាគ្លូ"



ភ្លៃម សារឹម

ម្ចាស់បទ"ចង់បណ្ដើរប្ដី"



ទ៉ិង ស៊ីវយឿន

ម្ចាស់បទ"អានុស្សាវរីយ៍កាំពី"



ពេសាហ្ស សារ៉ម

ដៃគូលោក ស សុខុម



ប៉ែន រ៉ាម

ប្អូនអ្នកស្រី ប៉ែន រ៉ន



ហ៊ាច់ ស្វើ

ម្ចាស់បទ"សោកំណាមាសបង"



អ៊ី សុខន

ម្ចាស់បទ"ផ្កាត្របែកព្រៃ"



អ៊ឹម សាវឿន

ម្ចាស់បទ "បើស្រលាញ់អូនពិត



ប៉ា សំអឿន



ប៉ុល កាប៉ាច

ម្ចាស់បទ"លាអ្នកម្ដាយមានគុណ"



[illegible]

ម្ចាស់បទ"ស្នែកមួយពាន់ដង"



យស់ អូឡារាំង

ម្ចាស់បទ"យុវជនខូចចិត្ត"

# អ្នកចម្រៀងល្បីៗអំឡុងទ.វឆ្នាំ ១៩៨០-១៩៩០



កែវ សារ៉ាត់

ម្ចាស់បទ "ពិសាខដើមឆ្នាំ"



ឡុង ស៊ីម

ដៃគូលោក កែវ សារ៉ាត់



ឃួង ម៉ាឡៀ



ចន្ធូ

ដៃគូលោក កែវ សារ៉ាត់



ម្រេស ជំពា

ដៃគូលោក កែវ សារ៉ាត់



ទី ស្រ៊ីខៀវ

ដៃគូលោក កែវ សារ៉ាត់



ហាណ ស្វាន

ជំនាន់លោក កែវ សារ៉ាត់



ម៉ូខ សុខុម

ដៃគូលោក កែវ សារ៉ាត់



ឈួយ សុភាព
ម្ចាស់បទ"ជីថ្មីចិត្តថ្មី"



ដល្លីន
ដៃគូលោក ឈួយ សុភាព



ស៊ីក សុផាត់
ដៃគូលោក ឈួយ សុភាព



ឈួយ សុផាត
ដៃគូលោក ឈួយ សុភាព



ហាស សុម៉ាលី

ម្ចាស់បទ "ប្រុសល្អភ្លេចខ្ញុំ"



ហ៊ឹម ស៊ីវន

ដៃគូលោក ឈួយ សុភាព



ម៉ឹក សៀងសំណាង

ម្ចាស់បទ "នាគពន្លឺអស់ពិស"



ហ៊ុង សេងហ៊ន

ម្ចាស់បទ "ខ្ញុំបានរូបថត គេបានបង"



ស៊ុន ចាន់ថន

ម្ចាស់បទ"កុំស្រលាញ់ស្រីក្នុងវ័យសិក្សា"



ណូ ឡាវ៉ៃ

ម្ចាស់បទ"អាល័យក្លិនអួន"



គាង យុទ្ធហាន

ម្ចាស់បទ"ចិន្ត្រាក្មេងកំព្រា"



ណូ សារឿន

ម្ចាស់បទ"ផងស្ទើរឡូវើល"



ឈួយ វ៉ាន់សេរី

ម្ចាស់បទ "បងសុំក្រអាមួយគាំ"



ជំណា សៀង

អ្នកចម្រៀងនៅប្រទេសបារាំង



អ៊ឹង ភិរម្យ

ម្ចាស់បទ "ភូមាឆ្លាក់លលក"



ពៀង ហ៊ុក

ម្ចាស់បទ "ស្រវឹងស្រា"

## នាមព្រះមហាក្សត្រខ្មែរតាំងពីដំនាន់ដើមដល់សព្វថ្ងៃ

កម្រងប្រវត្តិសាស្ត្រខ្មែរសង្ខេបនេះ ខ្ញុំដកស្រង់ចេញពីសៀវភៅ "**ប្រវត្តិវិទ្យាសំរាប់ថ្នាក់បឋមសិក្សា**" សុទ្ធសាធ ចេញផ្សាយដោយក្រសួងអប់រំ ។ ចំណែកក្នុងសៀវភៅ "**ផ្ការំចសពត់ស**" ភាគ ១ ខ្ញុំដកស្រង់ពីសៀវភៅ "**ប្រវត្តិវិទ្យាសំរាប់ថ្នាក់បឋមសិក្សា**" ផងនិងសៀវភៅ "Who'sWho" ផង ។ ដូច្នេះព្រះនាមរបស់ព្រះមហាក្សត្រខ្លះ និងកាលបរិច្ឆេទមួយចំនួនខុសគ្នា ។ ហេតុនេះដើម្បីកុំឱ្យមានការស្មុគស្មាញ ក្នុងសៀវភៅ "**ថ្ងៃលិចឯនាយសមុទ្រ**" ភាគ ៨ នេះ ខ្ញុំសូមដកស្រង់ចេញតែពីសៀវភៅ "**ប្រវត្តិវិទ្យាសំរាប់ថ្នាក់បឋមសិក្សា**" ចេញផ្សាយដោយក្រសួងអប់រំតែប៉ុណ្ណោះដើម្បីជៀសវាងការទិតៀនរិះគន់ផ្សេងៗពីអ្នកអានបើខុស គឺខុសតាមក្រសួងអប់រំដែរ ។

ខ្ញុំមិនមែនជាប្រវត្តិសាស្ត្រវិទូទេ ក៏ប៉ុន្តែដោយសារកាលពីពាក់កណ្ដាលឆ្នាំ ២០១១ កន្លងទៅ លោកគ្រូខ្ញុំម្នាក់ដែលបង្រៀននៅវិទ្យាល័យព្រែកតាដួងក្នុងស្រុកកោះធំ ខេត្តកណ្ដាល បានសំណូមពរឱ្យខ្ញុំធ្វើការងារនេះខ្ញុំក៏រៀបចំកំណត់ត្រានេះដើម្បីបំពេញបំណងរបស់គាត់ និងសំរាប់អស់លោកកូនខ្មែរទាំងឡាយ ដែលជាទូទៅខ្ជិលអានប្រវត្តិសាស្ត្ររបស់ខ្លួនដែលសរសេរលំអិតវែងៗនោះ ។

## សម័យ នគរភ្នំ (ហ្វូណន) ឬសម័យមុនអង្គរ

០១- ព្រះនាង លីវ យី (នាងនាគ) សោយរាជ្យមុនគ.សដល់គ.សឆ្នាំ ៦៨

០២- ព្រះបាទ ហ៊ុន ទាន (ព្រះថោង) សោយរាជ្យពីឆ្នាំ ៦៨ ដល់ ........?

ប្រវត្តិសាស្ត្រខ្មែរដំបូងតាំងពីចំណុចនេះមិនសូវច្បាស់លាស់ពីកាលបរិច្ឆេទទេ

០៣- ព្រះបាទ ហ៊ុន ផាន់ហួន សុគតនៅដើមស.វទី៣ នៃគ.ស ព្រះជន្ម ៩០ ព្រះវស្សា ។

០៤- ព្រះបាទ ផាន់ ផាន់ សោយរាជ្យ.......? សុគត.......?

០៥- ព្រះបាទ ហ្វាន់ ឆេម៉ាន់(ស្រីមារៈ) សោយរាជ្យ......? សុគតរវាងឆ្នាំ ២២៥

០៦- ព្រះបាទ ហ្វាន់ ចាន់ សោយរាជ្យ.......? សុគត.......?

០៧- ព្រះបាទ ហ្វាន់ ស៊ីយ៉ុន សោយរាជ្យ.......? សុគត.......?

០៨- ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន សោយរាជ្យ.......? សុគតឆ្នាំ ៥១៥

ចាប់ពីពេលនោះមក ប្រវត្តិសាស្ត្រប្រែប្រួលច្រើន នគរភ្នំធ្លាក់ទន់ខ្សោយនាំឱ្យស្តេចនគរចេនឡា វាយប្រហារឈ្នះហើយឡើងសោយរាជ្យបន្តបន្ទាប់...នៅឆ្នាំ ៥៥០ ព្រះរាជានគរចេនឡាព្រះនាមភវវរ្ម័នទី១ និងព្រះអនុជព្រះនាមចិត្រសេន បានលើកទ័ពចូលវាយនគរភ្នំ ហើយបានគ្រប់គ្រងនគរភ្នំរហូតដល់ទំនាបនៃដងទន្លេមេគង្គ ។ ព្រះមហាក្សត្រសម័យចេនឡាដែលសោយរាជ្យបន្តបន្ទាប់សុទ្ធតែមានឫទ្ធានុភាពខ្លាំងពូកែ ក៏ប៉ុន្តែពុំមានឯកសារបញ្ជាក់ពីកាលបរិច្ឆេទច្បាស់លាស់ទេ ។ រហូតមកដល់រាជព្រះបាទ ឥសានវរ្ម័ន (៦១៥-៦៣៥) នគរចេនឡានបានគ្រប់គ្រងលើនគរភ្នំទាំងមូល ។

## សម័យ ចេនឡា

០១- ព្រះបាទ ឥសានវរ្ម័ន សោយរាជ្យឆ្នាំ ៦១៥ សុគតឆ្នាំ ៦៣៥

០២- ព្រះបាទ ភវវរ្ម័ន ទី ២ សោយរាជ្យឆ្នាំ ៦៣៩ សុគតឆ្នាំ ៦៥៤

០៣- ព្រះបាទជ័យវរ្ម័នទី ១ សោយរាជ្យឆ្នាំ ៦៥៥ សុគតឆ្នាំ ៦៨១

ចាប់ពីរាជ្យស្ដេចអង្គនេះមក "នគរភ្នំ" ត្រូវបាត់ឈ្មោះ ហើយអ្នកកត់ត្រាប្រវត្តិសាស្ត្របានដាក់ឈ្មោះប្រទេសខ្មែរថា "ចេនឡារួបរួម"វិញ ។ រីឯកាលបរិច្ឆេទ និងព្រះនាមមហាក្សត្រផ្សេងៗដែលសោយរាជ្យពីព្រះរាជាអង្គនេះមកក៏ពុំមានឯកសារសរសេរច្បាស់លាស់ដែរ គឺទាល់តែរហូតដល់សម័យអង្គរទើបមានភាពជាក់លាក់រហូតមក។

## សម័យ អង្គរ (ពីឆ្នាំ ៨០២ ដល់ឆ្នាំ ១៤៣១)

០១- ព្រះបាទ ជ័យវរ្ម័នទី ២ សោយរាជ្យឆ្នាំ ៨០២ សុគតឆ្នាំ ៨៥០

០២- ព្រះបាទ ជ័យវរ្ម័នទី ៣ សោយរាជ្យឆ្នាំ ៨៥០ សុគតឆ្នាំ ៨៧៧

០៣- ព្រះបាទ ឥន្ទ្រវរ្ម័នទី ១ សោយរាជ្យឆ្នាំ ៨៧៧ សុគតឆ្នាំ ៨៨៩

០៤- ព្រះបាទ យសោវរ្ម័នទី ១ សោយរាជ្យឆ្នាំ ៨៨៩ សុគតឆ្នាំ ៩០០

០៥- ព្រះបាទ ហសិវរ្ម័ន ទី ១ សោយរាជ្យឆ្នាំ ៩០០ សុគតឆ្នាំ ៩២២

គួរបញ្ជាក់ថា រហូតមកដល់ឆ្នាំ ៩២១ ព្រះបិតុលា(ពូ)របស់ ព្រះបាទ ហសិវរ្ម័នទី ១ ស្រាប់តែបានប្រកាសខ្លួនជាស្ដេចផែនដីដែរ ដោយដាក់ព្រះនាមខ្លួនឯងថា ព្រះបាទ ជ័យវរ្ម័នទី៤ហើយបានប្រមូលរេហ៍ពលដែលស្មោះត្រង់នឹងខ្លួនទៅតាំងរាជធានីនៅ កោះកេរ(សព្វថ្ងៃស្ថិតក្នុងខេត្តព្រះវិហារ)។ ដូច្នេះមានន័យថាគ្រានោះ នគរខ្មែរតែមួយតែមានស្ដេចពីរអង្គ ។ លុះឆ្នាំ ៩២២ ព្រះបាទ ហសិវរ្ម័នទី ១បានចូលទីវង្គត រួចព្រះអនុជ(ប្អូន) ព្រះនាម ឥសាណវរ្ម័នទី ២ បានឡើងសោយរាជ្យបន្ត។ ដូច្នេះព្រះអង្គជាព្រះមហាក្សត្រផ្លូវការ ទី៦នៃសម័យអង្គរ ។

០៦- ព្រះបាទ ឥសានវរ្ម័នទី ២ សោយរាជ្យឆ្នាំ ៩២២ សុគតឆ្នាំ ៩២៨

លុះព្រះរាជាអង្គនេះសុគតឆ្នាំ ៩២៨ ព្រះបិតុលា (ពូ) គឺព្រះបាទ ជ័យវរ្ម័នទី ៤ ដែលប្រកាសខ្លួនជាស្តេចតាំងពីឆ្នាំ ៩២១នោះក៏បានគ្រប់គ្រងនគរខ្មែរទាំងមូល ចាប់ពីពេលនោះមក ។ ដូច្នេះគេអាចចាត់ទុកថា តាំងពីពេលនោះមកព្រះអង្គ ជាព្រះមហាក្សត្រផ្លូវការទី៧នៃសម័យអង្គរ ។

០៧- ព្រះបាទ ជ័យវរ្ម័នទី ៤ សោយរាជ្យឆ្នាំ ៩២៨ សុគតឆ្នាំ ៩៤១

០៨- ព្រះបាទ ហសិវរ្ម័ន ទី ២ សោយរាជ្យឆ្នាំ ៩៤១ សុគតឆ្នាំ ៩៤៤

០៩- ព្រះបាទ រាជិន្ទ្រវរ្ម័នទី ២ សោយរាជ្យឆ្នាំ ៩៤៤ សុគតឆ្នាំ ៩៦៨

១០- ព្រះបាទ ជ័យវរ្ម័នទី ៥ សោយរាជ្យឆ្នាំ ៩៦៨ សុគតឆ្នាំ ១០០១

១១- ព្រះបាទ ឧទយាទិត្យវរ្ម័ន ទី ១ សោយរាជ្យឆ្នាំ១០០១ សុគតឆ្នាំ ១០០២

មហាក្សត្រអង្គនេះសោយរាជ្យបានបន្តិចស្រាប់តែបាត់ព្រះកាយគ្មានមូលហេតុ ពេលនោះនគរខ្មែរក៏មានចលាចលគ្រប់ទីកន្លែង ។ អ្នកជាប់សាច់សារលោហិត ក្សត្រទាំងជាច្រើនបានប្រមូលគ្នាជាបក្សពួកហើយប្រកាសខ្លួនជាស្តេចគ្រប់ៗគ្នា នាំឱ្យនគរខ្មែរបែងចែកជាច្រើនចំណែក ។

ឆ្នាំ ១០០២ ក្សត្រមួយអង្គព្រះនាម ជ័យវីរ្ម័ន បានប្រកាសសោយរាជ្យនៅក្រុង អង្គរ(យសោធបុរៈ) ។ រីឯក្សត្រមួយអង្គទៀតព្រះនាម សុរិយវរ្ម័នទី ១ បាន ប្រកាសសោយរាជ្យនៅនគររាជ(កូរ៉ាត) ។ ក្សត្រអង្គនេះអះអាងថា ព្រះអង្គ ជាញាតិវង្សនៃព្រះបាទឥន្ទ្រវរ្ម័ន ដូច្នេះទ្រង់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុង គ្រប់គ្រងនគរទាំងមូល ។ រហូតមកដល់ឆ្នាំ ១០០៦ ព្រះបាទ សុរិយវរ្ម័នទី ១ បានលើកទ័ពពីនគររាជដើម្បីរំលំព្រះបាទ ជ័យវីរ្ម័ន ពីក្រុងអង្គរ ប៉ុន្តែចំបាំងនេះ គ្មានខាងណាចាញ់ឈ្នះទេ ទាល់តែមកដល់ឆ្នាំ ១០១០ ទើបព្រះបាទសុរិយវរ្ម័ន

ទី ១ បង្ក្រាបបានទាំងស្រុងហើយឡើងសោយរាជ្យពេញលេញលើនគរខ្មែរចាប់តាំងពីពេលនោះមក ។ ដូច្នេះយើងអាចកត់ត្រាទុកថា ព្រះបាទសុរិយវរ្ម័នទី ១ គឺជាព្រះមហាក្សត្រទី ១២ ក្នុងសម័យអង្គរ ។

១២- ព្រះបាទ សុរិយវរ្ម័នទី ១ សោយរាជ្យឆ្នាំ ១០១០ សុគតឆ្នាំ ១០៥០

១៣- ព្រះបាទឧទយាទិត្យវរ្ម័ន ទី ២ សោយរាជ្យឆ្នាំ ១០៥០ សុគតឆ្នាំ ១០៦៦

១៤- ព្រះបាទហសិវរ្ម័ន ទី ៣ សោយរាជ្យឆ្នាំ ១០៦៦ សុគតឆ្នាំ ១០៨០

ឆ្នាំ ១០៨០ ក្សត្រអង្គនេះបាត់ព្រះកាយដោយគ្មានមូលហេតុ ដំណាលគ្នានោះស្រាប់តែមានអភិជនម្នាក់ដែលនៅភាគខាងជើងនគរខ្មែរ (ស្ថិតជ្រង់ទន្លេមូនទឹកដីថៃសព្វថ្ងៃ) បានប្រកាសខ្លួនជាស្តេចចាប់ពីពេលនោះមក ហើយហៅព្រះនាមខ្លួនឯងថា ជ័យវរ្ម័ន ទី ៦ ។ បែរមកក្រុងអង្គរវិញ ក៏មានក្សត្រមួយអង្គព្រះនាមនព្វបតីន្ទ្រវរ្ម័ន ទី២ បានប្រកាសឡើងគ្រងរាជ្យដែរ ។ ដូច្នេះ នគរខ្មែរតែមួយមានស្តេចពីរអង្គនៅគ្រានោះ ។ ទោះយ៉ាងណាក្តី យើងមិនអាចបដិសេធប្រវត្តិសាស្ត្រនេះបានទេ យើងអាចចាត់ទុកថា ក្សត្រទាំងពីរអង្គនេះជាស្តេចទី ១៥នៃសម័យអង្គរដូចគ្នា ដូច្នេះយើងសរសេរដូចខាងក្រោមនេះ :

១៥- ព្រះបាទនព្វបតីន្ទ្រវរ្ម័ន ទី ២ សោយរាជ្យឆ្នាំ ១០៨០ សុគតឆ្នាំ១១១៣

១៥- ព្រះបាទ ជ័យវរ្ម័ន ទី ៦ សោយរាជ្យឆ្នាំ ១០៨០ សុគតឆ្នាំ១១០៧

គួរបញ្ជាក់ថា នៅឆ្នាំ ១១០៧ បន្ទាប់ពីព្រះបាទ ជ័យវរ្ម័ន ទី៦ ដែលសោយរាជ្យនៅភាគជើងប្រទេសចូលទិវង្គតទៅ ព្រះអនុជ (ប្អូន) របស់ទ្រង់ដែលមានព្រះនាមថា ធរណិន្ទ្រវរ្ម័ន ក៏ឡើងសោយរាជ្យបន្ត ។ ចំណែកនៅក្រុងអង្គរ ព្រះបាទនព្វបតីន្ទ្រវរ្ម័ន ទី ២ នៅសោរាជ្យដដែល ។ មានន័យថានគរខ្មែរនៅតែមានព្រះ

ដដែលដែរ ។ ដូច្នេះព្រះបាទ ធរណិន្រ្ទវរ្ម័ន ដែលសោយរាជ្យនៅភាគខាងជើង បន្តពីព្រះរាម ក៏យើងនៅតែចាត់ទុកថា ជាស្តេចទី ១៥ នៃសម័យអង្គរដែរ ។ ត្រង់ចំណុចនេះ យើងឃើញថា ប្រវត្តិសាស្ត្រខ្មែរមានភាពច្របូកច្របល់ខ្លាំង តែវាជាសម័យ "អន្តរកាល" មួយដែលយើងទាំងអស់គ្នាត្រូវតែទទួលស្គាល់មិនអាចប្រកែកបាន ។ ទាល់តែរហូតមកដល់ឆ្នាំ ១១១៣ ទើបប្រវត្តិសាស្ត្រវិលទៅរកភាពប្រក្រតីឡើងវិញ ។ ដូច្នេះយើងអាចសរសេរថា

១៥- ព្រះបាទ ធរណិន្រ្ទវរ្ម័ន សោយរាជ្យឆ្នាំ ១១០៧សុគតឆ្នាំ១១១៣

ត្រង់ចំណុចនេះគួរបញ្ជាក់ថា នៅឆ្នាំ ១១០៧ គ្រាដែលព្រះបាទ ធរណិន្រ្ទវរ្ម័ន ឡើងសោយរាជ្យបន្តនៅភាគខាងជើង ស្រាប់តែមានក្សត្រមួយអង្គទៀតព្រះនាម សុរិយវរ្ម័នទី ២ដែលត្រូវជាភាគនេយ្យ( ក្មួយ) របស់ព្រះបាទ ធរណិន្រ្ទវរ្ម័ន លេចចេញមកដែរ តែក្សត្រអង្គនេះបានប្រមូលគ្នីគ្នាជាកងទ័ពធ្វើសង្គ្រាមចេញប្រឆាំងនឹងព្រះបិតុលា( ពូ) របស់ខ្លួនគឺព្រះបាទធរណិន្រ្ទវរ្ម័ន នេះ រួចក៏បានច្បាំងឈ្នះនិងបានធ្វើគុតព្រះបាទ ធរណិន្រ្ទវរ្ម័ន ជាម្ចាស់ពូនៅឆ្នាំ ១១១៣។ លុះបានឡើងសោយរាជ្យនៅភាគខាងជើងហើយ ព្រះបាទ សុរិយវរ្ម័នទី ២ ក៏នាំទ័ពមកធ្វើសង្គ្រាមជាមួយព្រះបាទ នប្បបតីន្រ្ទវរ្ម័ន ទី ២ ដែលសោយរាជ្យនៅក្រុងអង្គរទៀត ព្រោះពាក្យស្លោកមួយថែងថា "ភ្នំមួយមិនអាចមានខ្លាពីរ" បានទេ។ នៅឆ្នាំ១១១៣ ដដែលនោះ ព្រះបាទ សុរិយវរ្ម័នទី២ ក៏បានច្បាំងឈ្នះនិងធ្វើគុតព្រះបាទ នប្បបតីន្រ្ទវរ្ម័នទី ២ ផងដែរ។ ដូច្នេះព្រះបាទ សុរិយវរ្ម័នទី២ក៏បានគ្រប់គ្រងទឹកដីខ្មែរទាំងមូលនៅឆ្នាំ ១១១៣ នោះរហូតមកដល់ឆ្នាំ ១១៥០គឺមកដល់ថ្ងៃដែលព្រះអង្គចូលទិវង្គត ។ ដូច្នេះយើងអាចកត់ត្រាទុកថា ព្រះអង្គគឺជាក្សត្រទី

១៦ នៃសម័យអង្គរ ។ យើងសរសេរដូចខាងក្រោមនេះ :

១៦- ព្រះបាទ សុរិយវរ្ម័នទី ២ សោយរាជ្យឆ្នាំ១១១៣ សុគតឆ្នាំ១១៥០

គួរបញ្ជាក់ផងដែរថា គឺព្រះបាទ សុរិយវរ្ម័នទី ២ ដែលបានកសាងប្រាសាទអង្គរវត្តដែលល្បីល្បាញពេញពិភពលោកនោះ តែក្នុងរាជព្រះអង្គ ប្រាសាទអង្គរវត្តសាងសង់មិនទាន់រួចរាល់ទេ ។

១៧- ព្រះបាទ ធរណិន្ទ្រវរ្ម័ន ទី ២ សោយរាជ្យឆ្នាំ ១០៥០ សុគតឆ្នាំ១១៦០

១៨- ព្រះបាទ យសោវរ្ម័ន ទី ២ សោយរាជ្យឆ្នាំ ១០៦០ សុគតឆ្នាំ១១៦៥

១៩- ព្រះបាទ ត្រីភូវនាទិត្យវរ្ម័ន សោយរាជ្យឆ្នាំ ១០៦៥ សុគតឆ្នាំ១១៧៧

សូមបញ្ជាក់ថា នៅឆ្នាំ ១១៧៧ ព្រះបាទ ត្រីភូវនាទិត្យវរ្ម័ន ត្រូវកងទ័ពចាមនាំរេហ៍ពលមកវាយចូលដល់ក្រុងអង្គរ រួចបានធ្វើគុតក្សត្រអង្គនេះក្នុងគ្រានោះទៅ ។ ចាប់ពីឆ្នាំ ១១៧៧ នោះមក ចាមគ្រប់ក្រងនគរខ្មែរទាំងស្រុងអស់រយៈពេល៤ឆ្នាំ ។ ទាល់តែមកដល់ឆ្នាំ១១៨១ ទើបក្សត្រខ្មែរមួយអង្គដែលមានព្រះនាម ជ័យវរ្ម័នទី ៧ បានដឹកនាំទ័ពច្បាំងឈ្នះកងទ័ពចាមហើយដណ្តើមបាននគរខ្មែរទាំងមូលមកវិញ ហើយព្រះអង្គក៏ឡើងគ្រងរាជ្យនៅឆ្នាំនោះដែរ ។ ដូច្នេះព្រះអង្គគឺជាមហាក្សត្រទី ២០ នៃសម័យអង្គរ ។ យើងសរសេរថា :

២០- ព្រះបាទ ជ័យវរ្ម័នទី ៧ សោយរាជ្យឆ្នាំ ១១៨១ សុគតឆ្នាំ១២២០

សូមបញ្ជាក់ថា : គឺទាល់តែមកដល់រាជព្រះបាទ ជ័យវរ្ម័នទី ៧ នេះឯងទើបប្រាសាទអង្គរវត្តបានសាងសង់រួចរាល់ជាផ្លូវការ ។ជាមួយគ្នានោះគឺនៅក្នុងរាជ្យព្រះមហាក្សត្រអង្គនេះហើយដែលនគរខ្មែរត្រូវបានគេចាត់ទុកថា គឺជាសម័យកាលរុងរឿងបំផុតក្នុងប្រវត្តិសាស្ត្រ ។ ខ្មែរមានអំណាចអស្ចារ្យលើផែនដី ខ្លាំងទាំង

កងទ័ព សេដ្ឋកិច្ច នយោបាយ វប្បធម៌ ។ រីឯទឹកដីខ្មែរមហាធំធេងណាស់ រហូតគេចាត់ទុកថា ខ្មែរជាមហាអំណាចមួយលើលោកទៀតផង ។ គ្រានោះ ថៃមិនទាន់មានប្រទេសនៅឡើយទេ គឺគ្រាន់តែជាកុលសម្ព័ន្ធតូចៗប៉ុណ្ណោះ ។

២១- ព្រះបាទ ឥន្ទ្រវរ្ម័ន ទី ២ សោយរាជ្យឆ្នាំ ២២០១ សុគតឆ្នាំ១២៤៣

២២- ព្រះបាទ ជ័យវរ្ម័ន ទី ៨ សោយរាជ្យឆ្នាំ ២២៤៣ សុគតឆ្នាំ១២៩៥

២៣- ព្រះបាទ ឥន្ទ្រវរ្ម័ន ទី ៣ សោយរាជ្យឆ្នាំ ២២៩៥ សុគតឆ្នាំ១៣០៨

២៤- ព្រះបាទ ឥន្ទ្រជ័យវរ្ម័ន សោយរាជ្យឆ្នាំ ១៣០៨សុគតឆ្នាំ១៣២៧
ឬ ព្រះបាទ ស្រិន្ទ្រជ័យវរ្ម័ន

## ព្រះមហាក្សត្រសម័យចុងអង្គរ

មកដល់ចំណុចនេះ ឯកសារទូទៅទាំងអស់សុទ្ធតែសរសេរដូចៗគ្នាថា"មកដល់ពាក់កណ្ដាលសតវត្សទី ១៤នេះ ប្រវត្តិសាស្ត្រខ្មែរស្រាប់តែដាច់បាត់ឈឹង ។ អ្នកកត់ត្រាមានភាពស្រពិចស្រពិលមិនច្បាស់លាស់ គឺគេបែរជាសរសេរដោយយកលំនាំតាមរឿងនិទានរឿង"តាត្រសក់ផ្អែម"ទៅវិញ ។ ដូច្នេះពីពេលនោះមក ស្ដេចដែលមានសាច់សារលោហិតជាប់ក្សត្រសម័យអង្គរត្រូវរលាយដាច់ពូជអស់ ។ ឯមហាក្សត្រចាប់តាំងពីរជ្ជកាលនោះរហូតមកដល់សព្វថ្ងៃ គឺជាសាច់សារលោហិតរបស់ព្រះបាទត្រសក់ផ្អែមទៅវិញទេ ។

២៥- ព្រះបាទត្រសក់ផ្អែម សោយរាជ្យឆ្នាំ ១៣៣៦សុគតឆ្នាំ១៣៤០

២៦- ព្រះបាទនិព្វានបាទ សោយរាជ្យឆ្នាំ ១៣៤០សុគតឆ្នាំ១៣៤៦

២៧- ព្រះបាទ សិទ្ធានរាជា សោយរាជ្យឆ្នាំ ១៣៤៦សុគតឆ្នាំ១៣៤៦
(សោយរាជ្យបាន៦ខែក៏សុគត)

២៨- ព្រះបាទលំពង្សរាជា សោយរាជ្យឆ្នាំ ១៣៤៧សុគតឆ្នាំ១៣៥៣

ត្រង់ចំណុចនេះ សូមបញ្ជាក់ថា នៅឆ្នាំ១៣៥២ កងទ័ពសៀមបានវាយចូលក្រុងអង្គរហើយបានកាន់កាប់ក្រុងអង្គរទាំងមូល ។ សៀមកាន់កាប់នគរខ្មែរតាំងពីឆ្នាំ ១៣៥២ដល់ឆ្នាំ ១៣៥៧(៥ឆ្នាំ) ។មកដល់ឆ្នាំ១៣៥៧ ព្រះបាទស្រីសុរិយោវង្សទី ១ ដែលត្រូវជាក្មួយព្រះបាទលំពង្សរាជាបានដឹកនាំទ័ពវាយកម្ចាត់កងទ័ពសៀមទៅវិញអស់ ហើយរំដោះបានក្រុងអង្គរមកវិញ រួចព្រះអង្គក៏ឡើងសោយរាជ្យតាំងពីឆ្នាំនោះមកដល់ព្រះអង្គចូលទីវង្គតនៅឆ្នាំ ១៣៦៦ ។ ដូច្នេះយើងអាចកត់ត្រទុកថា ព្រះអង្គគឺជាព្រះមហាក្សត្រទី ២៩ នៃសម័យអង្គរ ។ យើងសរសេរដូចខាងក្រោមនេះ :

២៩- ព្រះបាទស្រីសុរិយោវង្សទី ១ សោយរាជ្យឆ្នាំ ១៣៥៧សុគតឆ្នាំ១៣៦៦

៣០- ព្រះបាទបរមរាជា សោយរាជ្យឆ្នាំ១៣៦៦ សុគតឆ្នាំ១៣៧៣

៣១- ព្រះបាទធម្មាសោក សោយរាជ្យឆ្នាំ១៣៧៣ សុគតឆ្នាំ១៣៩៤

សូមបញ្ជាក់ថា ក្នុងរាជព្រះបាទធម្មាសោក សៀមបាននាំកងទ័ពអុកឡុកនគរខ្មែរយ៉ាងខ្លាំង ហើយមេទ័ពខ្មែរមួយចំនួនក៏បានក្បត់ជាតិលក់ភាពស្មោះត្រង់ឱ្យសៀមគ្មានអៀនខ្មាស ។ ទីបំផុតសៀមក៏បានបើឧបាយកលយកឈ្នះខ្មែរហើយបានកាន់កាប់នគរខ្មែរតាំងពីឆ្នាំ ១៣៩៤ រហូតដល់ឆ្នាំ១៤០១ ។ នៅឆ្នាំ១៤០១ ទើបក្សត្រមួយអង្គព្រះនាម ស្រីសុរិយោវង្សទី ២ ដែលជាបុត្ររបស់ព្រះបាទស្រីសុរិយោទ័យ បាននាំទ័ពមករំដោះក្រុងអង្គរបានជោគជ័យ ហើយគ្រងរាជ្យរហូតដល់ព្រះអង្គចូលទីវង្គតនៅឆ្នាំ ១៤១៧ ។ ដូច្នេះព្រះអង្គគឺជាក្សត្រទី ៣២ នៃសម័យអង្គរ ។ ដូច្នេះយើងសរសេរថា :

៣២- ព្រះបាទ ស្រីសុរិយោវង្សទី ២ សោយរាជ្យឆ្នាំ១៤០១ សុគតឆ្នាំ ១៤១៧

៣៣- ព្រះបាទបរមសុខា សោយរាជ្យឆ្នាំ១៤១៧ សុគតឆ្នាំ ១៤២០

សូមបញ្ជាក់ថា ក្នុងអំឡុងឆ្នាំ ១៤២០ដល់ឆ្នាំ១៤២១ សៀមកាន់កាប់ក្រុងអង្គរជាថ្មីម្តងទៀត ។ ទាល់តែមកដល់ឆ្នាំ ១៤២១ ទើបព្រះបាទពញាយ៉ាតដែលជាបុត្រារបស់ព្រះបាទ ស្រីសុរិយោវង្សទី ២ ដឹកនាំទ័ពមកកម្ចាត់សៀមវិញ ។

៣៤- ព្រះបាទពញាយ៉ាត សោយរាជ្យឆ្នាំ១៤២១ សុគតឆ្នាំ ១៤៦២

ដោយសារក្រុងអង្គរត្រូវកងទ័ពសៀមចូលវាយប្រហារញឹកញាប់ពេក ព្រះបាទពញាយ៉ាតក៏នាំទ័ពចាកចោលក្រុងអង្គរហើយមកតាំងរាជធានីនៅ ស្រីសន្ធរ ឯខេត្តកំពង់ចាមវិញក្នុងឆ្នាំ ១៤៣១ ។ ១ ឆ្នាំក្រោយមកដោយឈ្វេងយល់ថា ទីនោះពុំសូវមានអំណោយផលល្អ ព្រះអង្គក៏បញ្ជាឱ្យនាម៉ឺនមន្ត្រីរៀបចំសាងសង់រាជធានីនៅចតុមុខវិញ ។រាជធានីថ្មីនេះ(ចតុមុខ) ត្រូវបានសាងសង់រួចជាស្ថាពរនៅឆ្នាំ ១៤៣៤ ។ ដូច្នេះសម័យអង្គរក៏ត្រូវបានបិទបញ្ចប់នៅឆ្នាំនោះគឺត្រឹមព្រះបាទពញាយ៉ាត នេះ ។ព្រះអង្គចូលទិវង្គតនៅឆ្នាំ ១៤៦២ ។ ឯប្រវត្តិសាស្ត្រខ្មែរក៏ចូលមកដល់"សម័យចតុមុខ"ម្តង ។

**សរុប : សម័យអង្គរ រាប់ចាប់ពីឆ្នាំ ៨០២ ដល់ឆ្នាំ ១៤៣១**

## សម័យចតុមុខ

០១- ព្រះបាទ នរាយណ៍រាជា សោយរាជ្យឆ្នាំ១៤៦២ សុគតឆ្នាំ ១៤៦៧

០២- ព្រះបាទ ស្រីរាជា សោយរាជ្យឆ្នាំ១៤៦៧ សុគតឆ្នាំ ១៤៦៨

ចាប់ពីឆ្នាំ ១៤៦៨ នោះមក នគរខ្មែរកើតកលយុគយ៉ាងខ្លាំង ព្រោះបងប្អូននិងក្មួយបានបង្ទ័ពរៀងខ្លួនដើម្បីដណ្តើមគ្នាធ្វើស្តេចរៀង១ខ្លួន ។ ទីបំផុតនគរខ្មែរ

ត្រូវសោយរាជ្យដោយស្ដេចបីអង្គ ហើយទឹកដីក៏បែងចែកជាបីតំបន់ដែរ ។

-ទី ១ ព្រះបាទធម្មរាជា សោយរាជ្យក្រុងចតុមុខ

-ទី ២ ព្រះបាទ ស្រីរាជា គ្រប់គ្រងនៅ បរិបូរ ខេត្តកំពង់ឆ្នាំង

-ទី ៣ ព្រះបាទ ស្រីសុរិយោទ័យ គ្រប់គ្រងនៅ ស្រីសន្ធរ ខេត្តកំពង់ចាម

ក្សត្រទាំងបីដែលត្រូវជាបងប្អូននិងក្មួយនេះច្បាំងគ្នាអស់ជាច្រើនឆ្នាំដើម្បីឡើងសោយរាជ្យជាស្ដេចផ្ដាច់មុខ ធ្វើឱ្យប្រជានុរាស្ត្រជួបទុក្ខសោកវេទនាយ៉ាងខ្លាំងទាល់តែរហូតដល់ឆ្នាំ ១៤៧៤ ទើបនគរវិលមករកភាពប្រក្រតីវិញ ដោយសារព្រះបាទធម្មរាជាប្រើល្បិចកលពឹងពាក់សៀមបង្ខំឱ្យក្សត្រទាំងពីរអង្គនោះចាកចេញទៅគង់នៅក្រុងអាយុធ្យា ក្នុងទឹកដីសៀមរហូតដល់ថ្ងៃសុគត ។ ដូច្នេះព្រះបាទ ធម្មរាជា ក៏គ្រប់គ្រងនគរខ្មែរទាំងមូលចាប់តាំងពីឆ្នាំ ១៤៧៤ នោះមក ។ ដូច្នេះយើងអាចកត់ត្រាទុកថា ព្រះអង្គគឺជាមហាក្សត្រទី៣នៃសម័យចតុមុខ ។ យើងសរសេរដូចខាងក្រោម :

០៣- ព្រះបាទ ធម្មរាជា សោយរាជ្យឆ្នាំ១៤៧៤ សុគតឆ្នាំ ១៤៩៤

ឬអាចសរសេថា ព្រះអង្គសោយរាជ្យចាប់ពីឆ្នាំ ១៤៦៨ មកក៏បានដែរ ព្រោះជាទូទៅ ប្រវត្តិវិទូយល់ថា អ្នកណាកាន់កាប់រាជធានី គឺជាស្ដេចផ្លូវការ ។

០៤- ព្រះបាទសុគន្ធបទ សោយរាជ្យឆ្នាំ១៤៩៤ សុគតឆ្នាំ ១៥០៥

ព្រះបាទសុគន្ធបទ ជាបុត្ររបស់ព្រះបាទធម្មរាជា ក្រោយមកត្រូវនាយកន ធ្វើគុតនៅឆ្នាំ ១៥០៤ ( ឯកសារខ្លះសរសេរថាឆ្នាំ ១៥១២) រួចនាយកនក៏ប្រកាសខ្លួនជាស្ដេច ហើយឡើងគ្រងរាជ្យចាប់ពីពេលនោះមកដោយដាក់នាមថ្មីឱ្យសមជាស្ដេចថា ព្រះបាទស្រីជ័យជេដ្ឋាធិរាជរាមាធិបតី ។ ទោះយ៉ាងណាក្ដី នេះគឺជា

ប្រវត្តិសាស្ត្រដែលយើងត្រូវតែទទួលស្គាល់ ទោះបីស្ដេចកនជាជនក្បត់ដែលបានឡើងសោយរាជ្យដោយគ្មានជាប់សាច់ឈាមនឹងរាជវង្សក៏ដោយ ។ ដូច្នេះយើងអាចកត់ត្រាទុកថា ស្ដេចកន( ព្រះបាទព្រះបាទស្រីជ័យជេដ្ឋាធិរាជរាមាធិបតី គឺជាព្រះមហាក្សត្រទី ៥ នៃសម័យចតុមុខ ។ យើងសរសេរដូចខាងក្រោម :

០៥- ព្រះបាទព្រះបាទស្រីជ័យជេដ្ឋាធិរាជរាមាធិបតី (១៥០៤ ដល់ឆ្នាំ ១៥១៥)

ក្រោយមកស្ដេចកនត្រូវព្រះបាទអង្គចន្ទ័រាជា ( ឯកសារខ្លះសរសេរថា ព្រះបាទអង្គចន្ទ័ទី ១) បង្កទ័ពហើយលើកមកកម្ចាត់ស្ដេចកននិងធ្វើគុតស្ដេចឈាមរាស្ត្រនេះបានសម្រេចនៅឆ្នាំ ១៥១៥ រួចព្រះបាទចន្ទ័រាជាក៏ឡើងសោយរាជ្យចាប់ពីពេលនោះរហូតមក ។ គួបញ្ជាក់ផងដែរថា ក្រោយមកក្សត្រអង្គនេះក៏បានផ្លាស់រាជធានីមកនៅលង្វែក (សព្វថ្ងៃស្ថិតក្នុងខេត្តកំពង់ឆ្នាំង)វិញ ។ រាជធានីនេះបានសាងសង់រួចរាល់នៅឆ្នាំ ១៥២៨ ប៉ុន្តែរហូតមកដល់ឆ្នាំ ១៥២៩ ទើបព្រះបាទចន្ទ័រាជា យាងចូលមកគង់នៅរាជធានីថ្មីនេះ ។ ដូច្នេះ "**សម័យចតុមុខ**" ត្រូវបិទបញ្ចប់នៅឆ្នាំ ១៥២៩ នោះ ហើយប្រវត្តិសាស្ត្រខ្មែរក៏ឈានចូលមកដល់ "**សម័យលង្វែក**" វិញ ។ រីឯព្រះបាទ ចន្ទ័រាជា យើងអាចកត់ត្រាទុកថា ព្រះអង្គគឺជាមហាក្សត្រចុងក្រោយនៃសម័យចតុមុខ និងជាព្រះមហាក្សត្រទី១នៃ "**សម័យលង្វែក**" ។ យើងសរសេរដូចខាងក្រោមនេះ :

# សម័យលង្វែក

| | | |
|---|---|---|
| ០១- | ព្រះបាទចន្ទ័រាជា | សោយរាជ្យឆ្នាំ១៥១៥ សុគតឆ្នាំ ១៥៦៧ |
| ០២- | ព្រះបាទបរមិន្ទរាជា ឬ បរមរាជា | សោយរាជ្យឆ្នាំ១៥៦៧ សុគតឆ្នាំ ១៥៧៩ |
| ០៣- | ព្រះបាទសត្ថា ទី ១ | សោយរាជ្យឆ្នាំ១៥៧៩ ធ្លាក់រាជ្យ ១៥៨៦ |

០៤- ព្រះបាទជ័យជេដ្ឋាទី១ ឬជ័យជេស្ឋា សោយរាជ្យឆ្នាំ១៥៨៦ សុគតឆ្នាំ ១៥៩៣

០៥- ព្រះបាទរាមាជើងព្រៃ សោយរាជ្យឆ្នាំ ១៥៩៤ សុគតឆ្នាំ ១៥៩៦

០៦- ព្រះបាទពញាតន់ សោយរាជ្យឆ្នាំ១៥៩៦ សុគតឆ្នាំ ១៥៩៧

០៧- ព្រះបាទពញាអាន សោយរាជ្យឆ្នាំ១៥៩៧ សុគតឆ្នាំ ១៥៩៩

០៨- ព្រះបាទពញាញោម សោយរាជ្យឆ្នាំ១៥៩៩ សុគតឆ្នាំ ១៦០០

០៩- ព្រះបាទស្រីសុរិយោពណ៌ សោយរាជ្យឆ្នាំ១៦០០ សុគតឆ្នាំ ១៦១៨

# សម័យឧដុង្គ

០១- ព្រះបាទ ជ័យជេដ្ឋា ទី ២ សោយរាជ្យឆ្នាំ១៦១៨ សុគតឆ្នាំ ១៦២៨

០២- ព្រះបាទ រាជសម្ភារ ឬ ពញាតូ សោយរាជ្យឆ្នាំ១៦២៩ សុគតឆ្នាំ ១៦៣៤

០៣- ព្រះបាទ ពញានូ ឬ អង្គទង ទី ១ សោយរាជ្យឆ្នាំ១៦៣៤ សុគតឆ្នាំ ១៦៤០

០៤- ព្រះបាទ អង្គនន់ ទី ១ សោយរាជ្យឆ្នាំ១៦៤០សុគតឆ្នាំ ១៦៤២

០៥- ព្រះបាទរាមាធិបតីចន្ទ័ សោយរាជ្យឆ្នាំ១៦៤២ សុគតឆ្នាំ ១៦៥៨

០៦- ព្រះបាទអង្គសូរ ឬ បទុមរាជា សោយរាជ្យឆ្នាំ១៦៥៨ សុគតឆ្នាំ ១៦៧២

០៧- ព្រះបាទ ជ័យជេដ្ឋា ទី ៣ សោយរាជ្យឆ្នាំ១៦៧២ សុគតឆ្នាំ១៦៧៣
(សោយរាជ្យបាន ៦ ខែ)

០៨- ព្រះបាទអង្គជ័យ សោយរាជ្យឆ្នាំ១៦៧៣ សុគតឆ្នាំ ១៦៧៤

០៩- ព្រះបាទ ជ័យជេដ្ឋា ទី ៤ សោយរាជ្យឆ្នាំ១៦៧៤ ដាក់រាជ្យ ១៧០៦

១០- ព្រះបាទធម្មរាជា ទី២ សោយរាជ្យឆ្នាំ១៧០៦ សុគតឆ្នាំ ១៧១០

១១- ព្រះបាទអង្គអឹម ទី ២ សោយរាជ្យឆ្នាំ១៧១០ សុគតឆ្នាំ១៧២២

| | | |
|---|---|---|
| ១២- | ព្រះបាទ សត្ថា ទី ២ | សោយរាជ្យឆ្នាំ១៧២២ សុគតឆ្នាំ ១៧៣៨ |
| ១៣- | ព្រះបាទ ធម្មរាជា ទី ២ | សោយរាជ្យឆ្នាំ១៧៣៨ សុគតឆ្នាំ ១៧៤៧ |
| ១៤- | ព្រះបាទ ធម្មរាជាអង្គអឹម | សោយរាជ្យឆ្នាំ១៧៤៧ សុគតឆ្នាំ ១៧៤៧ (សោយរាជ្យបាន១ឆ្នាំត្រូវគេធ្វើគុត) |
| ១៥- | ព្រះបាទអង្គទងទី ២ (រជ្ជកាលទី១) | សោយរាជ្យឆ្នាំ១៧៤៧ ធ្លាក់រាជ្យ ១៧៤៩ |
| ១៦- | ព្រះបាទជ័យជេដ្ឋា ទី៥ (អង្គស្ងួន) | សោយរាជ្យឆ្នាំ១៧៤៩ សុគតឆ្នាំ ១៧៥៦ |
| ១៧- | ព្រះបាទ អង្គទងទី២ (រជ្ជកាលទី២) | សោយរាជ្យឆ្នាំ១៧៥៦ សុគតឆ្នាំ ១៧៥៧ (វិលមកសោយរាជ្យជាថ្មី) |
| ១៨- | ព្រះបាទឧទ័យទី ២ ឬ ឧទ័យរាជា | សោយរាជ្យឆ្នាំ១៧៥៨ ដាក់រាជ្យ ១៧៧៥ |
| ១៩- | ព្រះបាទអង្គនន់ ទី ៣ | សោយរាជ្យឆ្នាំ១៧៧៥សុគតឆ្នាំ ១៧៧៩ |
| ២០- | ព្រះបាទ អង្គអេង | សោយរាជ្យឆ្នាំ១៧៧៩ សុគតឆ្នាំ ១៧៩៦ |
| ២១- | រាជ្យសម្តេចចៅហ្វាប៉ុក | គ្រប់គ្រងពីឆ្នាំ១៧៩៦ ធ្លាក់នៅឆ្នាំ១៨០៦ |
| ២២- | ព្រះបាទអង្គចន្ទ័ ទី ២ | សោយរាជ្យឆ្នាំ១៨០៦ សុគតឆ្នាំ ១៨៣៤ |
| ២៣- | ព្រះមហាក្សត្រិយានី អង្គមី | សោយរាជ្យឆ្នាំ១៨៣៤ សុគតឆ្នាំ ១៨៤១ |
| ២៤- | ព្រះបាទអង្គឌួង ឬព្រះហរិរក្សរាមា | សោយរាជ្យឆ្នាំ១៨៤១ សុគតឆ្នាំ ១៨៦០ |

## សម័យអាណានិគមនិយមបារាំង ឬ សម័យភ្នំពេញ

| | | |
|---|---|---|
| ០១- | ព្រះបាទ នរោត្តម | សោយរាជ្យឆ្នាំ១៨៦០ សុគតឆ្នាំ ១៩០៤ |
| ០២- | ព្រះបាទ ស៊ីសុវត្ថិ | សោយរាជ្យឆ្នាំ១៩០៤ សុគតឆ្នាំ ១៩២៧ |
| ០៣- | ព្រះបាទ ស៊ីសុវត្ថិមុនីវង្ស | សោយរាជ្យឆ្នាំ១៩២៧ សុគតឆ្នាំ ១៩៤១ |

០៤- ព្រះបាទ នរោត្តម សីហនុ (រាជ្យ១) សោយរាជ្យឆ្នាំ ១៩៤១ ដល់ឆ្នាំ ១៩៥៥

(ពីឆ្នាំ **១៩៥៥** ដល់ឆ្នាំ **១៩៧០** ហៅថា **សម័យសង្គមរាស្ត្រនិយម**)

០៥- ព្រះបាទ សុរាម្រិត សោយរាជ្យឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៦០

០៦- ម្ចាស់ក្សត្រី កុសុមៈ នារីរតន៏ សោយរាជ្យឆ្នាំ ១៩៦០ ដល់ឆ្នាំ ១៩៧០

## សម័យសាធារណរដ្ឋខ្មែរ_កម្ពុជាប្រជាធិបតេយ្យ (គ្មានស្តេច)

០១- សេនាប្រមុខ លន់ នល់ គ្រប់គ្រងអំណាចពីឆ្នាំ១៩៧០ដល់១៩៧៥

(សម័យសាធារណរដ្ឋខ្មែរ)

០២- សាឡុតស ហៅ ប៉ុល ពត គ្រប់គងអំណាចពីឆ្នាំ ១៩៧៥ដល់១៩៧៩

(សម័យកម្ពុជាប្រជាធិបតេយ្យ)

## សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា (គ្មានស្តេច)

០១- សមមិត្ត ហេង សំរិន ដឹកនាំប្រទេសពីឆ្នាំ ១៩៧៩ដល់ ១៩៨១

០២- សមមិត្ត ប៉ែន សុវណ្ណ ដឹកនាំប្រទេសពីឆ្នាំ ១៩៨១ដល់ ១៩៨១

(ពីខែមិថុនា ដល់ខែ ធ្នូ ១៩៨១)

០៨- សមមិត្ត ចាន់ស៊ី ដឹកនាំប្រទេសពីឆ្នាំ ១៩៨១ដល់ ១៩៨៤

០៩- សមមិត្ត ហ៊ុន សែន ដឹកនាំប្រទេសពីឆ្នាំ ១៩៨៥ដល់ ១៩៨៩

១០- សមមិត្ត ហេង សំរិន (ប្រមុខរដ្ឋ) ដឹកនាំប្រទេសពីឆ្នាំ ១៩៨៩ដល់ ១៩៩១

## "ព្រះរាជាណាចក្រកម្ពុជា"

០១- ព្រះបាទ នរោត្តម សីហនុ(រាជ្យ២) ជាប្រមុខរដ្ឋពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ២០០៤

ចាប់ពីឆ្នាំ ១៩៩៣ ក្រោយពេលកម្ពុជារៀបចំការបោះឆ្នោត ពេលនោះប្រទេសដែលមានប្រវត្តិដ៏មហាអភព្វ័ផុតគេនៅលើផែនដីមួយនេះ ត្រូវបានផ្លាស់មកជា "**ព្រះរាជាណាចក្រកម្ពុជា**" វិញ ឬជាទូទៅគេនិយមហៅថា សម័យ "**រាជានិយមជំនាន់ទី ២**" ព្រោះតាំងពីឆ្នាំ ១៩៧០មក ប្រទេសនេះគ្មានស្តេចទេ ។ ដោយឡែក ទោះបីចាប់តាំងពីឆ្នាំ ១៩៩១ នោះ សម្តេចឪ ព្រះករុណា ព្រះបាទ នរោត្តម សីហនុ យាងចូលប្រទេសជាថ្មី និងឡើងគ្រងរាជ្យម្តងទៀត នៅថ្ងៃទី **២៤** ខែ **កញ្ញា** ឆ្នាំ **១៩៩៣** មែនតែព្រះអង្គមិនកាន់អំណាចទេ ។ ក្រោយមកព្រះអង្គប្រកាសដាក់រាជ្យនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៤ ។ លុះមកដល់ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ដដែល ក្រុមប្រឹក្សារាជសម្បត្តិក៏បានសម្រេចជ្រើសរើសព្រះរាជបុត្ររបស់ព្រះអង្គព្រះនាម នរោត្តម សីហមុនីឡើងគ្រងរាជ្យបន្ត ហើយពិធីឡើងសោយរាជ្យបានប្រារព្ធធ្វើជាផ្លូវការនៅថ្ងៃទី **២៩** ខែ **តុលា** ឆ្នាំ **២០០៤** ព្រះអង្គសោយរាជ្យមកដល់សព្វថ្ងៃ ។

០២- ព្រះបាទ **នរោត្តម សីហមុនី** គ្រងរាជ្យពីឆ្នាំ **២០០៤** ដល់បច្ចុប្បន្ន

..............................

## ទម្លាប់អាក្រក់ក្នុងសង្គមខ្មែរសព្វថ្ងៃ

ព្រលឹមឡើងនិងពេលល្ងាច នៅតាមដងវិថីនានាក្នុងរាជធានីភ្នំពេញ យើងតែងតែឃើញម៉ូតូ ស៊ីក្លូ តុកតុក(កង់បី) និងរថយន្តច្រើនស្អេកស្កះបើកប្រជ្រៀតគ្នាយ៉ាងកុះករគ្រប់ផ្លូវ និងតែងបង្កឱ្យកកស្ទះចរាចរណ៍រៀងរាល់ថ្ងៃជាប្រពៃណី ។ រហូតពេលខ្លះសូម្បីផ្លូវតូចៗចន្លោះផ្ទះល្វែងៗនានា (ផ្លូវឡើងហែម) ក៏កកស្ទះផងដែរ ។ ដោយសារឃើញពីការកកស្ទះចរាចរណ៍នេះ អស់លោកអ្នកធំៗមិននាំគ្នារិះរកវិធានការដោះស្រាយទេ តែបែរជាត្រេកអរណាស់ទៅវិញដោយអួតថា ឃើញទេស្រុកខ្មែររីកចម្រើនណាស់ មានកង់ម៉ូតូ ស៊ីក្លូ ឡាន...អស្ចារ្យណាស់ មិនចាញ់អាមេរិកទេ អ្នកណាថាស្រុកខ្មែរក្រគឺអ្នកនោះអត់បើកភ្នែកឡើយ ហើយនឹងត្រូវគេចំអកថា "អាចាំតែចាំ" ។

ល្មើយ ! ថាស្រុកខ្មែរមានក៏មានចុះ តែកុំភ្លេចថា នៅតាមដងវិថីនានាដែលស្អេកស្កះដោយរថយន្តទំនើបរបស់ពួកអ្នកធំៗនោះក៏ហែមហាមដោយហ្វូងអ្នកសុំទានក្មេងចាស់នាំឱ្យស្ទះចរាចរណ៍មួយផ្នែកផងដែរ ព្រោះពេលឡានទំនើបៗទាំងនោះឈប់ អ្នកសុំទានរត់ទៅសុំលុយពីឡានទំនើបនោះមុនគេ តែកម្រណាស់ដែលពួកអ្នកធំៗទាំងនោះបើកកញ្ចក់ឡានហុចមួយរយរៀលឱ្យពួកមនុស្សទើសភ្នែករបស់ពួកគេទាំងនោះ ហើយគឺអ្នកជិះកង់ម៉ូតូឯណោះទេដែលអាណិតហុចលុយឱ្យ ។ ចំណែកអ្នកជិះក្នុងឡានទំនើបៗនានាតែងតែគ្រវីក្បាលបញ្ជាក់ថា "អត់លុយទេ" រួចថែមទាំងព្រមានអ្នកសុំទានថែមទៀតថា "កុំមកក្បែរឡានអញ តិចកូតថ្នាំខូចអស់..." ។ ពេលឮសម្ដីពួកអភិជនទាំងនេះ នាំឱ្យពួកស្នូមពិភពគុនទាំងឡាយលួចខ្សឹបខ្សៀវដាក់គ្នាថា "ជិះសុទ្ធតែឡានថ្លៃ តែថាអត់លុយមិនគួរឱ្យជឿសោះ" ។ ប៉ុន្តែការលើកឡើងនេះ មិនមែនលើកទឹកចិត្តអ្នកសុំទានឱ្យកែនគ្នាមកពីស្រុកដើរសុំទាននាំឱ្យអាម៉ាស់ដល់អស់លោកអ្នកធំៗតំណាងជាតិទេ តែគួរអាសូរអ្នក

សុំទានណាស់ដែរ បើសិនពួកគេមានលទ្ធភាពធ្វើការងារបានប្រាក់ខែចិញ្ចឹមជីវិតរស់ ឬមានដីស្រែចំការដើម្បីបង្កបង្កើនផលបំពេញក្រពះនោះ ក៏ពួកគេមិនដើរសុំទានតត្រុកនាំឱ្យថោកទាបជីវិតដែរ តែអ្នកខ្លះមានដីស្រែមានចំការតាំងពីដូនតាមកម្លេះ ប៉ុន្តែត្រូវពួកអ្នកធំៗ ឧកញ៉ា ... ប្លន់យកអស់ ។ ហើយរឿងនេះគ្រាន់តែដើរកាត់មុខតូបលក់កាសែតយើងឃើញគេចុះផ្សាយព្រោងព្រាតរាល់ព្រឹកអំពីរឿងប្រជាពលរដ្ឋយំស្រែកព្រោះគេរឹបអូសប្លន់ដីធ្លីនេះ គឺទាំងកាសែតរណប និងកាសែតប្រឆាំងសុទ្ធតែចុះផ្សាយដូចៗគ្នា ។

ឥឡូវនិយាយអំពីទម្លាប់អាក្រក់មួយប្រភេទទៀតដែលកំពុងពេញនិយមក្នុងសង្គមខ្មែរបច្ចុប្បន្ននេះ នោះគឺការដាក់តាំងស្បែកខ្លា(ឯកសណ្ឋាន) ក្នុងឡានដើម្បីបំភ័យប៉ូលីសចរាចរណ៍ ។ ផ្ទាំងទស្សនីយភាពនេះ អ្នកណាក៏ឃើញដែរសព្វថ្ងៃនេះ ។ ហើយដោយសារស្រុកខ្មែរមានប្រពៃណី"យល់យោគ"ឬប្រើភាសាពិសពុលពីរម៉ាត់ថា"គ្នាឯង"នោះ នាំឱ្យការអនុវត្តន៍ច្បាប់មិនស្មើភាពកើតគ្រប់កន្លែង គ្មានអ្នកណាអាចលុបបំបាត់បានឡើយ ។

នៅតាមផ្លូវនានា បើសិនអ្នកជិះម៉ូតូកញ្ចាស់ៗ ឬថ្មីក៏ដោយ បើឈប់ខុសគំនូស អត់ពាក់មួក ឬបត់ខុសភ្លើងចរាចរណ៍ ពួកគេនឹងត្រូវប៉ូលីសរត់ប្រសេចប្រសាចទៅពាំងមុខស្កាត់ផ្លូវទាញកន្ទុយម៉ូតូ ឬប្រើដំបងឆក់គំរាមផាកពិន័យភ្លាម ហើយគ្មានចេញវិក្កយបត្រឱ្យឡើយ ហើយជួនកាលរឿងនេះកើតលើខ្លួនខ្ញុំម្តងម្កាលផងដែរ ប៉ុន្តែបើសិនឃើញឡានទំនើបៗ ហើយនៅក្នុងឡាននោះព្យួរអាវទាហាន អាវប៉ារ៉ាស្បែកខ្លា មានផ្កាយដាំលើស្មាព្រោងព្រាតនោះ ទោះបីឡាននោះបត់ខុសភ្លើង ឬខុសសញ្ញាចរាចរណ៍ក៏ប៉ូលីសទាំងនោះមិនហ៊ានក្អកហៅឱ្យឈប់ដែរ រួចថែមទាំងគំនាប់ឈរគោរពញញឹមធ្វើដៃ"សូមអញ្ជើញតាមសម្រួលទាន"ទៀតផង ។

ដោយឡែក មើលមកតាមភូមិគ្រឹះទំនើបៗរបស់ពួកអ្នកខ្លះវិញ យើងតែងតែឃើញ

ម្ចាស់ភូមិគ្រឹះដាក់តាំងរូបថតរបស់ពួកគេដែលថតជាមួយថ្នាក់ដឹកនាំ ឬអ្នកធំៗនានាព្យួរព្រោងព្រាតពេញជញ្ជាំងផ្ទះ ។ សំនួរសួរថា តើការដាក់តាំងនេះដើម្បីលំអឬយ៉ាងណា ? ការពិតមិនមែនដូច្នេះឡើយ ក្នុងចិត្តអ្នកខ្លះមិនប្រាកដថា ពួកគេស្រលាញ់ឬពេញចិត្តអ្នកធំៗទាំងនោះទេ តែពួកគេដាក់តាំងរូបថតទាំងនោះ គឺដើម្បីសំញ៉ែងអ្នកផង ឬ ភ្ញៀវមកលេងផ្ទះឱ្យដឹងថា ពួកគេមានបក្សពួក មានខ្សែរយៈជាមួយអ្នកនេះ អ្នកនោះ ហើយបើអជ្ញាធរចង់ឆែកឆេផ្ទះគេរកឈើក្រញូង រកថ្នាំញៀនឬអំពើខុសច្បាប់ផ្សេងៗពិតជាស៊យធំអស់សក្តិ អស់តំណែងមិនខាន ។

ដោយឡែក បើនិយាយពីភ្លើងនិងទឹកវិញ ចំពោះប្រជាពលរដ្ឋធម្មតា បើសិនដល់ថ្ងៃបង់សេវាមិនទៅបង់ ឬបង់យឺតយ៉ាវបួនប្រាំថ្ងៃ ពិតជាត្រូវគេផ្តាច់ទឹក ផ្តាច់ភ្លើងលែងឱ្យប្រើប្រាស់មិនខាន ហើយបើចង់ប្រើបន្ត ទាល់តែទទួលការផាកពិន័យទើបគេមកតឱ្យ ។ តែចំពោះផ្ទះអ្នកធំ ទោះហួសមួយខែក៏គ្មានអ្នកណាហ៊ានទៅក្បែរដែរ ។ ប៉ុន្តែខ្ញុំឮថា ពួកអ្នកធំៗខ្លះនៅស្រុកខ្មែរដូចជាប្រើភ្លើង ប្រើទឹកនិងចាក់សាំងឡានមិនអស់លុយទេព្រោះរដ្ឋជាអ្នកចេញលុយឱ្យ ។ ហេតុនេះហើយទើបសង្គមខ្មែរ បើអ្នកក្រកាន់តែក្រទៅ ឯអ្នកមានកាន់តែមានទៅ ដោយសារតែអំពើអយុត្តិធម៌បែបនេះ?ហើយបើអ្នកមិនគិត ពិតជាជាមិនដឹងសោះថា តើរដ្ឋយកលុយពីណាទៅបង់ថ្លៃទឹកថ្លៃភ្លើងឱ្យគ្រឹគ្នាពួកគេនោះទេពិតណាស់ វាជាលុយរបស់យើងទាំងអស់គ្នាដែលបង់ពន្ធរាល់ថ្ងៃលើការទិញប៊ីចេង ទិញស្ករទិញប្រហុក ឬចាក់សាំងនោះឯង ។ ដោយសារអ្នកធំមានបុងសាំងចាក់មិនអស់នោះឯងទើបផ្ទះខ្លះមានឡានបីបួន ប្តីឡានមួយ ប្រពន្ធឡានមួយ កូនឡានម្នាក់មួយ ឬជួនកាលអស់លោកខ្លះទិញឡានឱ្យស្រីលួចលាក់ខាងក្រៅទៀតផងហើយស្រីនោះក៏ចាក់សាំងមិនអស់លុយដែរ ព្រោះនាងក៏មានបុងសាំងដែរ ។ ហេស ! ហេ..ឡូយមែន ! ។

## ស្ថានភាព"អយុត្តិធម៌"ក្នុងសង្គមជាសាកល គឺ :

**បើសិនជាមានរឿងក្តីនៅតុលាការ អ្វីៗនឹងជួបភាពផ្ទុយពីដូចខាងក្រោម :**

**-អ្នកក្រ មិនអាចឈ្នះ អ្នកមានលុយ**

**-អ្នកមានលុយ មិនអាចឈ្នះ អ្នកមានអំណាច**

**បើសិនចង់ក្លាយជាអ្នកនយោបាយត្រឹមត្រូវ ថ្លៃថ្នូរ និងស្មោះត្រង់ បុគ្គលទាំងឡាយត្រូវតែបានទទួលយកលក្ខខណ្ឌ៤ចំណុច :**

**០១- បានរត់ចោលស្រុក**

**០២- បានជាប់គុក**

**០៣- បានព្រាត់ប្រាសបងប្អូន កូនប្រពន្ធ និងឪពុកម្តាយ**

**០៤- បានស្លាប់**

បើមិនអាចទទួលយកលក្ខខណ្ឌទាំង៤យ៉ាងនេះទេ កុំធ្វើនយោបាយឱ្យសោះ បើមិនដូច្នេះទេអ្នកត្រឹមតែអាចក្លាយជាកញ្ជះរបស់គេ ឬត្រឹមតែក្លាយជាអ្នកកេងប្រវ័ញ្ចទ្រព្យសម្បត្តិជាតិ និង ធ្វើឱ្យប្រជាជនឈឺចាប់តែប៉ុណ្ណោះ ព្រោះអ្នកឯងចាំតែលើកដៃ"ហៃអើ !"តាមគេ គឺមិនអាចក្លាយជាអ្នកដឹកនាំនយោបាយ ឬក្លាយជាវីរបុរសជាតិ ល្បីឈ្មោះក្នុងប្រវត្តិសាស្ត្របានទេ ។

**ការយល់ឃើញរបស់ សេង តារា**

# ចំណុចខុសគេគួរឱ្យហួសចិត្តនៅប្រទេសខ្មែរ ដែលប្លែកពីប្រទេសផ្សេងៗ

| ប្រទេសគេផ្សេងៗ | ប្រទេសខ្មែរ |
| --- | --- |
| -ពេលបុណ្យទានធំៗ គេលក់ចុះថ្លៃលើកទឹកចិត្តប្រជាជនគេឱ្យសប្បាយចិត្ត ។ | -ពេលបុណ្យទាន ខ្មែរលក់ទំនិញឡើងថ្លៃកប់ពពកធ្វើឱ្យប្រជាជនគក់ទ្រូង ...។ |
| -ពិធីបុណ្យផ្សេងៗ សំបុត្ររថយន្តឈ្នួល ឬរថភ្លើងបញ្ចុះតម្លៃ ដើម្បីសម្រួលជូនប្រជាជន | -បុណ្យទាន ឡានឈ្នួលឡើងថ្លៃគ្រប់គ្នាធ្វើឱ្យកម្មករកាន់តែក្រលំបាក ។ |
| -ប្រេងឡើងថ្លៃយឺតៗ ចុះថ្លៃលឿន ដើម្បីកុំឱ្យប្រជាជនគេត្អូញត្អែរ និងពិបាកចិត្ត ។ | -ប្រេងឡើងថ្លៃលឿន តែចុះថ្លៃយឺតដូចក្ដាមវារ ជូនកាលភ្លេចចុះថ្លៃទៀតផង ។ |
| -ពេលដល់អាយុចូលនិវត្តន៍ មន្ត្រីគេសប្បាយព្រោះមានឱកាសច្រើនសំរាប់គ្រួសារ ។ | -ដល់អាយុចូលនិវត្តន៍ មន្ត្រីខ្មែរពិបាកចិត្តព្រោះគ្មានឱកាសពុករលួយបន្ត។ |
| -មន្ត្រីគេគិតជាតិមុន ទើបគិតគ្រួសារក្រោយ | -ខ្មែរគិតជាតិក្រោយ គិតគ្រួសារមុន ។ |
| -មន្ត្រីគេធ្វើខុស គេសុំលាលែងតំណែង | -មន្ត្រីខ្មែរធ្វើខុស សុំឡើងតំណែងបន្ថែម |
| -ប្រទេសគេមាន តែមន្ត្រីនិងប្រជាជានគេធ្វើខ្លួនសាមញ្ញ ។ | -ប្រទេសខ្មែរក្រលំបាក ប៉ុន្តែមន្ត្រីខ្មែរនាំគ្នាសំញ៉ែងឡាន វីឡាទំនើបៗ..។ |
| -ពេលប្រជាជនគិតជាតិ គេលើកទឹកចិត្ត | -ប្រជាជនគិតជាតិ គេបំភ័យគំរាម... |
| -ពេលស្ទះចរាចរណ៍ មន្ត្រីគេពិបាកចិត្តហើយនាំគ្នារិះរកវិធីជួយសម្រួល និងដោះស្រាយ ។ | -ពេលស្ទះចរាចរណ៍ មន្ត្រីខ្មែរសប្បាយព្រោះងាយស្រួលផាកយកលុយ ។ |
| -ពេលមានបញ្ញវន្តចេះដឹងច្រើន គេជួយបណ្ដុះបណ្ដាលបន្ថែមដើម្បីឱ្យជួយជាតិរីកចំរើន | -មានអ្នកចេះដឹងផ្ដើមលូតលាស់ រកវិធីក្លិចត្រួយ ដើម្បីកុំគេខ្លាំងពូកែលើសខ្លួន |
| -ប្រជាជនច្រើន តែមន្ត្រីនិងបណ្ឌិតមានតិច | -ប្រជាជនតិច តែមន្ត្រីនិងបណ្ឌិតច្រើន |

..........នៅមានតភាគក្រោយ..........

សូមរង់ចាំអានសៀវភៅថ្មីៗទៀតដែលនឹងចេញ
ផ្សាយនៅពេលឆាប់ៗនេះ គឺសៀវភៅ ៖

ទឹកខ្មៅកវី ភាគ ១
ទឹកខ្មៅកវី ភាគ ២
មាសស្រោបនគរ ភាគ ១៤ ដែលសរសេរ
អំពីស្នាព្រះហស្ថនិពន្ធបទភ្លេង ទំនុកច្រៀង
និងដឹកនាំភាពយន្ត របស់សម្តេចឳ ព្រះបាទ
នរោត្តម សីហនុ ។

សូមអរគុណ !


សេង ដារា អំឡុងឆ្នាំ ១៩៩៤-៩៥
កំពុងរៀនថ្នាក់ទី ៥
មិត្តអ្នកអានអាចទាក់ទងអ្នកនិពន្ធបាន
តាមរយៈ Tel : 012 306 853
សេង ដារា
ឆ្នាំ ២០១១
(២៩ years)
Facebook : seng_dara1982@yahoo.com

# នេះជាសៀវភៅដែលកំពុងចេញលក់




សូមអញ្ជើញរកជាវនៅតាមបណ្ណាគារ
និងបញ្ជរលក់សៀវភៅគ្រប់ខេត្ត-ក្រុង

9789995089436